ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
Ministry of Health

# គោលការណ៍ណែនាំជាតិស្តីពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍លើមនុស្សពេញវ័យនៅកម្ពុជា

# National Guidelines for the use of Antiretroviral Therapy in Adults and Adolescents

ពិនិត្យឡើងវិញនៅខែ មិនា ឆ្នាំ ២០០៧
Revised in March 2007

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
National Center for HIV/AIDS, Dermatology and STD

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# គោលការណ៍ណែនាំជាតិ
# ស្ដីពី
# ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
# លើមនុស្សពេញវ័យនៅកម្ពុជា

ពិនិត្យឡើងវិញនៅខែ មិនា ឆ្នាំ ២០០៧

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

# មាតិកា


អារម្ភកថា ៤

សេចក្តីថ្លែងអំណរគុណ ៥

បញ្ជីពាក្យបំព្រួញ ៦

១ - សេចក្តីផ្តើម ៨

២ - តើការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជាអ្វី? ៨

៣ - គោលការណ៍ជាមូលដ្ឋាននៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ៩

៤ - ការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ១១

*៤.១. ការបញ្ជាក់អំពីការឆ្លងមេរោគអេដស៍ :* ១១

*៤.២. ការពិគ្រោះជំងឺលើកដំបូង* ១១

*៤.៣. ការពិគ្រោះជំងឺលើកទី ២* ១២

*៤.៤. ការពិគ្រោះជំងឺលើកទី ៣* ១៣

៥. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះអ្នកជំងឺអេដស៍ដែលមានជំងឺរបេង ១៤

៦. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះស្ត្រីមានផ្ទៃពោះ និង ស្ត្រីកំពុងបំបៅកូន ១៥

៧. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះអ្នកជំងឺអេដស៍ដែលធ្លាប់ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីមុនរួចហើយ ១៧

៨. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះអ្នកជំងឺអេដស៍ដែលមានជំងឺរលាកថ្លើមប្រភេទ B និង C ១៨

៩. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះអ្នកជំងឺអេដស៍ដែលមានជំងឺឱកាសនិយមផ្សេងៗ ១៨

១០ - សកម្មភាពដែលត្រូវធ្វើជាបន្តចំពោះអ្នកជំងឺអេដស៍ដែលទទួលការព្យាបាលដោយឱសថប្រឆាំងមេ រោគអេដស៍ ១៨

*១០.១. ការគាំទ្រអ្នកជំងឺឱ្យលេបឱសថប្រឆាំងមេរោគអេដស៍ដោយត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់* (Adherence) ១៨

*១០.២. ការតាមដាន ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ :* ២០

*១០.៣. ការធ្វើរោគវិនិច្ឆ័យ និង ការព្យាបាលជំងឺឱកាសនិយម* ២០

*១០.៤. ការធ្វើរោគវិនិច្ឆ័យ និង ការគ្រប់គ្រងផលប៉ះពាល់របស់ឱសថប្រឆាំងមេរោគអេដស៍* ២០

*១០.៥. ការធ្វើរោគវិនិច្ឆ័យ និងការគ្រប់គ្រងព្យាបាលជំងឺមួយចំនួនដែលកើតមានក្រោយពីមាន ការកើនឡើងវិញនៃប្រព័ន្ធ ការពារសារពាង្គកាយ* (Immune Reconstitution)**:** ២១

១១- កាត់បន្ថយជាអតិបរិមានូវការកើនឡើងនៃភាពស៊ាំរបស់មេរោគអេដស៍ទៅនឹងឱសថប្រឆាំងមេរោគ អេដស៍ ២៤

១២ - ផ្តល់ការគាំទ្រ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ២៤

១៣ - គាំទ្រការផ្លាស់ប្តូរការប្រព្រឹត្ត និង បើកចំហអំពីស្ថានភាពផ្ទុកមេរោគអេដស៍ ២៥

១៤ - ការផ្លាស់ប្តូរឱសថប្រឆាំងមេរោគអេដស៍ក្នុងពេលព្យាបាល ២៦
*១៤.១. ផ្លាស់ប្តូរមុខឱសថប្រឆាំងមេរោគអេដស៍ដោយសារផលប៉ះពាល់* ២៦
*១៤.២. ផ្លាស់ប្តូរមុខឱសថប្រឆាំងមេរោគអេដស៍ដោយសារការព្យាបាលទទួលបរាជ័យ* ២៧
១៤.២.១. កត្តាគ្លីនិក (Clinical failure)
១៤.២.២. កត្តាប្រពន្ធ័ការពារសារពាង្គកាយ (Immunological failure)
១៤.២.៣. កត្តាវីរុសសាស្ត្រ (Virological failure)
១៥ - ការផ្លាស់ប្តូរការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីរូបមន្តព្យាបាលជួរទី ១ ទៅរូបមន្ត ព្យាបាលជួរទី ២ វិញ ៣៣
ឯកសារយោង ៣៥

## មាតិកានៃតារាង

តារាង ១ : ព័តិមានជាមូលដ្ឋាននៃជំងឺអេដស៍ ១១
តារាងទី ២ : លក្ខណៈវិនិច្ឆ័យដើម្បីចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ១២
តារាងទី ៣ : អនុសាសន៍នៃការធ្វើតេស្តអមវេជ្ជសាស្ត្រក្នុងកំឡុងពេលព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ១២
តារាងទី ៤ : ស្តង់ដាឱសថប្រឆាំងមេរោគអេដស៍ ក្នុងរូបមន្តព្យាបាលជួរទី១ (First line regimens) ១៣
តារាងទី៥ : ការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍លើអ្នកជំងឺដែលកំពុងទទួលការព្យាបាលជំងឺរបេង ១៥
តារាងទី ៦ : ការចាប់ផ្តើមការព្យាបាលបង្ការ និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះស្ត្រីមានផ្ទៃពោះ ១៦
តារាង ៧ : ផលប៉ះពាល់របស់ឱសថប្រឆាំងមេរោគអេដស៍ ២២
តារាងទី ៨ : ការផ្លាស់ប្តូរឱសថប្រឆាំងមេរោគអេដស៍ដោយសារផលប៉ះពាល់ (សូមអានផ្នែក ១០,៤-១០,៥) ២៦
តារាងទី ៩ : ការគ្រប់គ្រងព្យាបាលចំពោះអ្នកជំងឺដែលសង្ស័យថា ការព្យាបាលដោយ ឱសថប្រឆាំងមេរោគអេដស៍ ត្រូវបរាជ័យដោយកត្តាគ្លីនិក ២៨
តារាងទី ១០ : ការគ្រប់គ្រងព្យាបាលចំពោះអ្នកជំងឺដែលសង្ស័យថា ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ត្រូវបរាជ័យ ដោយកត្តាប្រព័ន្ធការពារសារពាង្គកាយ ៣០
តារាងទី ១១ : លក្ខខ័ណ្ឌក្នុងការសុំធ្វើតេស្ត Viral Load ៣១
តារាងទី ១២ : ការគ្រប់គ្រងព្យាបាលចំពោះអ្នកជំងឺដែលសង្ស័យថា ការព្យាបាលដោយឱសថប្រឆាំង

មេរោគ អេដស៍ត្រូវបរាជ័យដោយកត្តាវីរុសសាស្ត្រ (Virological failure) ៣២
តារាងទី ១៣ : ការគ្រប់គ្រងព្យាបាលអ្នកជំងឺអេដស៍ដែលបញ្ជាក់ ថាការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទទួលបរាជ័យ ៣២
តារាងទី ១៤ : រូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី ២ នៅប្រទេសកម្ពុជា ៣៤
តារាងទី ១៥: កំរិតប្រើឱសថប្រឆាំងមេរោគអេដស៍-រូបមន្តព្យាបាល-ល័ក្ខខ័ណ្ឌ និង ការប្រើលើក្រុមអ្នកជំងឺមួយចំនួន ៣៩
តារាងទី ១៦ : ការគ្រប់គ្រងផលប៉ះពាល់ចំបងៗ នៃឱសថប្រឆាំងមេរោគអេដស៍ ៤៤
តារាងទី ១៧ : លក្ខណៈពិសេស និងការគ្រប់គ្រងនៃ hyperlactacmia ៤៨
តារាងទី ១៨ : ផលប៉ះពាល់របស់ NNRTI (Grade3/4) ក្នុងការសិក្សា 2NN ៥៤
តារាងទី ១៩ : អន្តរកម្មសំខាន់ៗរបស់ឱសថប្រឆាំងមេរោគអេដស៍ ៦២
តារាងទី ២០ : Karnofsky Performance Scale ៦៣

## មាតិកានៃឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ : ការចាត់ថ្នាក់អ្នកជំងឺអេដស៍លើមនុស្សពេញវ័យទៅតាមអនុសាសន៍នៃអង្គការសុខភាពពិភពលោកឆ្នាំ២០០៦ ៣៦
ឧបសម្ព័ន្ធទី ២ : មុខឱសថប្រឆាំងមេរោគអេដស៍ និងផលប៉ះពាល់របស់វា ៣៨
ឧបសម្ព័ន្ធទី ២,១ : ឱសថ Nucleoside Reverse Transcriptase Inhibitors (NRTIs) ៤៨
ឧបសម្ព័ន្ធទី ២,២ : ឱសថ Nucleotide Reverse Transcriptase Inhibitors (NtRTIs) ៥៤
ឧបសម្ព័ន្ធទី ២,៣ : ឱសថ Non-Nucleoside Reverse Transcriptase Inhibitors (NNRTIs) ៥៤
ឧបសម្ព័ន្ធទី ២,៤ : ឱសថ Protease Inhibitors (PIs) ៥៩
ឧបសម្ព័ន្ធទី ៣ : អន្តរកម្មសំខាន់ៗរបស់ឱសថប្រឆាំងមេរោគអេដស៍ ៦២
ឧបសម្ព័ន្ធទី ៤ : ការដាក់ពិន្ទុទៅតាម កាណូហ្វស្គី (Karnofsky Performance Scales) ៦៣

## មាតិកានៃរូបភាព

រូបភាពទី១ : ទំនាក់ទំនង ddI និង ការរលាកលំពែង ៥១
រូបភាពទី២ : ការថយចុះគ្រាប់ឈាមដោយ AZT (AZT-associated anemia) ៥២
រូបភាពទី៣ : ការពុលថ្លើមដោយឱសថប្រឆាំងមេរោគអេដស៍ (ART-associated liver toxicity) ៥៣
រូបភាពទី ៤ : NNRTI-associated rash ៥៧
រូបភាពទី ៥ : EFV-associated CNS symptoms ៥៨

# អារម្ភកថា

នៅព្រះរាជាណាចក្រកម្ពុជាយើង ចាប់តាំងពីឆ្នាំ ១៩៩៨ មក អត្រាឆ្លងមេរោគអេដស៍មានការថយចុះជាបន្តបន្ទាប់ដែលបានទទួលស្គាល់ទាំងថ្នាក់ជាតិ និងអន្តរជាតិ ជាក់ស្តែងអត្រាសេរ៉ូប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍បានថយចុះពី ៣% នៅឆ្នាំ ១៩៩៨ មក ១,៩% នៅឆ្នាំ ២០០៣ ដោយផ្អែកលើលទ្ធផលអង្កេតឈាមរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ។ ទោះបីជាមានការថយចុះនូវអត្រាឆ្លងមេរោគអេដស៍ក៏ដោយ ក៏មានអ្នកផ្ទុកមេរោគ អេដស៍ប្រមាណ ១២៣ ១០០នាក់ និងមានអ្នកជំងឺអេដស៍ប្រមាណ ២០ ០០០នាក់ ព្រមទាំងគ្រួសារគេរាប់សិបនាក់ទៀតដែល ត្រូវការថែទាំព្យាបាល ។

ក្រសួងសុខាភិបាលតាមរយៈមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ បានកំណត់ទិសដៅ និងយុទ្ធសាស្ត្រក្នុងការថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ជាពិសេសការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ ជាក់ស្តែង សេវាថែទាំព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានដាក់បញ្ចូលក្នុង ប្រព័ន្ធថែទាំសុខភាពដែលត្រូវបានពង្រីក និងពង្រឹងជាបន្តបន្ទាប់ដែលកើនឡើងដល់ ៤៤ កន្លែង នៅឆ្នាំ ២០០៦ ក្នុងនោះមាន គ្លីនិកអង្គការមិនមែនរដ្ឋាភិបាលផងដែរ ។ នៅឆ្នាំ ២០០៦ មានអ្នកជំងឺអេដស៍ចំនួន ២០១៣១នាក់ ក្នុងនោះមានកុមារចំនួន ១ ៧៨៧នាក់ បាននឹងកំពុងទទួលការ ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។

ផ្អែកលើវប្បធម៌របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ដែលជានិច្ចកាលធ្វើការសហការជាមួយគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ អ្នកជំនាញបច្ចេកទេសជាតិ និងអន្តរជាតិការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានចូលរួមយ៉ាងសកម្មក្នុងការត្រួតពិនិត្យឡើងវិញនូវគោលការណ៍ណែនាំជាតិដ៏មានសារសំខាន់នេះ ហើយអាចបញ្ចប់តាមកម្មវិធីដែលបានគ្រោងទុក ។

នៅឆ្នាំដដែលនេះ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានសហការជាមួយអ្នកជំនាញបច្ចេកទេសជាតិ និងអន្តរជាតិដើម្បីពិនិត្យមើលឡើងវិញនូវគោលការណ៍ណែនាំជាតិអំពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ក្នុងន័យកែលំអរអោយសមស្របតាមកាលៈទេសៈដែលមានសារៈប្រយោជន៍ដល់មន្ត្រីសុខាភិបាលទាំងផ្នែករដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងឯកជនក្នុងការផ្តល់ការព្យាបាលប្រកបដោយគុណភាព ហើយបញ្ចៀសអោយបានកើតទាបនូវភាពស៊ាំរបស់មេរោគអេដស៍ទៅនឹងឱសថប្រឆាំងមេរោគអេដស៍ ។

ក្រសួងសុខាភិបាលឯកភាពលើគោលការណ៍ណែនាំជាតិស្តីពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដែលបានពិនិត្យឡើងវិញនៅឆ្នាំ២០០៦ នេះ ហើយសង្ឃឹមយ៉ាងមាំលើស្មារតីទទួលខុសត្រូវរបស់មន្ត្រីសុខាភិបាល ទាំងផ្នែករដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជនក្នុងការអនុវត្តន៍តាមដានគោលការណ៍ណែនាំជាតិនេះ អោយទទួលបានលទ្ធផលល្អប្រសើរដើម្បីបង្កើនសុខភាពជូនដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ។

ភ្នំពេញថ្ងៃទី .........ខែ មិនា ឆ្នាំ ២០០៧

# សេចក្តីថ្លែងអំណរគុណ

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ សូមថ្លែងនូវការកោតសសើរដ៏ស្មោះចំពោះការខិតខំរួមគ្នារបស់អ្នកជំនាញបច្ចេកទេសជាតិ និងអន្តរជាតិ ក្នុងការសំរេចបានជាស្ថាពរនូវគោលការណ៍ណែនាំជាតិស្តីពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ ក្នុងឱកាសនេះដែរ មជ្ឈមណ្ឌលជាតិសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារបច្ចេកទេសដែលបានអញ្ជើញមកពីស្ថាប័នជាតិ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងសង្គមស៊ីវិលដែលបានចូលរួមយ៉ាងសកម្ម ក្នុងការរៀបចំឯកសារនេះរួមមាន : មន្ទីរពេទ្យកាល់ម៉ែត្រ មន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត មន្ទីរពេទ្យព្រះកេតុមាលា មន្ទីរ ពេទ្យព្រះកុសមៈ មន្ទីរពេទ្យបង្អែកខេត្ត-ក្រុង ស្រុកប្រតិបត្តិ គ្លីនិកសុខភាពសង្គម មន្ទីរពេទ្យព្រះសីហនុ-មណ្ឌលនៃក្តីសង្ឃឹម អង្គការគ្រូពេទ្យគ្មានព្រំដែនបារាំង និងបែលហ្សិក អង្គការសុខភាពពិភពលោក UNAIDS អង្គការសុខភាពគ្រួសារអន្តរជាតិ បណ្តាញ ESTHER CDC-GAP កាកបាទក្រហមបារាំង មូលនិធិគ្លីនតុន UNSW/NCHADS អង្គការ Maryknol CPN+ អង្គការ Care-Cambodia ។

មជ្ឈមណ្ឌលជាតិសូមថ្លែងអំណរគុណផងដែរដល់មន្ត្រីផ្នែកថែទាំជំងឺអេដស៍ និងលោកវេជ្ជ, Julian Elliot ដែលបានខិតខំសំរួលរាល់កិច្ចសហការជាមួយគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ឈានសំរេចបាននូវលទ្ធផលដ៏ប្រសើរនេះ ។

ភ្នំពេញ ថ្ងៃទី.........ខែ មិនា ឆ្នាំ ២០០៧

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍

សើស្បែក និង កាមរោគ

# បញ្ជីពាក្យបំព្រួញ

| | |
|---|---|
| 3TC | **Lamivudine** |
| ABC | **Abacavir** |
| AIDS | **Aquired Immunodeficiency Syndrome** |
| ALT | **Alanine Transaminase** |
| AST | **Aspartate Transaminase** |
| ARV | **Antiretroviral drug(s)** |
| AZT | **Zidovudine** |
| CBC | **Complete Blood Count** |
| CD4 | **T-CD4+ Lymphocyte** |
| CMV | **Cytomegalovirus** |
| CNS | **Central Nervous System** |
| CK | **Creatine Kinase** |
| CrCl | **Creatinine Clearance** |
| d4T | **Stavudine** |
| ddI | **Didanosine** |
| DOT | **Directly Observed Therapy** |
| EC | **Enteric Coated** |
| EFV | **Efavirenz** |
| EPTB | **Extra-pulmonary Tuberculosis** |
| ESRF | **End Stage Renal Failure (Dialysis dependent)** |
| HAART | **Highly Active Antiretroviral Therapy** |
| HGC | **Hard Gelatin Capsules** |
| HIV | **Human Immunodeficiency Virus** |
| IDV | **Indinavir** |
| IPT | **Isoniazid Preventive Therapy** |
| LDH | **Lactate Dehydrogenase** |
| LDL | **Low-Density Lipoprotein** |

| | |
|---|---|
| LPV | **Lopinavir** |
| LPV/RTV | **Lopinavir/Ritonavir** |
| MTCT | **Mother to Child Transmission** |
| NFV | **Nelfinavir** |
| NNRTI | **Non-Nucleoside Reverse Transcriptase Inhibitor** |
| NRTI | **Nucleoside Reverse Transcriptase Inhibitor** |
| NtRTI | **Nucleotide Reverse Transcriptase Inhibitor** |
| NVP | **Nevirapine** |
| OHL | **Oral Hairy Leukoplakia** |
| OI | **HIV related Opportunistic Infection** |
| PCP | **Pneumocystis carinii pneumonia** |
| PLHA | **Person/people living with HIV/AIDS** |
| PI | **Protease Inhibitor** |
| PID | **Pelvic Inflammatory Disease** |
| PMTCT | **Prevention of Mother to Child Transmission** |
| PPD | **Purified Protein Derivative (skin test for tuberculosis)** |
| PPE | **Papular Pruritic Eruption** |
| PTB | **Pulmonary Tuberculosis** |
| R | **Ritonavir (when given in association with other PIs for boosting effect)** |
| RTV | **Ritonavir** |
| SGC | **Soft Gelatin Capsules** |
| STI | **Sexually Transmitted Infection** |
| SQV | **Saquinavir** |
| TB | **Tuberculosis** |
| TDV | **Tenofovir** |
| TST | **Tuberculin Skin Test** |
| VCCT | **HIV Voluntary Confidentiality Counseling and Testing** |
| VDRL | **Venereal Diseases Reference Laboratory (refers to a test for syphilis)** |

## ១ ~ សេចក្តីផ្តើម

នៅខែមេសា ឆ្នាំ ២០០៦ ប្រទេសកម្ពុជាបានរៀបចំពិធីអបអរអំពីលទ្ធផលក្នុងការសំរេចទិសដៅជាតិដែលកំណត់ ឡើងក្រោមការផ្តួចផ្តើមរបស់អង្គការសុខភាពពិភពលោក គឺ ទិសដៅ 3 by 5 ក្នុងការបង្កើនការផ្តល់សេវាថែទាំ និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍អោយបានចំនួន ១២ ៣៥៥នាក់ នៅដំណាច់ឆ្នាំ ២០០៥ ។ក្រោយពីបានអនុវត្តគំរោងផែនការថែទាំ និង ព្យាបាលបន្ត និង គោលការណ៍ណែនាំជាតិ ស្តីពី ការព្យាបាលដោយឱសថ ប្រឆាំងមេរោគអេដស៍លើមនុស្សពេញវ័យនៅកម្ពុជាដែលបានបោះពុម្ពលើកទី១ ចំនួនអ្នកជំងឺអេដស៍ដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ កើនលើសពី ២០,០០០ នាក់នៅទូទាំងប្រទេស ។ តំរូវការបន្ទាន់ដើម្បីបង្ការការលេចចេញជាជំងឺធ្ងន់ធ្ងរ អសមត្ថភាពបំពេញការងារ និងការ ស្លាប់របស់អ្នកជំងឺអេដស៍នៅក្នុង ប្រទេសកម្ពុជា នៅតែជាចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លានៅឡើយ ។ ទន្ទឹមនឹងនេះត្រូវយកចិត្តទុកដាក់ពង្រឹង ផងដែរនូវការបង្ការជំងឺអេដស៍ តាមរយៈការលើកទឹកចិត្តឱ្យទៅធ្វើតេស្តឈាមរក មេរោគអេដស៍ កាត់បន្ថយការរើសអើង និងកាត់បន្ថយជាអតិបរមា នូវការចំលងមេរោគអេដស៍ ។ ឱសថប្រឆាំងមេរោគ អេដស៍ មិនមែនជាឱសថដែលអាចព្យាបាលជំងឺអេដស៍ឱ្យជាសះស្បើយបាននោះទេ និង មានបញ្ហាជាច្រើនដែលរួមផ្សំក្នុងការ ព្យាបាល ប៉ុន្តែអាយុជាមធ្យម គុណភាពនៃជីវិតរបស់អ្នកជំងឺ ការយល់ដឹងអំពីមេរោគអេដស៍ និងការប្រើប្រាស់សេវាសុខាភិបាល ត្រូវបានកែប្រែឱ្យប្រសើរឡើង ។

ដើម្បីធានាបានគុណភាពក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) ក្រសួងសុខាភិបាល បានឯកភាពដាក់អោយប្រើប្រាស់ជាផ្លូវការនូវគោលណ៍ណែនាំជាតិស្តីពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅឆ្នាំ ២០០១ ហើយបានកែលំអនៅឆ្នាំ ២០០៣ ។ ដូចគ្នានេះដែរ គោលការណ៍ណែនាំជាតិនេះនឹងមិនអាច ឆ្លើយតបទៅនឹង ករណីស្មុគ្រស្មាញមួយចំនួននៅក្នុងការ ប្រតិបត្តិថែទាំជំងឺអេដស៍ជាទូទៅ ឬក៏ក្នុងផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដល់ អ្នកជំងឺអេដស៍ដែលមានលក្ខណៈស្មុគ្រស្មាញនោះ ឡើយ ។

## ២ ~ តើការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជាអ្វី?

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ គឺសំដៅទៅលើការព្យាបាលដោយឱសថទាំងឡាយណាដែលមានសកម្មភាពប្រឆាំងនឹងមេរោគអេដស៍ ។ ឱសថទាំងនេះមានសកម្មភាពទប់ស្កាត់អង់ស៊ីម (Engym) ដែលមេរោគអេដស៍ត្រូវការដើម្បីបំបែកខ្លួនរបស់វា និងចំលងទៅកោសិកាផ្សេងទៀត ។ ឱសថប្រឆាំងមេរោគអេដស៍ដែលកំពុងប្រើប្រាស់នៅប្រទេសកម្ពុជាមាន សកម្មភាពសំដៅ លើអង់ស៊ីមដូចខាងក្រោម :

- Reverse Transcriptase
- Protease

ឱសថប្រឆាំងមេរោគអេដស៍ដែលកំពុងប្រើប្រាស់នៅប្រទេសកម្ពុជាចែកចេញជា ៤ក្រុមសំខាន់ៗ ។ ៣ក្រុមមានតួនាទីទប់ស្កាត់អង់ស៊ីម Reverse Transcriptase និង មួយក្រុមទៀតទប់ស្កាត់អង់ស៊ីម Protease :

- Nucleoside Reverse Transcriptase Inhibitors (NRTI)
- Nucleotide Reverse Transcriptase Inhibitors (NtRTI)
- Non- Nucleoside Reverse Transcriptase Inhibitors (NNRTI)
- Protease Inhibitors (PI)

ឱសថប្រឆាំងមេរោគអេដស៍បីក្រុមផ្សេងទៀតបានបង្ហាញសកម្មភាពប្រឆាំងមេរោគអេដស៍ រួមមាន Entry, Integrase និង Maturation inhibitor ។ ផ្ទុយទៅវិញ នៅពេលបច្ចុប្បន្ននេះឱសថប្រឆាំងមេរោគអេដស៍ពុំទាន់មានប្រើប្រាស់ទូលំទូលាយនៅឡើយទេ ព្រោះមុខឱសថ ARV ភាគច្រើនស្ថិតក្នុងដំណាក់កាលនៃការសិក្សា ។

ឱសថប្រឆាំងមេរោគអេដស៍ដែលបានបញ្ចូលនៅក្នុងគោលការណ៍ណែនាំនេះ គឺជាឱសថទាំងឡាយណាដែលមានប្រសិទ្ធិភាពខ្លាំង និងងាយស្រួលក្នុងការប្រើប្រាស់ ដែលអាចទទួលយកបានសំរាប់ការប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ :

- NRTI: Zidovudine (AZT or ZDV)
  Stavudine (d4T)
  Lamivudine (3TC)
  Didanoside (ddI)
  Abacavir (ABC)
- NtRTI Tenofovir (TDF)
- NNRTI Nevirapine (NVP)
  Efavirenz (EFV)
- PIs Nelfinavir (NFV)
  Indinivir and low dose Ritonavir (IDV/r)
  Lopinivir and low dose Ritonavir (LPV/r)
  Saquinavir and low dose Ritonavir (SQV/r)

- PIs និយមប្រើរួមគ្នាជាមួយ Ritonavir (RTV) ។ ទោះបី Ritonavir ជាឱសថដែលមានថាមពលខ្លាំងស្រាប់ក៏ដោយ ប៉ុន្តែផលប៉ះពាល់បានកំរិតនូវការប្រើប្រាស់របស់វា ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏វាអាចត្រូវបានប្រើប្រាស់ក្នុងកំរិតដូសទាប (Low Dose) ដើម្បីបន្ថយនូវមេតាបូលីស (Metabolism) នៃក្រុម PIs ផ្សេងៗទៀត និង បន្ថយចំនួនពេលនៃការលេបឱសថនេះ ។ Ritonavir គឺត្រូវតែប្រើប្រាស់ជាប្រភេទគ្រាប់ផ្សេងពីគេលើកលែងតែ LPV/r គឺជាគ្រាប់ឱសថមួយគ្រាប់ដែលលាយបញ្ចូលគ្នា ។
- ភាគច្រើននៃឱសថប្រឆាំងមេរោគអេដស៍ដែលអនុញ្ញាតអោយប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា គឺជាឱសថប្រឆាំងមេរោគអេដស៍ដែលរួមបញ្ចូលគ្នា ( ឱសថមួយគ្រាប់ដែលរួមបញ្ចូលគ្នាដោយឱសថប្រឆាំងមេរោគអេដស៍ចំនួន ២ ឬ ៣មុខផ្សេងៗគ្នា) ហើយ ទទួលស្គាល់ដោយអង្គការសុខភាពពិភពលោក រួមមាន :
  - Zidovudine + Lamivudine (AZT + 3TC)
  - Stavudine + Lamivudine (d4T + 3TC)
  - Zidovudine + Lamivudine + Nevirapine (AZT + 3TC + NVP)
  - Stavudine + Lamivudine + Nevirapine (d4T + 3TC + NVP)

## ៣ . គោលការណ៍ជាមូលដ្ឋាននៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

គោលបំណងនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍គឺ:

- ទប់ស្កាត់ អោយបានជាអតិបរមានិងយូរអង្វែងនូវការបំបែកខ្លួនរបស់មេរោគអេដស៍
- ធ្វើអោយមានភាពប្រសើរឡើងវិញនូវមុខងាររបស់ប្រព័ន្ធការពារសារពាង្គកាយ
- ធ្វើអោយប្រសើរឡើងនូវគុណភាពនៃជីវិត

- កាត់បន្ថយនូវអត្រាឈឺ និងអត្រាមរណៈភាពដែលបណ្តាលមកពីមេរោគអេដស៍
- បង្ការនូវភាពស៊ាំរបស់មេរោគអេដស៍ និង ភាពបរាជ័យក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- បង្ការការចំលងមេរោគអេដស៍ពីឪពុកម្តាយទៅទារក

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដែលរួមបញ្ចូលបីមុខ អាចអោយយើងសំរេចបាននូវគោលបំណងទាំងអស់ខាងលើ ។ ការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ រួមគ្នាបែបនេះត្រូវបានគេដឹងថាជាការព្យាបាលដែលមានសកម្មភាពប្រឆាំងមេរោគអេដស៍ខ្ពស់ (Highly active Antiretroviral Therapy “HAART ”) ។

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បីមុខរួមគ្នា អាចកាត់បន្ថយយ៉ាងលឿននូវការបំបែកខ្លួនរបស់មេរោគអេដស៍ដែលធ្វើអោយចំនួនមេរោគអេដស៍នៅក្នុងឈាម (Viral Load) ធ្លាក់ចុះក្រោមកំរិតដែលអាចរកឃើញដោយតេស្ត Viral Load ដែលយើងមានសព្វថ្ងៃ ។ វាបានកាត់បន្ថយនូវឥទ្ធិពលរបស់មេរោគអេដស៍ទៅលើប្រព័ន្ធការពារសារពាង្គកាយ នាំអោយមុខងាររបស់របស់វាប្រសើរឡើងៗ ទាំងបរិមាណ និងគុណភាពដែលបណ្តាលអោយថយចុះនូវគ្រោះថ្នាក់ទាទាបង្កដោយជំងឺឱកាសនិយម ។

ការធ្វើឱ្យបានប្រសើរឡើងនូវប្រព័ន្ធការពារសារពាង្គកាយ ត្រូវការរយៈពេលច្រើនខែ ឬច្រើនឆ្នាំ ប៉ុន្តែវាមិនអាចត្រលប់មកល្អឥតខ្ចោះដូចដើមវិញនោះទេ ។ ការប្រឈមមុខនឹងគ្រោះថ្នាក់ខ្លះៗ នៃជំងឺឱកាសនិយម ឬជំងឺផ្សេងៗទៀតដែលបង្កដោយមេរោគអេដស៍តែងកើតមានក្នុងរយៈពេលមួយកំណត់ ។ ដូច្នេះការបង្ការជំងឺឱកាសនិយម និងការតាមដានជំងឺថ្មីៗដែលបង្កដោយមេរោគអេដស៍ គឺមានសារៈសំខាន់ណាស់ចំពោះអ្នកជំងឺអេដស៍ដែលកំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មិនអាចសំលាប់មេរោគអេដស៍អោយអស់ពីក្នុងឈាមយើងបានទេ ប៉ុន្តែវាគ្រាន់តែទប់ស្កាត់ការបំបែកខ្លួនរបស់មេរោគអេដស៍ប៉ុណ្ណោះ ។ នៅពេលដែលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ត្រូវបានបញ្ឈប់ ចំនួនមេរោគអេដស៍នឹងកើនឡើងដូចមុនការព្យាបាល ហើយចាប់ផ្តើមបំផ្លាញប្រព័ន្ធការពារសារពាង្គកាយសារជាថ្មីម្តងទៀត ។

មេរោគអេដស៍ អាចធ្វើអោយមានការលូតលាស់នូវភាពស៊ាំដោយឯកឯង (Spontaneous genetic mutations) ក្នុងកំរិតខ្ពស់ ។ ប្រសិទ្ធិភាពនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ៣មុខផ្សេងៗ រួមគ្នាអាចកាត់បន្ថយការលូតលាស់នូវភាពស៊ាំដោយឯកឯងបាន (Spontaneous genetic mutations) ដោយបន្តទប់ស្កាត់នូវចំនួនមេរោគអេដស៍ក្នុងឈាមអោយនៅក្នុងកំរិតទាបបំផុត ។ ប្រសិនបើការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍មិនត្រឹមត្រូវមិនទៀងទាត់ និងមិនជាប់លាប់ ទេនោះ (ការប្រើរួមគ្នាមិនត្រឹមត្រូវ ឬប្រើឈប់ៗ) គឺ បណ្តាលអោយមេរោគអេដស៍នៅបន្តបំបែកខ្លួន នាំអោយមានការលូតលាស់នូវក្រុមមេរោគអេដស៍ដែលស៊ាំទៅនឹងឱសថទាំងនេះ ។ ដោយថាហេតុក្រុមមេរោគអេដស៍ដែលស៊ាំនឹងឱសថ នៅតែបន្តលូតលាស់យ៉ាងច្រើនលើសលប់ ជាពិសេស នាំឱ្យការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទទួលបរាជ័យ ។ ម្យ៉ាងវិញទៀតក្រុមមេរោគអេដស៍ដែលស៊ាំនឹងឱសថទាំងនេះនឹងបន្តចំលងទៅអ្នកដទៃទៀតបាន ។

# ៤ ~ ការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

## ៤.១. ការបញ្ជាក់អំពីការឆ្លងមេរោគអេដស៍ :

បញ្ជាក់ថា អ្នកដែលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ គឺ នៅពេលដែលមាន :

- ការប្រព្រឹត្តដែលប្រឈមមុខនឹងការចំលងមេរោគអេដស៍ ( ការប្រព្រឹត្តផ្លូវភេទជាមួយដៃគូច្រើនហើយពុំមានសុវត្ថិភាព, ការប្រើប្រាស់ថ្នាំញៀន)
- ផ្ទៃពោះ
- ជំងឺកាមរោគ
- ជំងឺរបេង
- រោគសញ្ញាដែលសង្ស័យថាមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍

មន្ត្រីសុខាភិបាលទាំងអស់ត្រូវផ្តល់ព័ត៌មានពីសារៈសំខាន់នៃការធ្វើតេស្តឈាមរកមេរោគអេដស៍ ហើយបញ្ជូនទៅធ្វើតេស្តឈាមដោយមានការយល់ព្រមពីសាម៉ីខ្លួនផងដែរ ។

**តារាងទី ១ : ព័ត៌មានជាមូលដ្ឋាននៃជំងឺអេដស៍**

| |
|---|
| មេរោគអេដស៍ គឺជាមេរោគដែលធ្វើអោយប្រព័ន្ធការពារសារពាង្គកាយចុះខ្សោយក្នុងការប្រឆាំងនឹងជំងឺផ្សេងៗ |
| ជំងឺអេដស៍ គឺជាជំងឺដែលកើតឡើងនៅពេលដែលប្រព័ន្ធការពាររាង្គកាយត្រូវបានចុះខ្សោយដោយសារមេរោគអេដស៍ |
| មេរោគអេដស៍ឆ្លងបានតាមការរួមភេទ តាមរយៈឈាម ទឹកកាម និងទឹករំអិលទ្វារមាសស្ត្រី |
| មេរោគអេដស៍ក៏អាចឆ្លងតាមការបញ្ចូលឈាម, ការប្រើប្រាស់ម្ជុលរួមគ្នា ឬឆ្លងពីឪពុកម្តាយទៅកូននៅពេលមានផ្ទៃពោះ, ឈឺពោះសំរាលកូន ឬ ការបំបៅដោះកូន |
| មេរោគអេដស៍មិនអាចឆ្លងតាមរយៈការប្រាស្រ័យទាក់ទងក្នុងសង្គមធម្មតា, ការថើប, បរិភោគម្ហូបអាហាររួមគ្នា ឬសត្វល្អិតទិចឬខាំ |
| មនុស្សអាចឆ្លងមេរោគអេដស៍ ហើយមានសុខភាពល្អជាច្រើនឆ្នាំ |
| ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ គឺគ្រាន់តែពន្យាអាយុជីវិត ប៉ុន្តែមិនអាចព្យាបាលជាសះស្បើយនោះទេ |

## ៤.២. ការពិគ្រោះជំងឺលើកដំបូង

- សួរប្រវត្តិជំងឺពីមុន រួមមាន ធ្លាប់កើតជំងឺរបេង ធ្លាប់ចូលរួមក្នុងកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន និង ធ្លាប់ទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- ប្រវត្តិជំងឺ និងរោគសញ្ញាបច្ចុប្បន្ន ( សូមមើលតារាងទី២)
- វាយតំលៃអំពីដំណាក់កាលជំងឺអេដស៍ផ្អែកតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោកនាពេលបច្ចុប្បន្ន ( សូមមើលតារាងទី២)
- ធ្វើការតាមដានជាប្រចាំ ដូចជា រាប់ចំនួនកោសិកា CD4
- បញ្ជូនទៅសេវាផ្តល់ប្រឹក្សាលើកតំបូង

**តារាងទី ២ : លក្ខណៈវិនិច្ឆ័យដើម្បីចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍**

| WHO Clinical Stage | **សកម្មភាព** |
|---|---|
| ដំណាក់កាលទី ១, ២ ឬ ៣ | ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ប្រសិនបើ CD4 cells ≤ 250 cells/mm$^3$ ហើយអ្នកជំងឺមានលក្ខខ័ណ្ឌផ្នែកចិត្តសាស្ត្រ និងសង្គមឆ្លើយតបទៅនឹងលក្ខខ័ណ្ឌជ្រើសរើស |
| ដំណាក់កាលទី ៤ | ដោយមិនគិតដល់ចំនួន CD4 ត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍សំរាប់អ្នកជំងឺ ទាំងឡាយណា* ដែលបំពេញល័ក្ខខ័ណ្ឌចិត្តសាស្ត្រ និងសង្គម |
| * ចំពោះអ្នកជំងឺអេដស៍មានកោសិកា CD4 ច្រើនជាង 250cells/mm$^3$ : គឺត្រូវពន្យាពេលចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ | |

## ៤.៣. ការពិគ្រោះជំងឺលើកទី ២

- បន្តតាមដាន និងព្យាបាលជំងឺបច្ចុប្បន្ន
- ត្រួតពិនិត្យលទ្ធផលនៃការតាមដានជាប្រចាំ និងប៉ាន់ស្មានអំពីលទ្ធភាពក្នុងការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- មុនចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ គប្បីធ្វើតេស្តអមវេជ្ជសាស្ត្រ ( ប្រសិនបើមាន ដូចជា CBC, SGPT/ALAT, ថតឆ្លុះសួតដោយកាំរស្មី X) ( សូមមើលតារាងទី៣)
- បញ្ជូនទៅជួបអ្នកផ្តល់ប្រឹក្សាមុនចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ( ប្រសិនបើចាំបាច់ត្រូវ ជួបអ្នកផ្តល់ប្រឹក្សាលើសពី ១ដង)

**តារាងទី ៣ : អនុសាសន៍នៃការធ្វើតេស្តអមវេជ្ជសាស្ត្រក្នុងកំឡុងពេលព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍**

| **តេស្តអមវេជ្ជសាស្ត្រ** | **មុនពេលចាប់ផ្តើម ART** | **នៅពេលប្រើ ART** |
|---|---|---|
| **តេស្តរកមេរោគអេដស៍** | ចាំបាច់ត្រូវធ្វើតេស្ត | មិនចាំបាច់ធ្វើតេស្ត |
| **តេស្ត CD4** | ចាំបាច់ត្រូវធ្វើតេស្ត | ត្រូវធ្វើតេស្តរៀងរាល់ ៦ខែ ម្តង |
| **Hemoglobin** | ចាំបាច់ត្រូវធ្វើតេស្ត ប្រសិនបើប្រើ AZT | ប្រសិនប្រើ AZT ត្រូវធ្វើតេស្ត នៅខែទី១, ខែទី២, ខែទី៣, ហើយត្រូវធ្វើរាល់៣-៦ខែ ប្រសិនបើប្រើ AZT ។ |
| **SGPT / ALAT** | ចាំបាច់ត្រូវធ្វើតេស្ត ប្រសិនបើប្រើ NVP ឬ EFV | ប្រសិនប្រើ NVP ឬ EFV ចាំបាច់ត្រូវធ្វើតេស្ត នៅខែទី១, ខែទី២, ខែទី៣, បន្ទាប់មករៀង រាល់៣-៦ ខែម្តង ប្រសិនបើប្រើ NVP ឬ EFV ។ |
| **ការធ្វើតេស្តបញ្ជាក់ថាមានផ្ទៃពោះ** | ចាំបាច់ត្រូវធ្វើតេស្ត ប្រសិនបើប្រើ EFV | ចាំបាច់ត្រូវធ្វើតេស្ត ក្នុងករណីប្រើ EFV និងសង្ស័យថា មានផ្ទៃពោះ ។ |

| | | |
|---|---|---|
| **CBC** | ចាំបាច់ត្រូវធ្វើតេស្ត | អាចធ្វើតេស្តរៀងរាល់ ៣-៦ ខែម្តង |
| **Chest X-ray** | ចាំបាច់ ត្រូវធ្វើតេស្ត | ករណីមានរោគសញ្ញាគ្លីនិក |
| **HIV viral load** | មិនចាំបាច់ធ្វើតេស្ត | អាចធ្វើតេស្ត ក្នុងករណីសង្ស័យថា ការព្យាបាល ទទួលបរាជ័យ |
| **Creatinine** | អាចមានជំរើសនៅគ្រប់ករណី ចាំបាច់ត្រូវធ្វើតេស្ត ប្រសិនបើប្រើ IDV ឬ TDF | អាចធ្វើតេស្តរៀងរាល់ ៦-១២ ខែម្តង |
| **Phosphate** | អាចមានជំរើសក្នុងការធ្វើតេស្ត ប្រសិនប្រើ TDF | អាចធ្វើតេស្តរៀងរាល់ ៣-៦ ខែម្តង ប្រសិនប្រើ TDF |
| **Amylase** | ធ្វើតេស្ត ក្នុងករណីមានសញ្ញាគ្លីនិកកើតឡើង | ករណីមានសញ្ញាគ្លីនិកកើតឡើង |
| **Lipids** | អាចមានជំរើសក្នុងការធ្វើតេស្ត ប្រសិនប្រើ d4T ឬ PI | អាចធ្វើតេស្តរៀងរាល់ ១២ ខែម្តង ប្រសិនប្រើ d4T ឬ PI |
| **Hepatitis B / C serology** | អាចមានជំរើសក្នុងការធ្វើតេស្តនៅគ្រប់ករណី | មិនចាំបាច់ធ្វើតេស្ត |

### ៤.៤. ការពិគ្រោះជំងឺលើកទី ៣

- បន្តតាមដាន និងព្យាបាលជំងឺពេលបច្ចុប្បន្ន
- ពិនិត្យតាមដានលទ្ធផលតេស្តអមគ្លីនិកមុនចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- ធ្វើការសំរេចប្រសិនបើអាចចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- ស្ទាបស្ទង់ការយល់ដឹងរបស់អ្នកជំងឺអេដស៍អំពីមេរោគអេដស៍ និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ ជោគជ័យនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍អាស្រ័យលើការយល់ដឹង និង ការយកចិត្តទុកដាក់របស់អ្នកជំងឺម្នាក់ៗក្នុងពេលព្យាបាល ។ ការពន្យាពេលចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងបញ្ជូនទៅអ្នកផ្តល់ប្រឹក្សា (ART counseling) ប្រសិនបើអ្នកជំងឺពុំទាន់យល់ដឹងច្បាស់អំពីជំងឺអេដស៍ ។
- ប្រសិនបើគ្រូពេទ្យ និងអ្នកជំងឺសំរេចចិត្តថា ចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ សូមជ្រើសរើស ប្រភេទរូបមន្តនៃការព្យាបាល (សូមមើលតារាងទី ៤)

**តារាងទី ៤ : ស្តង់ដាឱសថប្រឆាំងមេរោគអេដស៍ ក្នុងរូបមន្តជួរទី១ (First line regimens)**

| **ស្ថានភាព** | **Regimen** |
|---|---|
| **ស្តង់ដាឱសថប្រឆាំងមេរោគអេដស៍ ក្នុងរូបមន្តជួរទី១** | **d4T + 3TC + NVP** |
| **ជំរើសឱសថប្រឆាំងមេរោគអេដស៍ ក្នុងរូបមន្តជួរទី១ សំរាប់ករណីពិសេស** | |
| ស្ត្រីមានផ្ទៃពោះ | AZT + 3TC + NVP |
| អ្នកមានជំងឺសសៃប្រសាទ Neuropathy | AZT + 3TC + NVP |

| | |
|---|---|
| អ្នកមានជំងឺសរសៃប្រសាទ និងមានភាពស្លេកស្លាំង | ត្រូវសុំយោបល់ពីគ្រូពេទ្យជំនាញ |
| កំពុងព្យាបាលជំងឺរបេងដោយឱសថ rifampicin ប៉ុន្តែគ្មានជំងឺសរសៃប្រសាទ | d4T + 3TC + EFV |
| កំពុងព្យាបាលជំងឺរបេងដោយឱសថ rifampicin និងមានជំងឺសរសៃប្រសាទ | AZT + 3TC + EFV |
| ស្ត្រីមានផ្ទៃពោះដែលកំពុងព្យាបាលជំងឺរបេងដោយឱសថ rifampicin | ត្រូវសុំយោបល់ពីគ្រូពេទ្យជំនាញ |
| SGPT/ALAT > 5 ដងលើសពីតំលៃធម្មតា | d4T + 3TC + EFV |
| SGPT/ALAT > 5 ដងលើសពីតំលៃធម្មតា ព្រមទាំង មានផ្ទៃពោះផង | ត្រូវសុំយោបល់ពីគ្រូពេទ្យជំនាញ |
| អ្នកជំងឺអេដស៍ដែលបានព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍រួចហើយ | ត្រូវសុំយោបល់ពីគ្រូពេទ្យជំនាញ |
| **ស្តង់ដាឱសថប្រឆាំងមេរោគអេដស៍ ក្នុងរូបមន្តជួរទី២** | DDI+3TC+LPV/RTV ឬ<br>TDF+3TC+LPV/RTV |

ប្រតិកម្មរបស់ NVP (ជាពិសេសមានកន្ទួល) អាចកាត់បន្ថយបានដោយចាប់ផ្តើមប្រើ NVP ដោយដូសកំរិតទាប (lower dose) ។ សំរាប់រយៈពេល ២ សប្តាហ៍ដំបូង ត្រូវផ្តល់ d4T + 3TC + NVP លេប ១គ្រាប់ និងលេប d4T+3TC ១គ្រាប់ផ្សេងទៀត ជារៀងរាល់ថ្ងៃ ។ បន្ទាប់មកត្រូវបង្កើនដូស NVP មកកំរិតពេញលេញ ដែលលេបតែ d4T + 3TC + NVP មួយមុខគត់ ២ ដង ក្នុង ១ ថ្ងៃ ។

## ៥. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះអ្នកជំងឺអេដស៍ដែលមានជំងឺរបេង

ត្រូវចាប់ផ្តើមការព្យាបាលជំងឺរបេងភ្លាមៗ បន្ទាប់ពីការធ្វើរោគវិនិច្ឆ័យថាមានជំងឺរបេង និងប្រើប្រាស់រួមផ្សំជាមួយឱសថ Cotrimoxazole ដើម្បី បង្ការជំងឺ PCP ។ ពេលវេលាដែលសមស្របបំផុតដើម្បីចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍មិនទាន់ដឹងច្បាស់នៅឡើយទេនាបច្ចុប្បន្ននេះ (ស្ថិតនៅដំណាក់កាលសិក្សាស្រាវជ្រាវ) ។ ប្រសិនបើចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឆាប់ពេក នោះបណ្តាលឱ្យមានការកើនឡើងនូវផលប៉ះពាល់របស់ឱសថ និងកើនឡើងនូវចង្កោមរោគសញ្ញា ឆ្លើយតបរបស់ប្រព័ន្ធការពារសារពាង្គកាយ (Immune reconstitution inflammatory syndrom “ IRIS”) ដែលធ្វើអោយរោគសញ្ញានៃជំងឺរបេងកាន់តែធ្ងន់ធ្ងរ ។ ប្រសិនបើចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍យឺតពេក នោះអត្រានៃការប្រឈមមុខនឹងជំងឺឱកាសនិយមនឹងមានកំរិតខ្ពស់ ជាពិសេសចំពោះអ្នកជំងឺដែលមានCD4 ទាប (សូមមើលតារាងទី៥) ។

ការជ្រើសរើសពេលវេលាក្នុងការប្រើប្រាស់ឱសថប្រឆាំងនឹងមេរោគអេដស៍ មានការលំបាកដោយសារការប្រើឱសថ **Rifampicin** ក្នុងការព្យាបាលជំងឺរបេង ។ នៅ ពេលខ្លះគេអាចប្រើ d4T+3TC+EFV ដោយត្រូវប្រើ EFV តាមកំរិតដូសស្តង់ដា (តារាងទី ៤) ។ ស្ត្រីគប្បីប្រើឱសថ ពន្យាកំណើតដែលមានប្រសិទ្ធិភាព និងមិនត្រូវប្រើ EFV ក្នុងកំឡុងពេលត្រីមាសទី ១ នៃ រយៈពេលមានផ្ទៃពោះទេ ។

ប្រសិនបើមានរោគសញ្ញាប្រព័ន្ធប្រសាទគប្បីប្រើ AZT ជំនួស d4T វិញ។ ឱសថ NVP គឺជាជំរើសចុងក្រោយខណៈដែលកំរិតដូសត្រឹមត្រូវមិនទាន់អាចកំណត់បាន ហើយក៏អាចពុលថ្លើម (hepatotoxicity) ស្របគ្នាជាមួយនឹងការព្យាបាលជំងឺរបេង ។

ចំពោះអ្នកជំងឺអេដស៍ដែលឆ្លងមេរោគរបេង ក្នុងពេលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នោះ ត្រូវប្តូរ NVP ទៅ EFV វិញ ។ បន្ទាប់ពីបញ្ចប់ការព្យាបាលដោយឱសថប្រឆាំងមេរោគរបេង គេអាចប្រើ NVP ជំនួស EFV លុះត្រាតែចំនួន CD4 ច្រើនជាង 250 cells/mm$^3$ ចំពោះបុរស ។

**តារាងទី ៥ : ការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍លើអ្នកជំងឺដែលកំពុងទទួលការព្យាបាលជំងឺរបេង**

| ចំនួនកោសិកា CD4 | ចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ |
|---|---|
| < 200 cells/mm$^3$ | - ចាប់ផ្តើមព្យាបាលជំងឺរបេង<br>- ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បន្ទាប់ពីការព្យាបាលជំងឺរបេងបានរយៈពេល ២-៨សប្តាហ៍ ( ការព្យាបាលជំងឺរបេងមានតុល្យភាព)<br>- ប្រើ EFV* ដែលមានក្នុងរូបមន្តនៃការព្យាបាលលើកលែងតែស្ត្រីមានផ្ទៃពោះ |
| 200 – 250 cells/mm$^3$ | - ចាប់ផ្តើមព្យាបាលជំងឺរបេង<br>- ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បន្ទាប់ពីបញ្ចប់ការព្យាបាលជំងឺរបេងនៅដំណាក់កាលទី ១ ( រយៈពេល ៨ សប្តាហ៍)<br>- ប្រើ EFV* ដែលមានក្នុងរូបមន្តនៃការព្យាបាលលើកលែងតែស្ត្រីមានផ្ទៃពោះ |
| > 250 cells/mm$^3$ | - ចាប់ផ្តើមព្យាបាលជំងឺរបេង<br>- ពន្យាពេលចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ |

## ៦. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះស្ត្រីមានផ្ទៃពោះ និង ស្ត្រីកំពុងបំបៅកូន

រូបមន្តនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះស្ត្រីមានផ្ទៃពោះ គឺ AZT + 3TC + NVP ។ នៅពេលចាប់ផ្តើមការព្យាបាល អ្នកត្រូវជ្រើសរើសឱសថប្រឆាំងមេរោគអេដស៍ដោយប្រុងប្រយ័ត្ន ។ មិនត្រូវប្រើ Efavirenz ចំពោះស្ត្រីមានផ្ទៃពោះនៅត្រីមាសដំបូងទេ ពីព្រោះអាចបណ្តាលឱ្យប៉ះពាល់សុខភាពកូន (teratogenicity) ។ មានការប្រឈមមុខនឹងការកើនឡើងនូវជាតិ Acid Lactic និងខ្លាញ់ក្នុងថ្លើម (Hepatic steatosis) អំឡុងពេលមានផ្ទៃពោះ ។ Efavirenz អាចបន្តប្រើបាននៅពេលផ្ទៃពោះនៅត្រីមាសទី២ ឬ ត្រីមាសទី៣ ។ មិនត្រូវប្រើ d4T + ddI បូក បញ្ចូលគ្នាទេ ព្រោះវាបណ្តាលឱ្យមានការប្រឈមមុខនឹងគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរថែមទៀត លើកលែងតែក្នុងករណីគ្មានជំរើស ឱសថផ្សេងទៀត ។ សុវត្ថិភាពក្នុងប្រើប្រាស់ TDF ដើម្បីព្យាបាលពេលមានផ្ទៃពោះមិនទាន់អាចកំណត់បាននៅឡើយទេ ។ ដូចនេះ TDF គប្បីប្រើក្នុងកំឡុងពេលមានផ្ទៃពោះ ប្រសិនបើមានសារៈប្រយោជន៍ដល់សុខភាពម្តាយ បើប្រៀបធៀបទៅនឹងការប្រើឱសថផ្សេងទៀត ដូចជា ការប្រើរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី២ ចំពោះអ្នកជំងឺដែលស៊ាំនឹងឱសថប្រឆាំងមេរោគអេដស៍ជួរទី ១ ។ ទិន្នន័យជាច្រើនស្តីអំពីសុវត្ថិភាពរបស់ SQV/r ក្នុងកំឡុងពេលមានផ្ទៃពោះ ជាជាងការប្រើប្រាស់ LPV/r ។ ប្រសិនបើត្រូវប្រើ LPV/r គប្បីប្រើក្នុងកំរិតស្តង់ដា ។

- ប្រើ NNRTIs រួមគ្នាក្នុងការព្យាបាល ទោះបីជាស្ត្រីធ្លាប់បានព្យាបាលដោយឱសថ NVPតែមួយមុខសំរាប់កម្មវិធីកាត់បន្ថយការចំលងមេរោគអេដស៍ពីឪពុកម្តាយទៅកូន ក៏ដោយ ។ ចំពោះស្ត្រីដែលមិនធ្លាប់បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅពេលដែលចាប់ផ្តើមមានផ្ទៃពោះ គប្បីចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

នៅពេលណាក៏បានដែលចាំបាច់ ។ ប្រសិនបើចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅពេលមានផ្ទៃពោះ គឺត្រូវបន្ត ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅក្រោយពេលសំរាល ។

- ស្ត្រីដែលទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ហើយបន្ទាប់មកមានផ្ទៃពោះគប្បីបន្តការព្យាបាលតទៅទៀត ។ គេត្រូវជ្រើសរើសប្រភេទនៃឱសថប្រឆាំងមេរោគអេដស៍ដើម្បីធានាថាមេរោគអេដស៍មានចំនួនតិចបំផុតក្នុងឈាមរបស់ម្តាយនៅពេលសំរាល ព្រោះវាជាចំនុចសំខាន់ក្នុងការព្យាករណ៍អំពីការចំលងមេរោគអេដស៍ពីឪពុកម្តាយទៅកូន ។ ប្រសិនបើដឹងថា ស្ត្រីមានផ្ទៃពោះនៅកំឡុងត្រីមាសទី១ គេត្រូវប្តូរ EFV ទៅឱសថប្រឆាំងមេរោគអេដស៍ផ្សេងវិញ ។ ឱសថ EFV គប្បីប្រើ បន្តចំពោះស្ត្រីមានផ្ទៃពោះក្នុងកំឡុងត្រីមាសទី ២ និង ទី ៣ ។ មិនត្រូវប្រើឱសថប្រឆាំងមេរោគអេដស៍រួមបញ្ចូលគ្នា d4T+ddI ទេ គប្បីប្តូរទៅឱសថប្រឆាំងមេរោគអេដស៍ផ្សេងវិញ ។
- នៅពេលសំរាលកូន ម្តាយត្រូវបន្តប្រើឱសថប្រឆាំងមេរោគអេដស៍ ហើយត្រូវផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដល់ទារកផងដែរ ដោយគោរពតាមគោលការណ៍ណែនាំជាតិស្តីអំពីការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ។ ត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតចំពោះការលេបឱសថប្រឆាំងមេរោគអេដស៍អោយបានត្រឹមត្រូវ និងទៀងទាត់ និង ជាប់លាប់ក្នុងកំឡុងពេល និងបន្ទាប់ពីពេលមានផ្ទៃពោះ គឺជាការចាំបាច់ព្រោះការលេបឱសថប្រឆាំងមេរោគអេដស៍អាចមានការលំបាកនៅក្នុងកំឡុងពេលនេះ ប៉ុន្តែវាមានសារៈសំខាន់សំរាប់សុខភាពម្តាយនិងកាត់បន្ថយការចំលងមេរោគអេដស៍ទៅកូន ។ ការផ្តល់ប្រឹក្សាដល់ម្តាយអំពីឱសថប្រឆាំងមេរោគអេដស៍ទាក់ទងនឹងជំរើសវិធីផ្សេងៗក្នុងការបំបៅកូន គឺមានសារៈសំខាន់ណាស់ ដោយត្រូវផ្អែកទៅតាមគោលការណ៍ណែនាំជាតិស្តីអំពីការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅទារក ។ ស្ត្រីកំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដែលសំរេចចិត្តបំបៅកូនត្រូវតែបន្តការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទៀត ។
- ដោយសារឱសថ NVP និង PIs ភាគច្រើនបន្ថយនូវកំរិតរបស់ឱសថពន្យាកំណើតក្នុងឈាម គេត្រូវប្រើមធ្យោបាយពន្យាកំណើតផ្សេងៗទៀតជំនួសវិញ (ដូចជា ប្រើស្រោមអនាម័យ) ។ ឥទ្ធិពលរវាងឱសថ EFV និង ការពន្យាកំណើតដោយប្រើ hormonal (ការពន្យាកំណើតប្រភេទចាក់) មិនទាន់កំណត់ច្បាស់នៅឡើយ ដូច្នេះជំរើសផ្សេងទៀតសំរាប់ពន្យាកំណើត (ដូចជា ស្រោមអនាម័យ) គប្បីប្រើផងដែរក្នុងស្ថានភាពនេះ ។

**តារាងទី ៦ : ការចាប់ផ្តើមការព្យាបាលបង្ការ និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះស្ត្រីមានផ្ទៃពោះ**

| លក្ខខណ្ឌជ្រើសរើស | ម្តាយ | ទារក |
|---|---|---|
| អាចចាប់ផ្តើមព្យាបាល ចំណាត់របស់អង្គការសុខភាពពិភពលោក ដំណាក់កាលទី ៤ និង ចំនួន CD4 តិចជាង ២៥០ cells/mm[3] | • រូបមន្តព្យាបាល AZT+3TC+NVP[1]<br>• បើមានការស្លេកស្លាំង ត្រូវប្រើ d4T+3TC+NVP | • ប្រើតែមួយដូស NVP នៅពេលសំរាល[2]<br>• ប្រើ AZT រយៈពេល១ សប្តាហ៍[3] |
| មិនទាន់សមស្របក្នុងការទទួលឱសថប្រឆាំងមេរោគអេដស៍ ឬ ប្រសិនបើគ្មាន HAART | • ប្រើ AZT[1] ចាប់ពី សប្តាហ៍ទី ២៨ នៃការមានផ្ទៃពោះ និង ពេលកំពុងសំរាល[4].<br>• ប្រើ NVP តែ១ ដូសនៅពេលសំរាល | • ប្រើតែមួយដូស NVP នៅពេលសំរាល[2]<br>• ប្រើ AZT រយៈពេល១ សប្តាហ៍[3] |

| | | |
|---|---|---|
| | • ប្រើ AZT+3TC រយៈ ៧ ថ្ងៃ ក្រោយពេលសំរាល | |
| ម្តាយទទួលការតាមដានក្រោយពេលសំរាល | • វាយតំលៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ តាមដំណើរធម្មតា | • ប្រើតែមួយដូស NVP នៅពេលសំរាល [2]<br>• ប្រើ AZT រយៈពេល៤សប្តាហ៍[3] |
| [1] មុនចាប់ផ្តើមប្រើ AZT ពិនិត្យ hemoglobin/hematocrit. បើ hemoglobin <90 g/l or hematocrit <33% គឺជំងឺស្លេកស្លាំង ។ ប្រសិនបើ តំរូវឱ្យព្យាបាលដោយ HAART ត្រូវប្រើរូមមន្តព្យាបាលដែលមាន d4T ជាជាងការប្រើរូបមន្តព្យាបាលដែលមាន AZT ។<br>[2]ប្រើតែមួយដូសនៃ NVP 2mg/kg ក្នុងកំឡុងពេល ៧២ ម៉ោង នៅពេលសំរាល<br>[3]ម្តាយទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ តិចជាង ៤ សប្តាហ៍ នៅពេលមានផ្ទៃពោះ ត្រូវផ្តល់ AZT ដល់ទារករយៈពេល ៤ សប្តាហ៍ ។<br>[4]ប្រើ AZT 300mg តែម្តងនៅពេលឈឺពោះសំរាល និង រៀងរាល់ ៣ ម៉ោងម្តងរហូតដល់ពេលសំរាលកូន | | |

## ៧. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះអ្នកជំងឺអេដស៍ដែលធ្លាប់ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីមុនរួចហើយ

ការព្យាបាលអ្នកជំងឺអេដស៍ដែលធ្លាប់ប្រើឱសថប្រឆាំងមេរោគអេដស៍ពីមុន គឺ មានភាពស្មុគ្រស្មាញ ដូចនេះត្រូវតែពិគ្រោះសុំយោបល់ ឬបញ្ជូនអ្នកជំងឺនេះទៅគ្រូពេទ្យជំនាញព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បីមុខរួមបញ្ចូលគ្នាក្នុងពេលវេលាមួយច្បាស់លាស់ និងការបញ្ឈប់ឱសថទាំងអស់ក្នុងពេលដូចគ្នា គឺពុំមានការប្រឈមមុខនឹងភាពស៊ាំរបស់មេរោគអេដស៍នឹងឱសថប្រឆាំងមេរោគអេដស៍ខ្លាំងក្លាពេកទេ ។ ប្រសិនបើមានការវាយតំលៃថា មានការចាំបាច់ក្នុងការចាប់ផ្តើមឡើងវិញនូវការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នោះ គឺត្រូវចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍រួមបញ្ចូលគ្នាបីមុខ ប្រើប្រាស់រូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ ត្រូវប្រើក្រុមឱសថដែលធ្លាប់ប្រើពីមុន ប្រសិនបើវាសមស្របហើយ ដោយមានតុល្យភាពល្អ និងបានប្រើដោយត្រឹមត្រូវបំផុតនោះ : ចំពោះអ្នកជំងឺដែលធ្លាប់ព្យាបាលដោយឱសថក្រុម NRTI ១ ឬ ២ មុខ ក្នុងរយៈពេលតិចជាងពី ២ ទៅ ៣ខែ នោះ គឺ ត្រូវប្តូរមកប្រើឱសថប្រឆាំងមេរោគអេដស៍បីមុខរួមគ្នាវិញ ។ ចំពោះអ្នកជំងឺដែលធ្លាប់ប្រើឱសថក្រុម NRTI ១ ឬ ២ មុខ ក្នុងរយៈពេលលើសពី ២ ទៅ ៣ខែ ហើយនោះ គឺ មានការប្រឈមមុខខ្ពស់នឹងការស៊ាំរបស់មេរោគអេដស៍នឹងឱសថនៃក្រុម NRTI ។ ការគ្រប់គ្រងព្យាបាលអ្នកជំងឺប្រភេទនេះមានភាពស្មុគ្រស្មាញណាស់ ដូចនេះមានវិធីសាស្ត្រមួយគឺត្រូវចាប់ផ្តើមព្យាបាលដោយ ឱសថប្រឆាំងមេរោគតាមរូបមន្ត ព្យាបាលជួរទី១ ។ ប្រសិនបើការព្យាបាលទទួលបរាជ័យនោះគឺត្រូវប្រើឱសថប្រឆាំងមេរោគ អេដស៍ដែលមានប្រសិទ្ធិភាពបំផុតដែលស្ថិតក្នុងក្រុម NRTI, NNRTI និង/រឺ PI ។ រីឯការគ្រប់គ្រងព្យាបាលអ្នកជំងឺអេដស៍ធ្លាប់ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍តាមរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍រួមបញ្ចូលគ្នាមិនសមស្របពីមុនគឺត្រូវប្រែប្រួលទៅតាមប្រវត្តិនៃការព្យាបាលរបស់អ្នកជំងឺម្នាក់ៗ ។ ប្រសិនបើគេមិនដឹងថា គេបានព្យាបាលតាមរូបមន្ត ជួរទី១ទេនោះ គេអាចព្យាបាលតាមរូបមន្ត (d4T+3TC+NVP) ប៉ុន្តែត្រូវធ្វើការតាមដានយ៉ាងជិតដល់អំពីការបរាជ័យនៃការព្យាបាលនោះ ។

## ៨. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះអ្នកជំងឺអេដស៍ដែលមានជំងឺរលាកថ្លើមប្រភេទ B និង C

ការពុលថ្លើមដោយសារឱសថប្រឆាំងមេរោគអេដស៍បានកើនឡើងប្រហែល៣ដង លើអ្នកជំងឺអេដស៍ដែលមានជំងឺរលាកថ្លើមប្រភេទ **B** ឬប្រភេទ **C** ប៉ុន្តែរោគសញ្ញានៃការរលាកថ្លើមនៅតែពុំសូវជួបប្រទះញឹកញាប់ទេ គឺប្រមាណ ១-២% ប៉ុណ្ណោះ ។ ការប្រើឱសថ **NVP** រួមជាមួយឱសថ **d4T+ddI** ត្រូវជៀសវាងចំពោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ដែលមានអង់ហ្ស៊ីមរបស់ថ្លើមមិនធម្មតា គឺមានការកើនឡើង **ALT, AST** រឺ **bilirubin** ។ ឱសថ **3TC** និងឱសថ **TDF** មានសកម្មភាពប្រឆាំងនឹងជំងឺរលាកថ្លើមប្រភេទ **B** ប៉ុន្តែជំរើសក្នុងការប្រើឱសថទាំងពីរមុខនេះ ចំពោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ដែលមានជំងឺរលាកថ្លើមពុំទាន់មានការបញ្ជាក់ច្បាស់នៅឡើយទេហើយនិងមានការលំបាកក្នុងករណីដែលពុំមានតេស្តជាក់លាក់ (Specific test)។ គេសង្កេតឃើញមានការប្រឈមមុខនឹងការកើនឡើងវិញនូវចំនួនវីរុសរលាកថ្លើមប្រភេទ **B** ក្រោយពេលបញ្ឈប់ការព្យាបាលដោយឱសថ **3TC** ឬ **TDF** ។ មេរោគអេដស៍បានធ្វើឱ្យមានការផ្លាស់ប្តូរប្រវត្តិនៃការឆ្លងមេរោគរលាកថ្លើមដែលបណ្តាលឱ្យមានការវិវត្តន៍ទៅរកជំងឺរលាកថ្លើមធ្ងន់ធ្ងរមានអត្រាខ្ពស់ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ និងរលាកថ្លើម ។ វត្តមាននៃមេរោគអេដស៍ គឺមានទាក់ទងជាមួយនឹង អត្រាខ្ពស់នៃការវិវត្តន៍ទៅ រកជំងឺក្រិនថ្លើម ។

## ៩. ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះអ្នកជំងឺអេដស៍ដែលមានជំងឺឱកាសនិយមផ្សេងៗ

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍រួមជាមួយនឹងការព្យាបាលជំងឺឱកាសនិយមផ្សេងៗទៀតក្រៅពីជំងឺរបេង គឺ ពុំទាន់មានការលំបាកទេ ហើយមានការងាយស្រួលនៅក្នុងស្ថានភាពភាគច្រើន ដែលគប្បីពន្យាការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍រហូតទាល់តែជំងឺឱកាសនិយមមានសភាពធូរស្រាល ។ មិនត្រូវចាប់ផ្តើមការព្យាបាល ដោយប្រើ Cotrimxazole និង NVP ក្នុងពេលជាមួយគ្នាទេ ព្រោះមានការពិបាកក្នុងការកំណត់រកមូលហេតុនៃភាពកន្ទួលស្បែក (Skin rash) ដែលកើតឡើង ។ គួរកត់សំគាល់ថា គេអាចចាប់ផ្តើមការព្យាបាលដោយប្រើ គ្រប់ឱសថប្រឆាំងមេរោគអេដស៍ទាំងអស់ក្នុងពេលតែមួយបាន ។ ចំពោះជំងឺឱកាសនិយមមួយចំនួនដែលពុំមានការព្យាបាលប្រកបដោយប្រសិទ្ធិភាពទេនោះ ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឆាប់រហ័ស គឺអាចមានផលប្រយោជន៍ដែលនាំអោយមានការប្រសើរឡើងវិញនូវ ប្រពន្ធ័ការពារសារពាង្គកាយ ។ ការព្យាបាលបង្ការជំងឺឱកាសនិយមត្រូវអនុវត្តតាម " គោលការណ៍ណែនាំជាតិស្ដីពីការព្យាបាលជំងឺឱកាសនិយម "។

## ១០ ៹ សកម្មភាពដែលត្រូវធ្វើជាបន្តចំពោះអ្នកជំងឺអេដស៍ដែលទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

### *១០.១. ការគាំទ្រអ្នកជំងឺឱ្យលេបឱសថប្រឆាំងមេរោគអេដស៍ដោយត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់* (Adherence)

ការលេបឱសថប្រឆាំងមេរោគអេដស៍ដោយត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ (Adherence) ឱ្យបានកំរិតខ្ពស់លើសពី ៩០ភាគរយដោយមិនភ្លេច ឬ ពន្យាពេល ដែលជាកត្តាសំខាន់ក្នុងការទទួលបានជោគជ័យនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ ការលេបឱសថប្រឆាំងមេរោគអេដស៍មិនបានត្រឹមត្រូវ មិនទៀងទាត់ និងមិនជាប់លាប់ (Poor Adherence) គឺបណ្តាលអោយការព្យាបាលទទួលបរាជ័យដែលនាំអោយមេរោគអេដស៍ស៊ាំនឹងឱសថប្រឆាំងមេរោគអេដស៍ ហើយបានបន្ថយនូវជំរើសផ្សេងៗនៃការព្យាបាល (Reduce Treatment options) និងបង្កើននូវតំលៃនៃការព្យាបាលផងដែរ ។ ការលេបឱសថ

ប្រឆាំងមេរោគអេដស៍ត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់រៀងរាល់ថ្ងៃ ហើយត្រូវលេបវា អស់មួយជីវិតដែលជាការងារមួយដ៏លំបាក ។ ជាក់ស្តែង គឺពុំមានអ្នកជំងឺណាម្នាក់អាចលេបឱសថប្រឆាំងមេរោគអេដស៍ បានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ១០០ភាគរយ អស់មួយជីវិតនោះទេ ។ ការវាយតំលៃពីការលេបឱសថប្រឆាំងមេរោគអេដស៍ដោយត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ របស់អ្នកជំងឺអេដស៍ម្នាក់ដោយមន្ត្រីសុខាភិបាលគឺបង្ហាញថា ជាញឹកញាប់ពុំសូវបានអនុវត្តដោយសុក្រិតទេ ។ ដូច្នេះត្រូវចំណាយពេលអោយបានច្រើនក្នុងការគាំទ្រដល់ការលេបឱសថប្រឆាំងមេរោគអេដស៍អោយបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ប្រសើរជាងការវាយតំលៃ ។ មធ្យោបាយដ៏ល្អបំផុតសំរាប់គាំទ្រដល់ការលេបឱសថប្រឆាំងមេរោគអេដស៍អោយបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ត្រូវផ្តោតលើការដោះស្រាយនូវផលវិបាករបស់អ្នកជំងឺដែលកំពុងលេបឱសថប្រឆាំងមេរោគអេដស៍នេះ ។ គេត្រូវបញ្ជូនអ្នកជំងឺអេដស៍ទៅចូលក្រុមគាំទ្រ ឬ ក្រុមមិត្តជួយមិត្ត ដើម្បីលើកទឹកចិត្តគាត់អោយស្វែងយល់ពីមិត្តភ័ក្រ្តអំពីការលេបឱសថនេះឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ (Adherence Supporter) ហើយគប្បីបញ្ចូលគាត់ទៅក្នុងក្រុមដែលគាំទ្រដោយ ក្រុមថែទាំអ្នកជំងឺអេដស៍តាមផ្ទះផងដែរ ។

ការលើកទឹកចិត្តអ្នកជំងឺអេដស៍ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យចូលរួមយ៉ាងសកម្មក្នុងការថែទាំសុខភាពរបស់ពួកគាត់ មានសារៈប្រយោជន៍ក្នុងការជួយពួកគាត់អោយយល់អំពីការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ និងការព្យាបាលព្រមទាំងអោយគាត់រកឃើញនូវឧបសគ្គនានាដែលរារាំងដល់ការលេបឱសថប្រឆាំងមេរោគអេដស៍បានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ហើយគាត់អាចរកមធ្យោបាយដើម្បីជំនះនូវរាល់ឧបសគ្គទាំងអស់នេះ ។ ក្រសួងសុខាភិបាលពុំអនុញ្ញាតអោយអនុវត្តវិធីសាស្រ្ត (ការលេបឱសថ ARV ក្រោមការពិនិត្យដោយផ្ទាល់ភ្នែក) DOT ដោយចុះទៅផ្តល់ឱសថប្រឆាំងមេរោគអេដស៍ផ្ទាល់ដល់អ្នកជំងឺនៅផ្ទះនោះទេ ពីព្រោះវាពុំមាននិរន្តភាពក្នុងរយៈពេលយូរ ។ ការស្វែងយល់នូវគ្រោះថ្នាក់ និងផលប្រយោជន៍អំពីការបើកចំហអំពីស្ថានភាពនៃការផ្ទុកមេរោគអេដស៍របស់អ្នកជំងឺម្នាក់ៗ និងដោយមានការគាំទ្រពីមិត្តភ័ក្តិ និងក្រុមគ្រួសារ គឺជួយជំរុញអោយការលេបឱសថ ARV បានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ដែលធ្វើឱ្យប្រសើរឡើងដ៏គួរអោយកត់សំគាល់ ព្រមទាំងកាត់បន្ថយការរើសអើង ។

គេត្រូវរកអោយឃើញ និងបង្ហាញអំពីបញ្ហាដែលទាក់ទងនឹងបញ្ហាសុខភាពផ្លូវចិត្ត ជាពិសេសអ្នកជំងឺដែលបាក់ទឹកចិត្ត (depression) និងអ្នកជំងឺដែលប្រើប្រាស់នូវសារៈធាតុដែលអាចបង្កគ្រោះថ្នាក់ (Harmful substance) ។ ជាការចាំបាច់ផងដែរក្នុងការបន្ថយជាអប្បបរមានូវចំនួនគ្រាប់ឱសថដែលត្រូវឱ្យអ្នកជំងឺលេបក្នុងមួយថ្ងៃៗ ។ ផលប៉ះពាល់របស់ឱសថប្រឆាំងមេរោគអេដស៍អាចកាត់បន្ថយនូវការលេបឱសថនេះដោយត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ។ លើកទឹកចិត្តអ្នកជំងឺដែលកំពុងប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ឱ្យរាយការណ៍ពីរោគសញ្ញាថ្មីៗដែលកើតឡើងចំពោះពួកគេ ។ រកមើលនូវផលប៉ះពាល់របស់ឱសថ ARV រាល់ពេលអ្នកជំងឺមកពិនិត្យ និងធ្វើការព្យាបាលអោយបានទាន់ពេលវេលា ។ ផលប៉ះពាល់ ដែលជួបប្រទះញឹកញាប់ ហើយសំខាន់ គឺ ការចង្អោរ ក្អួត និងរាគ ហើយក្នុងរយៈពេលយូរ នឹងមានដូចការប្រែប្រួលនៃជាតិខ្លាញ់ (Lipodystrophy) ។ ការបញ្ឈប់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដោយស្មគ្រ័ចិត្ត ជួនកាលត្រូវបានអនុវត្តចំពោះអ្នកជំងឺដែលមាន Seroconversion illness និង ជំងឺឱកាសនិយមមួយចំនួន ពិសេស ចំពោះអ្នកជំងឺទាំងឡាយណាដែលមាន CD4 ទាប ។ ការលេបឱសថប្រឆាំងមេរោគអេដស៍បានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ គឺចាំបាច់ត្រូវអនុវត្តរយៈពេលយូរ ដូចនេះ ត្រូវការពិភាក្សាអំពីប្រធានបទនេះរាល់ពេលអ្នកជំងឺមកពិនិត្យ ។

## ១០.២. ការតាមដានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ :

- គ្រប់អ្នកជំងឺដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ត្រូវមកពិភាក្សាជាមួយគ្រូពេទ្យអំពីការលេបឱសថ និងបញ្ហាសុខភាព នៅ:
  - ៤សប្តាហ៍ (២សប្តាហ៍ប្រសិនបើប្រើ NVP) បន្ទាប់ពីចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
  - រៀងរាល់ខែរហូតដល់អ្នកជំងឺយល់អំពីឱសថប្រឆាំងមេរោគអេដស៍ និងពុំមានបញ្ហាសុខភាពថ្មីៗទៀតឡើយ
  - បន្ទាប់មកត្រូវមកពិនិត្យជារៀងរាល់ខែ យ៉ាងតិច៣ខែដើម្បីទទួលឱសថ និងពិភាក្សាអំពីការលេបឱសថអោយបានត្រឹមត្រូវ ទៀងទាត់ និង ជាប់លាប់ និងរោគសញ្ញាថ្មីៗ ជាមួយសមាជិកផ្សេងៗទៀតនៃក្រុមអ្នកជំងឺដែលបានទទួលការព្យាបាល ។
- សូមសង្កត់ធ្ងន់ទៅលើអ្នកជំងឺដែលកំពុងលេបឱសថប្រឆាំងមេរោគអេដស៍ នូវសារៈសំខាន់នៃការរាយការណ៍អំពីរោគសញ្ញាថ្មីៗអោយបានឆាប់រហ័សតាមដែលអាចធ្វើបាន ។ គ្រូពេទ្យត្រូវសួរ និងពិនិត្យរកមើលរោគសញ្ញាកើតមានថ្មីៗរាល់ពេលពិនិត្យ និងកំណត់រកមើលឱ្យឃើញថា :
  - ជំងឺកើតមានថ្មីដោយរាប់បញ្ចូលជំងឺឱកាសនិយមមួយ (សូមអានតារាងទី ២)
  - ផលប៉ះពាល់របស់ឱសថ
  - ជំងឺមួយចំនួនដែលកើតមានដោយសារការកើនឡើងវិញនៃប្រពន្ធ័ការពារសារពាង្គកាយ (Immune Reconstitution)
- ការតាមដានយ៉ាងទៀងទាត់នូវតេស្តអមវេជ្ជសាស្ត្រមួយចំនួន គឺចាំបាច់មុនពេល និងកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (សូមអានតារាងទី៥) ។ តេស្តអមវេជ្ជសាស្ត្រជាច្រើនបន្ថែមទៀត ត្រូវធ្វើនៅពេលដែលមានរោគសញ្ញាចាំបាច់ ។

## ១០.៣. ការធ្វើរោគវិនិច្ឆ័យ និង ការព្យាបាលជំងឺឱកាសនិយម :

បើទោះជាការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានទទួលលទ្ធផលល្អ ក៏ជំងឺឱកាសនិយមនៅតែអាចកើតមាន ។ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺឱកាសនិយមត្រូវអនុវត្តតាមគោលការណ៍ណែនាំជាតិស្តីអំពីការព្យាបាល និងថែទាំ មនុស្សពេញវ័យដែលផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ។

## ១០.៤. ការធ្វើរោគវិនិច្ឆ័យ និង ការគ្រប់គ្រងផលប៉ះពាល់របស់ឱសថប្រឆាំងមេរោគអេដស៍ :

ការពន្យល់ដល់អ្នកជំងឺដែលកំពុងលេបឱសថប្រឆាំងមេរោគអេដស៍អំពីផលប៉ះពាល់ដែលតែងតែជួបប្រទះជាញឹកញាប់ ជាភារៈកិច្ចសំខាន់របស់អ្នកទទួលបន្ទុកព្យាបាល និងអ្នកផ្តល់ប្រឹក្សា ។ផលប៉ះពាល់របស់ឱសថប្រឆាំងមេរោគអេដស៍ ជាទូទៅតែងកើតមាននៅក្នុងរយៈពេលពី ២-៣សប្តាហ៍ដំបូង ដែលជាទូទៅមិនធ្ងន់ធ្ងរ និងអាចធូរស្រាលទៅវិញបន្ទាប់ពីការព្យាបាលមានរយៈពេលប្រហែលមួយខែក្រោយមក ។ទោះបីជាយ៉ាងណាក៏ដោយ ក៏ផលប៉ះពាល់អាចកើតមានគ្រប់ពេល និងអាចមានសភាព ធ្ងន់ធ្ងរផងដែរ (សូមមើលតារាងទី៦ និង តារាងទី១០ សំរាប់ការគ្រប់គ្រងផលប៉ះពាល់នៃឱសថប្រឆាំងមេរោគអេដស៍) ។

### ១០.៥. ការធ្វើរោគវិនិច្ឆ័យ និងការគ្រប់គ្រងព្យាបាលជំងឺមួយចំនួនដែលកើតមានក្រោយពីមានការកើនឡើងវិញនៃប្រព័ន្ធការពារសារពាង្គកាយ (Immune Reconstitution)៖

រោគសញ្ញា (Symptoms) និងសញ្ញាគ្លីនិក (Signs) នៃជំងឺជាច្រើនដែលបានកើតឡើងនៅពេលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ គឺបណ្តាលមកពីប្រតិកម្មរបស់ប្រព័ន្ធការពារសារពាង្គកាយ ។ នៅពេលដែលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានពង្រឹងលើប្រពន្ធ័ការពារសារពាង្គកាយទៅនឹងជំងឺឱកាសនិយមនានា នោះវាបង្កជារោគសញ្ញាផ្សេងៗជាច្រើនដូចជា:

- ការប្រែក្លាយពី មិនមានរោគសញ្ញានៃជំងឺឱកាសនិយមពីមុនមក ទៅជាមានរោគសញ្ញា
- បង្ហាញអោយឃើញថារោគសញ្ញានៃជំងឺមួយចំនួនប្រែទៅជាធ្ងន់ធ្ងរបើទោះជាការព្យាបាលបានទទួលជោគជ័យក៏ដោយ ។

រោគសញ្ញាទាំងនេះមិនមែនគ្រាន់តែជាលទ្ធផលនៃជំងឺ ឬប្រពន្ធ័ការពារសារពាង្គកាយតែឯកឯងប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាអន្តរកម្មរវាងបញ្ហាទាំងពីរខាងលើនេះដែរ។ ជាទូទៅវាច្រើនកើតមានក្នុងអំឡុងពេល ពីរ ឬបីសប្តាហ៍ដំបូងនៃការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ប៉ុន្តែវាក៏អាចកើតមានគ្រប់ពេលក្នុងអំឡុងពេលពី ៣ ទៅ ៦ខែ ហើយកំរនឹងកើតមានឡើងនៅពេលក្រោយមកទៀត ។

**ជំងឺរបេង** ជាជំងឺសំខាន់បំផុតដែលបណ្តាលមកពីកើនឡើងវិញនៃប្រពន្ធ័ការពារសារពាង្គកាយ (Immune reconstitution) ។ ជួនកាលគេហៅថា "ប្រតិកម្មប៉ារ៉ាដុកស៊ីកាល់ (Paradoxical reaction)" ដែលគេជួបប្រទះផងដែរនៅលើអ្នកគ្មានមេរោគអេដស៍ដែលកំពុងព្យាបាលដោយឱសថព្យាបាលជំងឺរបេង ។ ជាទូទៅរោគសញ្ញាដែលតែងជួបប្រទះ រួមមាន ក្តៅខ្លួន និងមានការរីករាលដាលដំបៅដែលបណ្តាលមកពីជំងឺរបេង ជាពិសេស ការឡើងកូនកណ្តុរ ការរលាកសួត (Pulmonary infiltrates) ការស្ទះបង្ហូរនោម រឺ ជំងឺប្រពន្ធ័សរសៃប្រសាទ ។

ចំណុចសំខាន់ៗនៃការធ្វើរោគវិនិច្ឆ័យលើភាពខុសគ្នារវាងជាតិពុលរបស់ឱសថប្រឆាំងមេរោគអេដស៍ ឬ ការបរាជ័យនៃការព្យាបាលជំងឺរបេងដែលបណ្តាលមកពីភាពស៊ាំរបស់ឱសថ ឬការលេបឱសថមិនត្រឹមត្រូវ មិនទៀងទាត់ និងមិនជាប់លាប់នោះគឺជាការពិបាក ។

វិធីសាស្រ្តទូទៅសំរាប់ការគ្រប់គ្រងការព្យាបាល IRIS គឺ :

- បន្តការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- ចាប់ផ្តើម រឺ បន្តការព្យាបាលទៅតាមរោគសញ្ញានៃជំងឺនានា
- ផ្តល់ការព្យាបាលរយៈពេលខ្លីនូវក្រុមឱសថ Corticosteroids ប្រសិនបើរោគសញ្ញាក្លាយជាធ្ងន់ធ្ងរ ដូចជា ហត់ រោគសញ្ញាប្រពន្ធ័សរសៃប្រសាទ ស្ទះតំរងនោម (Renal obstruction)។ Non-steroidal anti-inflammatory agent អាចប្រើប្រាស់ដើម្បីកាត់បន្ថយរោគសញ្ញាទាក់ទងនឹងការរលាកដូចជាការរលាកកូនកណ្តុរ និងគ្រុនក្តៅ ។

**តារាងទី ៧ : ផលប៉ះពាល់របស់ឱសថប្រឆាំងមេរោគអេដស៍**

| ឱសថ និង ក្រុមឱសថ | ចំណាត់ថ្នាក់នៃផលប៉ះពាល់ តាមក្រុមឱសថនិមួយៗ | ចំណាត់ថ្នាក់នៃផលប៉ះពាល់ របស់ឱសថនិមួយៗ | | | | |
|---|---|---|---|---|---|---|
| | | ស្បែក | ឈាម | ប្រដាប់រំលាយអាហារ | ប្រព័ន្ធសសៃប្រសាទ | ផ្សេងៗ |
| Zidovudine (ZDV or AZT) | | | - ស្លេកស្លាំង<br>- ថយចុះគ្រាប់ឈាមស | ចង្អោរ (ញឹកញាប់) | - ឈឺក្បាល (ញឹកញាប់)<br>- ជំងឺសាច់ដុំ<br>- ជំងឺបេះដូង | |
| Stavudine (d4T) | -ការបាត់បង់នៃជាតិខ្លាញ់<br>-ឡើងជាតិអាស៊ីត ឡាក់ទិក<br>- ពុលថ្លើម | | | - រលាកលំពែង (កំរ)<br>- ពុលថ្លើម | -រលាកសសៃប្រសាទសើស្បែក<br>Guillain-Barre like syndrome | - បាត់បង់ជាតិខ្លាញ់<br>- ឡើងជាតិអាស៊ីត ឡាក់ទិក |
| Lamivudine (3TC) | | | ថយចុះគ្រាប់ឈាមស (កំរ) | រលាកលំពែង (កំរ) | -រលាកសសៃប្រសាទសើស្បែក(កំរ)<br>-ឈឺក្បាល (មិនសូវញឹក ញាប់) | មិនមានផលប៉ះពាល់ធំដុំទេ |
| Didanosine (ddI) | | | | រលាកលំពែង រាគ ចង្អោរ ក្អួត ឈឺពោះ | រលាកសសៃប្រសាទសើស្បែក<br>Peripheral neuropathy | |
| Abacavir (ABC) | | | | | | ប្រតិកម្ម (Hypersensitivity $s^d$) |
| Tenofovir (TFV or TDF) | | | | | | មិនមានផលប៉ះពាល់ធំដុំទេ |
| Nevirapine (NVP) | កន្ទួលស្បែក (Rash)<br>រលាកថ្លើម | កន្ទួលស្បែក | | រលាកថ្លើម | | ប្រតិកម្ម (Hypersensitivity $s^d$) |

| | | | | | | |
|---|---|---|---|---|---|---|
| Efavirenz (EFV) | | កន្ទួលស្បែក | | រលាកថ្លើម | រលាកប្រពន្ធ័សសៃប្រសាទញ៉ឹកញាប់ | *ប៉ះពាល់ដល់ទារក ក្នុងផ្ទៃ (Teratogenicity)* |
| Nelfinavir (NFV) | - ការប្រែប្រួលជាតិខ្លាញ់<br>- ស៊ាំនឹងជាតិ Insulin និង ជំងឺទឹកនោមផ្អែម<br>- ឡើងជាតិ ខ្លាញ់ ក្នុងឈាម<br>- រលាកថ្លើម<br>- ការប្រែប្រួលនៃឆ្អឹង<br>- កើនឡើងនូវ ការហូរឈាមចំពោះជំងឺ hemophiliacs | កន្ទួលស្បែក | | រាគ ឈឺពោះ | | |
| Indinavir + Ritonivir (IDV/r) | | - ជ្រុះសក់<br>- ស្ងួតស្បែក និងបបូរមាត់ | | - ឡើងជាតិ bilirubine ក្នុងឈាម<br>- Oesophageal reflux | ស្ពឹក | គ្រួសតំរងនោម |
| Lopinavir + Ritonavir (LPV/r) | | | | រាគ | ស្ពឹក | ឡើងជាតិខ្លាញ់ក្នុងឈាម |
| Saquinavir + Ritonavir (SQV/r) | | | | - ចង្អោរ<br>- រាគ | - ឈឺក្បាល<br>- ស្ពឹក | |

## ១១. កាត់បន្ថយជាអតិបរិមានូវការកើនឡើងនៃភាពស៊ាំរបស់មេរោគអេដស៍ទៅនឹងឱសថប្រឆាំងមេរោគអេដស៍:

ការកើនឡើងនៃភាពស៊ាំរបស់មេរោគទៅនឹងឱសថ គឺ ជាផលវិបាកដែលមិនអាចជៀសរួចចំពោះការព្យាបាលជំងឺឆ្លងមួយចំនួន ប៉ុន្តែវាមិនមែនជាអំណះអំណាងគ្រប់គ្រាន់ក្នុងការបញ្ឈប់ការព្យាបាលទេ ។ ភាពស៊ាំរបស់មេរោគអេដស៍ចំពោះឱសថប្រឆាំងមេរោគអេដស៍ បានកាត់បន្ថយនូវប្រសិទ្ធិភាពនៃការព្យាបាល និងបង្កើនថ្លៃព្យាបាល ហើយមេរោគអេដស៍ដែលស៊ាំនឹងឱសថអាចឆ្លងទៅអ្នកដទៃទៀតផង ។ ដូចនេះការផ្តល់ការគាំទ្រដល់ការលេបឱសថប្រឆាំងមេរោគអេដស៍អោយបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ (adherence) គឺជាមធ្យោបាយប្រសើរក្នុងការកាត់បន្ថយភាពស៊ាំ ពីព្រោះ adherence ទាបជាមូលហេតុចំបងនាំឱ្យមានភាពស៊ាំរបស់មេរោគអេដស៍ ទៅនឹងឱសថប្រឆាំងមេរោគអេដស៍ (សូមអានផ្នែក ១០.១) ។

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍មិនសមស្របដោយអ្នកដែលមិនបានបណ្តុះបណ្តាលជំនាញនេះ ក៏ជាមូលហេតុដ៏សំខាន់នៃភាពស៊ាំរបស់មេរោគអេដស៍ចំពោះឱសថប្រឆាំងមេរោគអេដស៍នេះផងដែរ ។ ឱសថប្រឆាំងមេរោគអេដស៍ត្រូវតែមានវេជ្ជបញ្ជាចេញដោយក្រុមវេជ្ជបណ្ឌិត ឬគ្រូពេទ្យដែលបានបណ្តុះបណ្តាលរួចហើយតែប៉ុណ្ណោះ ដែលធានាបានយ៉ាងត្រឹមត្រូវក្នុងការប្រើឱសថប្រឆាំងមេរោគអេដស៍នេះ ដូចជា ការជ្រើសរើសរូបមន្តព្យាបាលត្រឹមត្រូវ កំរិតប្រើរបស់ឱសថ ការតាមដាន ការផ្គត់ផ្គង់ឱសថ និងការផ្លាស់ប្តូររូបមន្តព្យាបាលដ៏សមស្រប ។

ក្រសួងសុខាភិបាលមិនអនុញ្ញាតអោយប្រើឱសថប្រឆាំងមេរោគអេដស៍ដែលមានប្រសិទ្ធិភាពតិចជាងបីមុខរួមគ្នាទេ ។ ប្រសិនបើឱសថប្រឆាំងមេរោគអេដស៍ណាមួយត្រូវបានបញ្ឈប់នោះ គឺត្រូវបញ្ឈប់គ្រប់ឱសថប្រឆាំងមេរោគអេដស៍ទាំងអស់រហូតដល់ពេលដែលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទាំងអស់ត្រូវបានចាប់ផ្តើមឡើងវិញ ។ គេត្រូវបន្តប្រើប្រាស់ក្រុម NRTIs ពី ១០ ទៅ ១៤ ថ្ងៃ ក្រោយពេលបញ្ឈប់ NVP ឬ EFV ពីព្រោះរយៈពេលដែល NVP/EFV បន្តនៅក្នុងឈាមមានរយៈពេលវែងជាងក្រុម NRTIs ។

ការកាត់បន្ថយនូវការប្រព្រឹត្តដែលប្រឈមមុខខ្ពស់នឹងភាពស៊ាំរបស់មេរោគអេដស៍ទៅនឹងឱសថប្រឆាំងមេរោគអេដស៍ចំពោះអ្នកដែលកំពុងព្យាបាលដោយឱសថនេះ គឺជាយន្តការមួយដ៏សំខាន់ណាស់ក្នុងការកាត់បន្ថយការរីករាលដាលនៃ មេរោគអេដស៍ដែលស៊ាំនឹងឱសថប្រឆាំងមេរោគអេដស៍នោះ។ ការលេបឱសថប្រឆាំងមេរោគអេដស៍ ឱ្យបានត្រឹមត្រូវ ជាប់លាប់ និង ទៀងទាត់ គឺជាកត្តាសំខាន់ផងដែរក្នុងការកាត់បន្ថយនូវចំនួនមេរោគអេដស៍ក្នុងឈាម និងសារធាតុរាវពីរាងកាយ និងបន្ថយនូវភាពគ្រោះថ្នាក់នៃការចំលងមេរោគអេដស៍ ។

## ១២ . ផ្តល់ការគាំទ្រ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ :

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍តែឯកឯង គឺមិនគ្រប់គ្រាន់ទេ ព្រោះថា ជោគជ័យនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ក៏អាស្រ័យផងដែរទៅលើវិធីសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងការឆ្លើយតបទៅនឹងតំរូវការរបស់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដូចជា :

- ការគាំទ្រផ្នែកចិត្តសាស្ត្រ : ការគាំទ្រផ្នែកចិត្តសាស្ត្រ នៅពេលដែលអ្នកជំងឺជួបប្រទះការលំបាក គឺអាចទទួលបានលទ្ធផលល្អយូរអង្វែង
- ការគាំទ្រផ្នែកអាហារូបត្ថម្ភ : មានអ្នកជំងឺជាច្រើនដែលអាចមានលទ្ធភាពទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ប៉ុន្តែមិនមានចំណីអាហារគ្រប់គ្រាន់ទេ ។ ចំណុចនេះគួរតែត្រូវបានយកចិត្តទុកដាក់ដល់គ្រប់អ្នកជំងឺដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។
- ការគាំទ្រផ្នែកសង្គម និងហិរញ្ញវត្ថុអាចជួយអ្នកជំងឺអេដស៍ឱ្យកាន់តែមាំមួនឡើង ។ ការបង្កើតមុខរបរដើម្បីបង្កើនប្រាក់ចំណូល និងការបណ្តុះបណ្តាល ដើម្បីឱ្យពួកគេមានភាពម្ចាស់ការលើផ្នែកសេដ្ឋកិច្ចអាចជាការងារសំខាន់ផងដែរ ។

ការទំនាក់ទំនងជាមួយនឹងសេវាដែលមានស្រាប់ គឺជាកត្តាសំខាន់នៃជោគជ័យនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ជាពិសេស ជាមួយក្រុមថែទាំជំងឺអេដស៍តាមផ្ទះ និងក្រុមមិត្តគាំទ្រមិត្តរបស់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ មានចែងក្នុងគោលការណ៍ណែនាំស្តីពីការថែទាំ និងព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដែលជាមធ្យោបាយសំរាប់ផ្សារភ្ជាប់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទៅក្នុងវិធីសាស្ត្រថែទាំព្យាបាលបន្តគ្រប់ជ្រុងជ្រោយ ។

## ១៣ ~ គាំទ្រការផ្លាស់ប្តូរការប្រព្រឹត្ត និង បើកចំហរអំពីស្ថានភាពផ្ទុកមេរោគអេដស៍ :

ពេលវេលាដែលសមស្រប ដើម្បរកឱ្យឃើញនូវការប្រព្រឹត្តដែលប្រឈមមុខខ្ពស់ គឺនៅក្នុងរយៈពេល ២ ឬ ៣ខែ បន្ទាប់ពីចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ ដូចនេះ គេត្រូវសួរអំពីការប្រព្រឹត្តផ្លូវភេទ ការប្រើប្រាស់ស្រោមអនាម័យ ផែនការពន្យារកំណើត និងការប្រើប្រាស់ឱសថពន្យារកំណើត ។ គេត្រូវគាំទ្រឱ្យមានការអនុវត្តន៍សុវត្ថិភាពផ្លូវភេទជាវៀងរហូត ។

គេត្រូវពង្រឹងការអប់រំដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដោយផ្តោតលើ :

- មិនគប្បីផ្តល់ឈាម ឬសារធាតុរាវទៅអោយអ្នកដទៃទេ
- មិនត្រូវអោយអ្នកដទៃប្រើប្រាស់នូវម្ជុល ឬវត្ថុមុតស្រួចដែលបានប្រើរួចហើយនោះទេ

រកឱ្យឃើញនូវគ្រោះថ្នាក់ និងផលចំណេញពីការបើកចំហនូវស្ថានភាពផ្ទុកមេរោគអេដស៍របស់នរណាម្នាក់ រួមទាំងចំពោះដៃគូរួមភេទរបស់ពួកគេផងដែរ ។ វាជាការខុសឆ្គងមួយក្នុងការធានាថា ពុំមានអ្នកដទៃណាម្នាក់ទៀតដែលទទួលរងនូវការឆ្លងមេរោគអេដស៍ពីអ្នកជំងឺរបស់យើងឡើយ និងផ្តល់ការគាំទ្រយ៉ាងធំធេងពីការបើកចំហស្ថានភាពនៃការផ្ទុកមេរោគអេដស៍នេះ ប៉ុន្តែករណីនេះត្រូវមានតុល្យភាពជាមួយ នឹងការប្រឈមមុខនឹងការរើសអើង ឬមើលងាយនៅថ្ងៃខាងមុខ ។

# ១៤ ~ ការផ្លាស់ប្ដូរឱសថប្រឆាំងមេរោគអេដស៍ក្នុងពេលព្យាបាល :

## ១៤.១. ផ្លាស់ប្ដូរមុខឱសថប្រឆាំងមេរោគអេដស៍ដោយសារផលប៉ះពាល់:

បើតំរូវឱ្យមានការផ្លាស់ប្ដូរមុខឱសថប្រឆាំងមេរោគអេដស៍ណាមួយ គេត្រូវផ្លាស់មុខឱសថទាំងអស់នៅក្នុងរូបមន្តព្យាបាល ។ ប៉ុន្តែបន្តប្រើប្រាស់ NRTIs រយៈពេល ១០-១៤ ថ្ងៃ បន្ទាប់ពី NVP ឬ EFV ត្រូវបានបញ្ឈប់ពីព្រោះ រយៈពេលដែល NVP/EFV បន្តនៅក្នុងឈាមយើងមានរយៈពេលវែងជាង NRTIs ។ ដើម្បីអោយបានច្បាស់អំពីបញ្ហានេះ ត្រូវមើល " រោគវិនិច្ឆ័យ និងការគ្រប់គ្រងផលប៉ះពាល់ដោយឱសថប្រឆាំងមេរោគអេដស៍ " (សូមអានតារាងទី ៨ ខាងក្រោម និង តារាងទី ៦ ឧបសម្ព័ន្ធទី ២ និង តារាង ១០ សំរាប់ព័ត៌មានលំអិត) ។

**តារាងទី ៨ : ការផ្លាស់ប្ដូរមុខឱសថប្រឆាំងមេរោគអេដស៍ដោយសារផលប៉ះពាល់ (ARV side effect)**

| ឱសថ | ផលប៉ះពាល់ | ដំណោះស្រាយភ្លាមៗ | ដំណោះស្រាយពេលអនាគត |
|---|---|---|---|
| **NRTI** | -ការផ្លាស់ប្ដូរ-បាត់បង់ស្រទាប់ខ្លាញ់ | ពិចារណាក្នុងការប្ដូរ NRTI (d4T រឺ ddI រឺ AZT) ទៅ ABC | អាចប្រើឱសថទាំងនេះម្ដងទៀតបាន ប៉ុន្តែនឹង ធ្វើឱ្យការបាត់បង់ស្រទាប់ខ្លាញ់ ប្រែជាធ្ងន់ធ្ងរ |
| | - ឡើងជាតិអាស៊ីត ឡាក់ទិក | ត្រូវប្ដូរ NRTI ទៅ ABC រឺ TDF | ព្យាយាមជៀសវាង ការប្រើ AZT, d4T រឺ ddI ម្ដងទៀត |
| **AZT** | - ស្លេកស្លាំង (Hb<80 g/l or fall > 25%) | ត្រូវប្ដូរ AZT ទៅ d4T | មិនត្រូវប្រើ AZT ម្ដងទៀតទេ |
| | - ថយចុះគ្រាប់ ឈាមស (neutrophils < 1.0x$10^6$/l) | ត្រូវប្ដូរ AZT ទៅ d4T | មិនត្រូវប្រើ AZT ម្ដងទៀតទេ |
| **d4T** | -រលាកសសៃ ប្រសាទសើស្បែក (Peripheral neuropathy): មធ្យម-ធ្ងន់ធ្ងរ | ត្រូវប្ដូរ d4T ទៅ AZT | មិនត្រូវប្រើ d4T ម្ដងទៀតទេ |
| **ddI** | - រលាកលំពែង<br>-រលាកសសៃប្រសាទសើស្បែក | ត្រូវប្ដូរ ddI ទៅ NRTI ផ្សេងទៀត ក្រៅពី d4T | មិនត្រូវប្រើ ddI ម្ដងទៀតទេ |
| **ABC** | - ប្រតិកម្ម (Hypersensitivity Syndrome) | ត្រូវប្ដូរ ABC ទៅឱសថ ARV ផ្សេង ទៀតអាស្រ័យទៅតាមប្រវត្តិនៃការប្រើឱសថ ARV ពីមុនមក | មិនត្រូវប្រើ ddI ម្ដងទៀតទេ ព្រោះអាចមាន គ្រោះថ្នាក់ធ្ងន់ធ្ងរ |

| | | | |
|---|---|---|---|
| **NVP** | - កន្ទួលស្បែកៈ មធ្យម-ធ្ងន់ធ្ងរ (eg bullae, "wet") | ត្រូវប្តូរ NVP ទៅ EFV | មិនត្រូវប្រើ NVP ម្តងទៀតទេ |
| | - កន្ទួលស្បែកៈ ធ្ងន់ធ្ងរដែលមានផលវិបាក [complicated (mucosal involvement or fever)] | ត្រូវប្តូរ NVP ទៅ PI រឺ ABC | មិនត្រូវប្រើ NVP រឺ EFV ម្តងទៀតទេ |
| | - រលាកថ្លើម | ផ្លាស់ប្តូរ NVP ទៅ EFV | មិនត្រូវប្រើ NVP ម្តងទៀតទេ |
| | - រលាកថ្លើមៈ ធ្ងន់ធ្ងរ គំរាមកំហែងដល់ជីវិត | ផ្លាស់ប្តូរ NVP ទៅ PI រឺ ABC | មិនត្រូវប្រើ NVP រឺ EFV ម្តងទៀតទេ |
| **EFV** | ឥទ្ធិពលលើប្រពន្ឋ័សសៃប្រសាទៈ ធ្ងន់ធ្ងរ | ត្រូវប្តូរ EFV ទៅ NVP | មិនត្រូវប្រើ EFV ម្តងទៀតទេ |
| | -ស្ត្រីមានផ្ទៃពោះ (ប៉ះពាល់ដល់ទារកក្នុងផ្ទៃ) | ត្រូវប្តូរ EFV ទៅ NVP | អាចប្រើ EFV ម្តងទៀតបាន ពេលដែលគ្មានផ្ទៃពោះ |
| **PI** | ផលវិបាក Metabolic complications (hyperglycaemia, hyperlipidaemia) – uncontrolled | ត្រូវប្តូរ PI ទៅ non-PI ប្រសិនបើមិនអាចគ្រប់គ្រងបាន | ជៀសវាង ការប្រើ PI ម្តងទៀត ប្រសិនបើអាចធ្វើបាន |
| **NFV** | រាគ ធ្ងន់ធ្ងរ រឺ ជាប្រចាំ | ត្រូវប្តូរ NFV ទៅ non-PI ប្រសិនបើមានលទ្ធភាព (ឬ PI/r) | ជៀសវាង ការប្រើ NFV ម្តងទៀត ប្រសិនបើ អាចធ្វើបាន |
| **IDV** | គ្រួសនៅតំរងនោម - repeated | ផ្លាស់ប្តូរ IDV ទៅ PI ផ្សេងទៀត ឬ ឱសថ ARV ផ្សេងទៀត | មិនត្រូវប្រើ IDV ម្តងទៀតទេ ប្រសិនបើអាចធ្វើបាន |

## ១៤.២. ផ្លាស់ប្តូរមុខឱសថប្រឆាំងមេរោគអេដស៍ដោយសារការព្យាបាលទទួលបរាជ័យៈ

ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទទួលបរាជ័យ គឺបណ្តាលមកពីកត្តាផ្សេងៗមានជាអាទិ៍ :

### ១៤.២.១. កត្តាគ្លីនិក (Clinical failure)

- អ្នកជំងឺអេដស៍កើតមានរោគសញ្ញាគ្លីនិកថ្មី ឬជំងឺផ្សេងៗបង្កដោយមេរោគអេដស៍ (ជំងឺឱកាសនិយម ឬជំងឺមហារីកស្បែក (malignancy) បន្ទាប់ពីព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានរយៈពេល ៣ខែមក (អង្គការសុខភាពពិភពលោកបានផ្តល់អនុសាសន៍លើការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍តាមរូបមន្តព្យាបាលជួរទី១ គប្បីមាន រយៈពេលពី ៦ ទៅ ១២ខែដើម្បីដឹងពី បរាជ័យកត្តាគ្លីនិក) (សូមមើលតារាងទី ១០ ផងដែរ) ដែលបញ្ជាក់ពីការវិវត្តទៅមុខនៃសភាពជំងឺ ។

**១៤.២.២. កត្តាប្រពន្ធ័ការពារសារពាង្គកាយ** (Immunological failure)

- ពុំមានការកើនឡើងនូវចំនួនកោសិកា CD4 ពី 20-25 cells/mm$^3$ ក្នុងកំឡុង ១២ខែ ដំបូងនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។
- ការធ្លាក់ចុះនូវចំនួនកោសិកា CD4 ដែលពិនិត្យឃើញមុនពេលចាប់ផ្តើមការព្យាបាល (pre-therapy baseline) ឬមានចំនួនកោសិកា CD4 តិចជាង មុនពេលព្យាបាលដោយមិនមានជំងឺឱកាសនិយមផ្សេងៗ ដើម្បីពន្យល់ពីការថយចុះនេះ ។
- ការថយចុះលើសពី ៥០% ធៀបនឹងចំនួន CD 4 ដែលឡើងខ្ពស់ជាងគេនៅពេលព្យាបាល ដោយគ្មានជំងឺឱកាសនិយមផ្សេងៗ បញ្ជាក់ពីការថយចុះនេះ ។

**១៤.២.៣. កត្តាវីរុសសាស្រ្ត** (Virological failure)

នៅតែមានមេរោគអេដស៍ក្នុងឈាម បញ្ជាក់ដោយការធ្វើតេស្ត viral load ។

មូលហេតុនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទទួលបរាជ័យដូចរៀបរាប់ខាងលើ តំរូវអោយមានការផ្លាស់ប្តូររូបមន្តនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ នេះជាការសំរេចចិត្តដ៏ស្មុគស្មាញមួយ ដែលចាំបាច់ត្រូវសុំយោបល់ពីអ្នកជំនាញឯកទេសដែលមានបទពិសោធន៍ក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ សូមមើលតារាងទី ៩ និង១៣ខាងក្រោម ។

**តារាងទី ៩ : ការគ្រប់គ្រងព្យាបាលចំពោះអ្នកជំងឺដែលសង្ស័យថា ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ត្រូវបរាជ័យដោយកត្តាគ្លីនិក**

| Scenario | រយៈពេលចាប់ផ្តើម | ការធ្វើរោគវិនិច្ឆ័យ | ការព្យាបាល |
|---|---|---|---|
| លេចចេញនូវជំងឺឱកាសនិយមដែលទាក់ទងនឹងជំងឺអេដស៍ថ្មីៗឬសារចុះសារឡើង | តិចជាង ៣ ខែ | • គ្មានការព្យាបាលបរាជ័យ<br>• អាចបណ្តាលមកពីៈ<br>o IRD/IRIS<br>o ការកើតឡើងជំងឺឱកាសនិយម ដោយសារតែការថយចុះចំនួន CD4 | • ត្រូវព្យាបាលជំងឺឱកាសនិយមទាក់ទងនឹងជំងឺអេដស៍<br>• ត្រូវព្យាបាលដោយឱសថ anti-inflammatory ប្រសិនបើ រោគសញ្ញា ដែលបណ្តាលមកពី ជំងឺរបេងទាក់ទងនឹង IRD/IRIS.<br>• បន្តការព្យាបាលដោយឱសថ ប្រឆាំងនឹងមេរោគអេដស៍ ដោយមិនប្តូររូបមន្តព្យាបាល |
| លេចចេញនូវជំងឺឱកាសនិយមដែលទាក់ទងនឹងជំងឺអេដស៍ថ្មីៗឬសារចុះសារឡើង | ៣-៦ខែ | • អាចបណ្តាលមកពីៈ<br>o IRD/IRIS<br>o ការកើតឡើងជំងឺឱកាសនិយម ដោយសារតែការថយចុះចំនួន CD4<br>o បរាជ័យក្នុងការព្យាបាល | • ត្រូវព្យាបាលជំងឺឱកាសនិយមទាក់ទងនឹងជំងឺអេដស៍<br>• ត្រូវព្យាបាលដោយឱសថ anti-inflammatory ប្រសិនបើ រោគសញ្ញា ដែលបណ្តាលមកពី ជំងឺរបេងទាក់ទងនឹង IRD/IRIS.<br>• បន្តការព្យាបាលដោយឱសថ ប្រឆាំងនឹងមេរោគអេដស៍ ដោយមិនប្តូររូបមន្តព្យាបាល |

| | | | |
|---|---|---|---|
| | | | • ពិនិត្យសភាពគ្លីនិក និង ចំនួនកោសិកា CD4 ក្រោយពេលព្យាបាលមួយរយៈ ។ ប្រសិនបើ CD4 កើនឡើង និង សភាពគ្លីនិកប្រសើរឡើង ដូច្នេះ អាចមិនមែនបណ្តាលមកពីការព្យាបាលបរាជ័យទេ ។ |
| ការចាត់តាមអង្គការសុខភាពពិភព លោក ដំណាក់កាល ទី២ | លើសពី ៦ ខែ | • អាចបណ្តាលមកពី:<br>o ជំងឺស្រាលៗមួយចំនួន<br>o IRD/IRIS ជួបប្រទះដោយកំរ ក្រោយការព្យាបាលបាន ៦ ខែ<br>o ការព្យាបាលបរាជ័យ ជាពិសេសមកពី PPE | • ត្រូវព្យាបាលជំងឺឱកាសនិយមទាក់ទងនឹងជំងឺអេដស៍<br>• ពិនិត្យសភាពគ្លីនិក និង ចំនួនកោសិកា CD4 ក្រោយពេលព្យាបាលមួយរយៈ ។ ប្រសិនបើ CD4 កើនឡើង និង សភាពគ្លីនិកប្រសើរឡើង ដូច្នេះ អាចមិនមែនបណ្តាលមកពី ការព្យាបាលបរាជ័យទេ ។ |
| ការចាត់ថ្នាក់តាមអង្គការសុខភាពពិភពលោក ដំណាក់កាលទី៣/៤ លើកលែងតែជំងឺរបេង | លើសពី ៦ ខែ | • បញ្ហានេះអាចកើតឡើងនៅពេលព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជោគជ័យ ទោះបីចំនួនកោសិកា CD4 នៅទាបក៏ដោយ<br>• អាចបណ្តាលមកពី:<br>o ប្រព័ន្ធភាពស៊ាំនៅតែចុះខ្សោយ<br>o ការព្យាបាលបរាជ័យ IRD/IRIS ជួបប្រទះដោយកំរ ក្រោយការព្យាបាលបាន ៦ ខែ | • ត្រូវព្យាបាលជំងឺឱកាសនិយមទាក់ទងនឹងជំងឺអេដស៍<br>• ពិនិត្យសភាពគ្លីនិក, ចំនួនកោសិកា CD4, និង តេស្ត Viral Load ក្រោយពីការព្យាបាលមួយរយៈ ។ |
| ជំងឺរបេង នៅគ្រប់ ទំរង់ | លើសពី ៦ ខែ | • ជំងឺរបេងអាចកើតមានដោយមិនទាក់ទងនឹងចំនួនកោសិកា CD4 និង មុខងាររបស់ភាពស៊ាំការពារសារពាង្គកាយទេ អាចបណ្តាលមកពី:<br>o ការប្រឈមមុខនឹងការ | • ត្រូវព្យាបាលជំងឺឱកាសនិយមទងនឹងជំងឺអេដស៍<br>• ត្រូវព្យាបាលដោយឱសថ anti-inflammatory ប្រសិនបើ រោគសញ្ញា ដែលបណ្តាលមកពី ជំងឺរបេង ទាក់ទងនឹង IRD/IRIS.<br>• ពិនិត្យសភាពគ្លីនិក, ចំនួនកោសិកា CD4 តេស្ត Viral Load ក្រោយពីការព្យាបាលមួយរយៈ |

| | | | |
|---|---|---|---|
| | | ឆ្លងមេរោគរបេងខ្ពស់ នៅប្រទេសកម្ពុជា<br>o IRD/IRIS ជួបប្រទះ ដោយកំរ ក្រោយការ ព្យាបាលបាន ៦ ខែ<br>o ការព្យាបាលបរាជ័យ | |

**តារាងទី ១០ : ការគ្រប់គ្រងព្យាបាលចំពោះអ្នកជំងឺដែលសង្ស័យថា ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ត្រូវបរាជ័យ ដោយកត្តាប្រព័ន្ធការពារសារពាង្គកាយ**

| Scenario | **រយៈពេលនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍** | **ការធ្វើរោគវិនិច្ឆ័យ** | **សកម្មភាព** |
|---|---|---|---|
| កំណើន កោសិកា CD4 តិចជាង ២៥-៥០ cells/mm$^3$ នៅក្នុងរយៈពេល ១២ ខែតំបូង នៃការព្យាបាល ដោយឱសថប្រឆាំង មេរោគអេដស៍ | ១២ ខែ | • អាចបណ្តាលមកពីៈ<br>o ការព្យាបាលបរាជ័យ<br>o ការឆ្លើយតបធម្មតានៅ លើមនុស្សចាស់<br>o កំហុសរបស់បច្ចេកទេស មន្ទីរពិសោធន៍ | • ពិនិត្យសភាពគ្លីនិក, ចំនួនកោសិកា CD4<br>• ប្រសិនបើការឆ្លើយតបគ្លិនិកទៅនឹង ការព្យាបាលដោយឱសថប្រឆាំង មេរោគអេដស៍ តិចតួច ត្រូវធ្វើតេស្ត Viral Load |
| ការថយចុះ កោសិកា CD4 តិចជាងចំនួន កោសិកា CD4 មុនពេលព្យាបាល | លើសពី ៦ ខែ | • អាចបណ្តាលមកពីៈ<br>o ការព្យាបាលបរាជ័យ<br>o មានជំងឺកើតឡើងសារចុះសារឡើង<br>o កំហុសបច្ចេកទេស មន្ទីរពិសោធន៍ | • ពិនិត្យ ចំនួនកោសិកា CD4 ប្រសិនបើ បានធ្វើតេស្ត CD4 នៅពេលពិនិត្យជំងឺលើកមុន<br>• ក្រោយបានធ្វើតេស្តបញ្ជាក់ពី ចំនួន CD4 ត្រូវធ្វើតេស្ត Viral Load |
| ការថយចុះ កោសិកា CD4 ៥០% ធៀបនឹង | លើសពី ៦ ខែ | • អាចបណ្តាលមកពីៈ<br>o ការព្យាបាលបរាជ័យ<br>o មានជំងឺកើតឡើងសារចុះសារឡើង | • ពិនិត្យ ចំនួនកោសិកា CD4 ប្រសិនបើ បានធ្វើតេស្ត CD4 នៅពេលពិនិត្យជំងឺលើកមុន |

| | | | |
|---|---|---|---|
| ចំនួន កោសិកា CD4 ដែលបាន ឡើងខ្ពស់ដល់ កំពូល | | o កំហុសបច្ចេកទេស មន្ទីរពិសោធន៍ | • ក្រោយបានធ្វើតេស្តបញ្ជាក់ពី ចំនួន CD4 ត្រូវធ្វើតេស្ត Viral Load |
| ការថយចុះចំនួន CD4 | លើសពី ៦ ខែ | • អាចបណ្តាលមកពីៈ<br>o ការឆ្លើយតបធម្មតានៅ លើមនុស្សចាស់<br>o ការព្យាបាលបរាជ័យ<br>o កំហុសបច្ចេកទេស មន្ទីរពិសោធន៍ | • ពិនិត្យ ចំនួនកោសិកា CD4 ប្រសិនបើ បានធ្វើតេស្ត CD4 នៅពេលពិនិត្យជំងឺលើកមុន<br>• ក្រោយបានធ្វើតេស្តបញ្ជាក់ពី ចំនួន CD4 ត្រូវធ្វើតេស្ត Viral Load |

**តារាងទី ១១ : លក្ខខ័ណ្ឌក្នុងការសុំធ្វើតេស្ត Viral Load**

| មនុស្សពេញវ័យ |
|---|
| •មានកើតសារចុះសារឡើង នៃការចាត់ថ្នាក់របស់អង្គការសុខភាពពិភពលោក នៅដំណាក់កាលទី ៣ ឬ ទី ៤ រួមមានជំងឺ របេងនៅគ្រប់ទំរង់ ក្រោយពី ការព្យាបាលដោយឱសថប្រឆាំង មេរោគអេដស៍ រយៈពេល ៦ ខែ<br><br>• កំណើន កោសិកា CD4 តិចជាង ២៥-៥0 Cells/mm³ នៅក្នុងរយៈពេល ១២ ខែតំបូង នៃការព្យាបាលដោយឱសថ ប្រឆាំងមេរោគអេដស៍ ( សូមមើល ឧបសម្ព័ន្ធទី ៥, រូបភាពទី ១)<br>• ការថយចុះ កោសិកា CD4 តិចជាងចំនួន កោសិកា CD4 មុនពេលព្យាបាល ដោយគ្មានមូលហេតុ<br>•ការថយចុះ កោសិកា CD4 ៥0% ធៀបនឹង ចំនួន កោសិកា CD4 ដែលបាន ឡើងខ្ពស់ដល់កំពូល ដោយគ្មានមូលហេតុ<br>• ត្រូវស្នើសុំធ្វើតេស្ត viral load គ្រប់ករណីដែលបណ្តាលឱ្យ ថយចុះចំនួន CD4 |

**តារាងទី ១២ : ការគ្រប់គ្រងព្យាបាលចំពោះអ្នកជំងឺដែលសង្ស័យថា ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ត្រូវបរាជ័យ ដោយកត្តាវីរុសសាស្ត្រ (Virological failure)**

| | | | |
|---|---|---|---|
| តេស្ត viral load នៅតែរកឃើញមេរោគអេដស៍ | តិចជាង ៤ ខែ | • គ្មានការព្យាបាលបរាជ័យ<br>• ការថយចុះ viral load នៅក្រោមក៏វិតដែលអាច មើលឃើញ អាចកើតមានឡើងនៅ ៤ ខែ ក្រោយពេលចាប់ផ្តើមការព្យាបាល | • បន្តការព្យាបាលឱសថប្រឆាំងមេរោគអេដស៍ ដោយមិនផ្លាស់ប្តូរមុខឱសថប្រឆាំងមេរោគអេដស៍ |
| តេស្ត viral load នៅតែរកឃើញមេរោគអេដស៍ | លើសពី ៤ ខែ | • អាចបណ្តាលមកពីៈ<br>o ការបរាជ័យដោយកត្តាវិរុសសាស្ត្រ<br>o If < 500 c/ml then may be a 'blip'.* | • ពិនិត្យសភាពគ្លីនិក, និង ចំនួនកោសិកា CD4<br>• បរាជ័យក្នុងការព្យាបាលកើតមានឡើង នៅពេលដែលមានបរាជ័យទាំងគ្លីនិក និង ប្រព័ន្ធការពារសារពាង្គកាយ<br>• បរាជ័យវីរុសសាស្ត្រ កើតមានឡើង នៅពេលដែលសភាពគ្លីនិកបានប្រសើរឡើង និង ការកើនឡើងចំនួនកោសិកា CD 4 |

*A HIV viral load 'blip' is a single 'detectable' result below 500 c/ml followed by an 'undetectable' result. It is due to normal biological and statistical variation and has no clinical significance.

**តារាងទី ១៣ : ការគ្រប់គ្រងព្យាបាលអ្នកជំងឺអេដស៍ដែលបញ្ជាក់ ថាការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ទទួលបរាជ័យ**

| ជំហានដែលត្រូវធ្វើ | សកម្មភាព |
|---|---|
| **ជំហានទី ១** | • ធ្វើការសំរេចចិត្តប្រសិនបើច្បាស់ថា ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទទួល បរាជ័យ |
| ជំហានទី ២ | • ធ្វើការសំរេចចិត្តអំពីអ្វីដែលទំនងជាមូលហេតុនៃការព្យាបាលទទួលបរាជ័យ :<br>o ធ្វើការវាយតំលៃអំពីការលេបឱសថ ARV ដោយត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ :<br>• ពិភាក្សាអំពី ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដោយត្រឹមត្រូវ ទៀងទាត់ និង ជាប់លាប់ ដោយមិនធ្វើការរំខាន<br>• សាកសួរអំពី ការផ្តល់ប្រឹក្សា និង មិត្តគាំទ្រមិត្ត<br>• វាយតំលៃព័ត៌មានបន្ថែម ការចូលមកពិនិត្យគ្លីនិក ការឆ្លើយតបទៅនឹងសំនួរទាក់ទងនឹងការលេបឱសថត្រឹមត្រូវ ទៀងទាត់ និង ជាប់លាប់ ការរាប់ចំនួនចំនួនគ្រាប់ឱសថ<br>o ធ្លាប់ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍<br>o ក៏វិតដូសឱសថប្រឆាំងមេរោគអេដស៍ ជាពិសេសចំពោះកុមារ |

| | |
|---|---|
| | o អន្តរកម្មឱសថ<br>o ការស្រូបឱសថ (ឧ: រាគរុំារ៉ៃ)<br>o ដាច់ស្តុកឱសថប្រឆាំងមេរោគអេដស៍ |
| ជំហានទី ៣ | • ឆ្លើយតបទៅនឹងមូលហេតុ នៃការព្យាបាលបរាជ័យ:<br>o ជួយគាំទ្រស្វែងរកដំណោះស្រាយរាល់ការលំបាក ពាក់ព័ន្ធនឹងការលេបឱសថឱ្យបានត្រឹមត្រូវ ទៀងទាត់ និង ជាប់លាប់ ឧ. ការគាំទ្រពី ក្រុមថែទាំអ្នកជំងឺអេដស៍ តាមផ្ទះ ប្រព័ន្ធរំលឹកការលេបឱសថ<br>o ផ្លាស់ប្តូរឱសថ/ កំរិតដូស ដោយចៀសវាង ការប្រើដូសមិនគ្រប់ ឬ មានអន្តរកម្មឱសថ |
| ជំហានទី ៤ | • ធ្វើការសំរេចចិត្ត អំពី ការផ្លាស់ប្តូររូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដោយពិគ្រោះយោបល់នឹងគ្រូពេទ្យជំនាញ |

## ១៥ ~ ការផ្លាស់ប្តូរការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីរូបមន្តព្យាបាលជួរទី ១ ទៅរូបមន្តព្យាបាលជួរទី ២ វិញ

ការផ្លាស់ប្តូរការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទៅរូបមន្តព្យាបាលជួរទី ២ គឺជាការសំរេចចិត្តមួយដ៏សំខាន់ និងមានភាពស្មុគស្មាញដែលត្រូវធ្វើការពិគ្រោះយោបល់ជាមួយគ្រូពេទ្យជំនាញ ដែលមានបទពិសោធន៍ក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ ដូចនេះការសំរេចចិត្តដើម្បីផ្លាស់ប្តូររូបមន្តព្យាបាល មិនត្រូវពឹងផ្អែកលើលទ្ធផលរបស់តេស្តអមវេជ្ជសាស្ត្រ ឬ រោគសញ្ញាគ្លីនិកប៉ុណ្ណោះទេ ប៉ុន្តែត្រូវពឹងផ្អែកលើរាល់ព័ត៌មានទាំងអស់រួមមាន ប្រវត្តិព្យាបាលជំងឺ, ការលេបឱសថប្រឆាំងមេរោគអេដស៍ត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់, សភាពគ្លីនិក, ចំនួនកោសិកា CD4 និង ចំនួនមេរោគអេដស៍ក្នុងឈាម (Viral Load testing) ។

នៅបណ្តាប្រទេសអភិវឌ្ឍន៍ ការធ្វើតេស្តរកចំនួនមេរោគអេដស៍ក្នុងឈាម គឺជាមធ្យោបាយដ៏ល្អ និងសាមញ្ញបំផុតដើម្បីសំរេចអំពីការផ្លាស់ប្តូររូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីជួរទី១ ទៅជួរទី២ ។ មធ្យោបាយនេះក៏ជាជំរើសមួយដែរសំរាប់ប្រទេសកម្ពុជាក្នុងការអនុវត្តន៍ការផ្លាស់ប្តូររូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីរូបមន្តជួរទី១ ទៅជួរទី២ ។ដើម្បីធានាគុណភាពនៃការព្យាបាលតាមរូបមន្តជួរទី២ និងអោយបានទាន់ពេលវេលាផងនោះ គ្រូពេទ្យព្យាបាល OI និង ART ត្រូវសុំធ្វើតេស្ត viral load ដោយផ្ញើគំរូឈាមមកមន្ទីរពិសោធន៍នៃវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ ឬមន្ទីរពិសោធន៍នៃមហាវិទ្យាល័យឱសថសាស្ត្រ ។ ចំពោះមន្ទីរពេទ្យបង្អែកថ្នាក់ខេត្ត/ក្រុង ស្រុកប្រតិបត្តិ ប្រសិនបើមានការស្មុគស្មាញក្នុងការសំរេចចិត្តដើម្បីផ្លាស់ប្តូររូបមន្តព្យាបាលទៅជួរទី២ សូមបញ្ជូនអ្នកជំងឺមកគ្លីនិកសុខភាពសង្គមរបស់មជ្ឈមណ្ឌលជាតិ ។

ទិន្នន័យជាច្រើនបង្ហាញថា សភាពគ្លីនិក និង Immunological អាចរក្សានូវកំរិតមេរោគអេដស៍ក្នុងឈាម (viral load) ទាបជាង 10,000 copies/mL ទោះបីជាមានភាពស៊ាំនឹងឱសថប្រឆាំងមេរោគអេដស៍ក៏ដោយ ។

**តារាងទី ១៤: រូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី ២ នៅប្រទេសកម្ពុជា**

| ស្ថានភាព | រូបមន្តព្យាបាល |
|---|---|
| រូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី ២ | TDF+3TC + LPV/RTV (Kaletra)<br>ឬ<br>DDI+3TC + LPV/RTV (Kaletra) |

## ឯកសារយោង

ក្រុមការងារបច្ចេកទេសដែលបានចូលរួមក្នុងការពិនិត្យមើលឡើងវិញនូវគោលការណ៍ណែនាំជាតិអំពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍លើមនុស្សពេញវ័យ បានប្រើប្រាស់នូវឯកសារមួយចំនួនដូចខាងក្រោមនេះ :


១. British HIV Association (BHIVA) guidelines for the treatment of HIV-infected adults with antiretroviral therapy. HIV Med 2001; 2:276-313.

២. Recommendations for antiretroviral therapy in HIV infected adults and adolescents - 2002/2003: Brazilian Ministry of Health, 2002.

៣. Fact sheets on antiretroviral drugs: SEARO, 2002.

៤. The use of antiretroviral therapy: a simplified approach for resource-constrained countries: SEARO, 2002.

៥. ARV protocol: Sihanouk Hospital Center of Hope, 2002

៦. Scaling up antiretroviral therapy in resource-limited settings: guidelines for a public health approach: World Health Organisation, 2002.

៧. Guidelines for antiretroviral therapy in Zimbabwe: National Drug and Therapeutics Policy Advisory Committee, 2003.

៨. Yeni P, Hammer S, Carpenter C, et al. Antiretroviral treatment for adult HIV infection in 2002: updated recommendations of the International AIDS Society - USA Panel. JAMA 2002; 288:222-235.

៩. Antiretroviral Therapy for HIV Infection in adults and Adolescents in Resource-Limited-Settings: Towards Universal Access. Recommendations for a public health approach. 2006 version. Wiorld Health Organization

## ឧបសម្ព័ន្ធទី១ : ការចាត់ថ្នាក់អ្នកជំងឺអេដស៍លើមនុស្សពេញវ័យទៅតាមអនុសាសន៍នៃអង្គការសុខភាពពិភពលោកឆ្នាំ ២០០៦

| CLINICAL STAGE 1 |
|---|
| Asymptomatic<br>Persistent generalized lymphadenopathy |
| **CLINICAL STAGE 2** |
| Unexplained moderate weight loss (<10% of presumed or measured body weight)[i]<br>Recurrent respiratory tract infections (sinusitis, tonsillitis, otitis media and pharyngitis)<br>Herpes zoster<br>Angular cheilitis<br>Recurrent oral ulceration<br>Papular pruritic eruptions<br>Seborrhoeic dermatitis<br>Fungal nail infections |
| **CLINICAL STAGE 3** |
| Unexplained[i] severe weight loss (>10% of presumed or measured body weight)<br>Unexplained chronic diarrhoea for longer than one month<br>Unexplained persistent fever (above 37.5°C intermittent or constant, for longer than one month)<br>Persistent oral candidiasis<br>Oral hairy leukoplakia<br>Pulmonary tuberculosis<br>Severe bacterial infections (such as pneumonia, empyema, pyomyositis, bone or joint infection, meningitis or bacteraemia)<br>Acute necrotizing ulcerative stomatitis, gingivitis or periodontitis<br>Unexplained anaemia (<8 g/dl), neutropaenia (<0.5 × $10^9$ per litre) and/or chronic thrombocytopaenia (<50 × $10^9$ per litre) |

i Assessment of body weight in pregnant woman needs to consider the expected weight gain of pregnancy.

| CLINICAL STAGE 4[ii] |
| --- |
| HIV wasting syndrome<br>Pneumocystis pneumonia<br>Recurrent severe bacterial pneumonia<br>Chronic herpes simplex infection (orolabial, genital or anorectal of more than one month's duration or visceral at any site)<br>Oesophageal candidiasis (or candidiasis of trachea, bronchi or lungs)<br>Extrapulmonary tuberculosis<br>Kaposi's sarcoma<br>Cytomegalovirus infection (retinitis or infection of other organs)<br>Central nervous system toxoplasmosis<br>HIV encephalopathy<br>Extrapulmonary cryptococcosis including meningitis<br>Disseminated non-tuberculous mycobacterial infection<br>Progressive multifocal leukoencephalopathy<br>Chronic cryptosporidiosis<br>Chronic isosporiasis<br>Disseminated mycosis (extrapulmonary histoplasmosis or coccidiomycosis)<br>Recurrent septicaemia (including non-typhoidal *Salmonella*)<br>Lymphoma (cerebral or B-cell non-Hodgkin)<br>Invasive cervical carcinoma<br>Atypical disseminated leishmaniasis<br>Symptomatic HIV-associated nephropathy or symptomatic HIV-associated cardiomyopathy |

i Unexplained refers to where the condition is not explained by other causes.

ii Some additional specific conditions can also be included in regional classifications (such as reactivation of American trypanosomiasis [meningoencephalitis and/or myocarditis]) in the WHO Region of the Americas and penicilliosis in Asia).

**ឧបសម្ព័ន្ធទី២ : មុខឱសថប្រឆាំងមេរោគអេដស៍ និងផលប៉ះពាល់របស់វា**

- ត្រូវស្វែងយល់ដឹងពី ឱសថប្រឆាំងមេរោគអេដស៍និមួយៗ ជាពិសេស អំពី ផលប៉ះពាល់វា និង ការគ្រប់គ្រងផលប៉ះពាល់ទាំងនោះ
- សូមពិនិត្យមើលតារាងទាំងពីរ : តារាងទី ១៥ ដែលបានសង្ខេបពី រូបសណ្ឋានឱសថនិមួយៗ និង តារាងទី ១៦ ដែលបានសង្ខេបពី ផលប៉ះពាល់របស់ឱសថប្រឆាំងមេរោគអេដស៍និមួយៗ ។ ឱសថប្រឆាំងមេរោគអេដស៍ ដែលមាននៅក្នុងតារាង និង មានរៀបរាប់ពិភាក្សាពីផលប៉ះពាល់របស់វា ផងដែរ ។
- ចូលអានផងដែរ អំពី គោលការណ៍នៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍-ការធ្វើរោគវិនិច្ឆ័យ និង ការគ្រប់គ្រងផលប៉ះពាល់ ។ តារាងទី៦ រៀបរាប់អំពី ការគ្រប់គ្រងលើក្រុមពិសេស និង ការផ្លាស់ប្តូរមុខឱសថប្រឆាំងមេរោគអេដស៍ ។

**តារាងទី ១៥ : កំរិតប្រើឱសថប្រឆាំងមេរោគអេដស៍-រូបមន្តព្យាបាល-ល័ក្ខខ័ណ្ឌ និង ការប្រើលើក្រុម អ្នកជំងឺមួយចំនួន**

| ឱសថ និង ចំណាត់ថ្នាក់ | កំរិតដូស | ប្រភេទឱសថ | តំរូវអោយមានការរក្សាទុកនៅទីកន្លែងត្រជាក់សំរាប់រយៈពេលយូរអង្វែង | ការជះឥទ្ធិពលរបស់ចំណីអាហារ | ការប៉ះពាល់ដល់តំរងនោមនិងថ្លើម | ស្ត្រីមានផ្ទៃពោះ (មើល ទំព័រ៣៤) | ការឆ្លងមេរោគព្រមគ្នារបេង និងអេដស៍ (មើល ទំព័រ ៣៥) |
|---|---|---|---|---|---|---|---|
| **NRTIs** | | | | | | | |
| Zidovudine (ZDV or AZT) | ៣00mg (១គ្រាប់) លេប ១ ថ្ងៃ ២ ដង | -ប្រភេទគ្រាប់ : (១00mg, ២៥0mg, ៣00mg) -ប្រភេទថ្នាំចាក់ : ១0mg/ml (១ដបមាន ២0ml) -ប្រភេទទឹក : ១0mg/ml | មិនបាច់ទេ | គ្មាន | ទេ | និយមប្រើ | និយមប្រើ |
| Stavudine (d4T) | -៣0mg (១គ្រាប់) លេប ១ថ្ងៃ ២ ដង | -ប្រភេទគ្រាប់ ១៥ mg, ២0 mg, ៣0mg, -ប្រភេទទឹក : ១ mg/ml | ចំពោះតែប្រភេទដំណក់ដែលលាយទឹកផឹកតែប៉ុណ្ណោះ | គ្មាន | CrCl 10-50ml/min: halve each dose | ប្រើបាន (តែមិនត្រូវរួមផ្សំ ជាមួយ ddI ទេ) | អាចទទួលយកបាន តែបង្កើនគ្រោះថ្នាក់នៃជំងឺសសៃប្រសាទ (neuropathy) |
| Lamivudine (3TC) | ១៥0mg (១គ្រាប់) មួយថ្ងៃ ២ ដង | -ប្រភេទគ្រាប់ : ១៥0mg, -ប្រភេទទឹក : ១0mg/ml | ទេ | គ្មាន | CrCl 10-50ml/min: 150mg ក្នុងមួយថ្ងៃ | និយមប្រើ | និយមប្រើ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| Didanosine (ddI) | -ទំងន់លើសពី ៦០ kg: ៤00mg (one EC capsule) លេប១គ្រាប់/ថ្ងៃ -ទំងន់តិចជាង ៦០ kg: ១២៥mg (២គ្រាប់) ឬ ឬ ២៥0mg (one EC capsule) លេប ១គ្រាប់/១ថ្ងៃ | -ប្រភេទគ្រាប់ : ២៥ mg, ៥0mg ១00mg ១៥0mg ២00mg -ប្រភេទទឹក : : ១0 mg/ml, -ប្រភេទ capsule : ១២៥mg, ២00mg, ២៥0mg, ៤00mg | ទេ | លេប ៣0 នាទី មុនបាយ ឬ ២ ម៉ោងក្រោយបាយ | CrCl 10-50ml/min: កំរិតឱសថធម្មតា ប៉ុន្តែ លេបបាន តែ ១ដង/១ថ្ងៃ | ប្រើបាន( ប៉ុន្តែ មិនត្រូវប្រើរួម ជាមួយ d4T | ប្រើបាន តែបង្កើន គ្រោះថ្នាក់នៃជំងឺ សសៃប្រសាទ (neuropathy) |
| Abacavir (ABC) | ៣00mg (១គ្រាប់) លេប ១ថ្ងៃ ២ ដង | -ប្រភេទគ្រាប់ : ៣00 mg, -ប្រភេទទឹក : ២0mg/ml | ទេ | គ្មាន | ទេ | ទេ | ប្រើបាន ប៉ុន្តែ ប្រហែលជា ពិបាក វិនិច្ឆ័យ ទៅលើ hypersensitivity របស់ ABC |
| **NtRT** | | | | | | | |
| Tenofovir (TFV or TDF) | ៣00mg (១គ្រាប់) លេប ១ថ្ងៃ ១ ដង | -ប្រភេទគ្រាប់ : ៣00mg | ទេ | លេបពេលបាយ | មិនត្រូវប្រើលើ អ្នកជំងឺខូចតំរងនោម (CrCl <50ml/min) | ទេ | ទេ |
| **NNRTI** | | | | | | | |
| Nevirapine (NVP) | ២00mg (១គ្រាប់) លេបមួយថ្ងៃម្តង រយៈ | -ប្រភេទគ្រាប់ ២00mg , -ប្រភេទម្សៅ : 10mg/ml | ទេ | គ្មាន | តំរងនោម : ទេ ថ្លើម: ចៀសវាង | និយមប្រើ | ចៀសវាង ប្រសិន បើមិនអាចដឹងពីកំរិត |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ពេល ២សប្តាហ៍ បន្ទាប់ មក ២00mg(១គ្រាប់) មួយថ្ងៃ ២ ដង ។ | | | | | | ជាតិពុល និង កំរិតដូស |
| Efavirenz (EFV) | ៦00mg (១គ្រាប់) លេបមួយថ្ងៃម្តង | -ប្រភេទគ្រាប់ : ៥0mg, ១00mg, ២00mg, ៦00 mg,<br>-ប្រភេទទឹកស៊ីរ៉ូ : ៣0 mg/ml | ទេ | ចៀសវាងអាហារ ដែលមានជាតិ ខ្លាញ់ច្រើន | តំរងនោម : ទេ ថ្លើម: ចៀសវាង | ទេ | និយមប្រើ |
| **PIs** | | | | | | | |
| Nelfinavir (NFV) | លេបម្តង ៥គ្រាប់ = ១២៥0 mg (១គ្រាប់/២៥0mg) ២ដង ក្នុងមួយថ្ងៃ | -ប្រភេទគ្រាប់ : ២៥0mg, ប្រភេទម្សៅ : ៥0mg/g | ទេ | លេបពេលបាយ ឬ យ៉ាងហោច ណាស់ពេលបរិភោគ ចំណី បន្តិចបន្តួច | គ្មានព័តិមាន | និយមប្រើ | ទេ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| Indinavir + Ritonivir (IDV/r) | ១គ្រាប់/៤00mg/១00 mg លេបម្តង ២ គ្រាប់ ២ដង ក្នុងមួយថ្ងៃ | -ប្រភេទគ្រាប់ : IDV ១ គ្រាប់ ១00mg, ២00mg, ៣៣៣mg, ៤00 mg<br>-ប្រភេទ RTV : ១គ្រាប់ ១00 mg;<br>-ប្រភេទទឹក : 80 mg/ml | មានតែ RTV គ្រាប់ទេ ដែលអាច ទុកបាន ៣0 ថ្ងៃ នៅបន្ទប់សីតុណ្ហភាព ធម្មតា | គ្មាន | តំរងនោម: ចៀសវាង<br>ថ្លើម: ចៀសវាង | ប្រើបាន | ទេ |
| Lopinavir + Ritonavir | ១គ្រាប់/៤00mg/១00 | -ប្រភេទគ្រាប់សំប៉ែត : | អាចទុកបាន ២ខែ | លេបពេល | តំរងនោម: | ទេ | ទេ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| (LPV/r) | mg (3 capsules) លេប ២ដង ក្នុងមួយថ្ងៃ (គ្រាប់ថ្នាំបញ្ចូលគ្នា) | ២០០mg + ៥០mg<br>-ប្រភេទគ្រាប់ :<br>១៣៣.៣mg +៣៣.៣mg,<br>-ប្រភេទទឹក : 80 mg/ml+ 20mg/ml | នៅបន្ទប់សីតុណ្ហភាពធម្មតា | បាយ | គ្មានទិន្នន័យ<br>ថ្លើម: ចៀសវាង | | |
| Saquinavir + Ritonavir (SQV/r) | ១០០០mg/១០០mg (៦ គ្រាប់ ) ២ដងក្នុង១ថ្ងៃ | - ប្រភេទគ្រាប់ : SQV ១ គ្រាប់ ២០០ mg, RTV ១គ្រាប់ ១០០ mg;<br>-ប្រភេទទឹក: 80 mg/ml | មានតែ SQV, SGC (ទុកបាន ៣ខែ) និងគ្រាប់ RTV គ្រាប់ ( ទុកបាន ៣០ ថ្ងៃ) នៅបន្ទប់សីតុណ្ហភាពធម្មតា | គ្មាន | តំរងនោម:<br>គ្មានទិន្នន័យ<br>ថ្លើម: ចៀសវាង | បាទ | បាទ |

| **ការប្រើរួមគ្នា** | | | | | | | |
|---|---|---|---|---|---|---|---|
| Zidovudine + Lamivudine (AZT + 3TC) | ៣០០mg/១៥០mg (១គ្រាប់) មួយថ្ងៃ ២ ដង | | ទេ | គ្មាន | ប្រើរូបមន្ត ដោយឡែកចំពោះឱសថនិមួយៗ ប្រសិនបើ CrCl <50ml/min | និយមប្រើ | និយមប្រើ |
| Stavudine + Lamivudine (d4T + 3TC) | ៣០mg/១៥០mg) លេប ២ ដង ក្នុង១ថ្ងៃ | | ទេ | គ្មាន | ប្រើរូបមន្តដោយឡែក ចំពោះឱសថ ARV និមួយៗ ប្រសិន បើ CrCl <50ml/min | បាទ | អាចប្រើបានតែបង្កើនគ្រោះថ្នាក់ដល់ជំងឺសសៃប្រសាទ (neuropathy) |
| Stavudine + | បន្ទាប់លេបបាន ២សប្តាហ៍ | | ទេ | គ្មាន | តំរងនោម: ប្រើ | បាទ | ចៀសវាង ដោយមាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| Lamivudine + Nevirapine (d4T + 3TC + NVP) | ៣0mg/ ១៥0 mg/ ២00 mg (១គ្រាប់) ២ ដង ក្នុង ១ថ្ងៃ | | | | រូបមន្តដោយឡែកចំពោះមុខឱសថនិមួយៗ ប្រសិនបើ CrCl <50ml/min ថ្លើម: ចៀសវាង | | ជាតិពុល ត្រួតគ្នា បង្កើនជាតិពុល និង មានគ្រោះថ្នាក់ ជំងឺសសៃប្រសាទ (neuropathy) និង កំរិតដូសឱសថ មិនច្បាស់លាស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| Zidovudine + Lamivudine + Nevirapine (AZT + 3TC+NVP) | បន្ទាប់ពីលេបបាន ២ សប្តាហ៍ ៣00mg/១៥0 mg/២00mg (១គ្រាប់) ២ ដង ក្នុង ១ ថ្ងៃ | | ទេ | គ្មាន | តំរងនោម: ប្រើ រូបមន្តដោយឡែក ចំពោះមុខឱសថ និមួយៗ ប្រសិនបើ CrCl <50ml/min ថ្លើម: ចៀសវាង | និយមប្រើ | ចៀសវាង បើអាច ដោយមានជាតិពុល ត្រួតគ្នា និង កំរិតដូស ឱសថមិនច្បាស់ លាស់ |
| Zidovudine + Lamivudine + Abacavir (AZT + 3TC+ABC) | ៣00mg/១៥0 mg/៣00 mg (១គ្រាប់) លេប២ដង ក្នុង១ ថ្ងៃ | | ទេ | គ្មាន | ប្រើរូបមន្ត ដោយ ឡែកចំពោះមុខ ឱសថនិមួយៗ ប្រសិនបើ CrCl <50ml/min | ទេ | ប្រើបាន ប៉ុន្តែ ប្រហែលជាពិបាកធ្វើ រោគវិនិច្ឆ័យ ទៅលើ hypersensitivity របស់ ABC |

**តារាងទី ១៦ : ការគ្រប់គ្រងព្យាបាលផលប៉ះពាល់ចំបងៗរបស់ឱសថប្រឆាំងមេរោគអេដស៍**

| ផលប៉ះពាល់ | មូលហេតុចំបងដែលបណ្តាលមកពីឱសថប្រឆាំងមេរោគអេដស៍ | ការបង្ហាញចេញជារោគសញ្ញា | ការបង្ការ | ការគ្រប់គ្រងព្យាបាល |
|---|---|---|---|---|
| ឈឺពោះ | រលាកថ្លើម: d4T, NVP, EFV,RTV<br>រលាកលំពែង: ddI, d4T | ឈឺពោះ | ពិនិត្យ ALT និង hepatitis serology មុនពេល ចាប់ផ្តើមប្រើ ។ ចៀសវាង ប្រសិនបើ រលាកថ្លើម ឬ រលាកលំពែង | ពិនិត្យ Amylase and ALT. ពិនិត្យអេកូពោះ ។ សូមអានពី រលាកថ្លើម ឬ លំពែង ឬ lactic acidosis |
| ស្លេកស្លាំង | AZT | ខ្សោយ ភាពស្លឹក វិលមុខ | ពិនិត្យគ្រាប់ឈាម (CBC) មុនពេល ចាប់ផ្តើមប្រើ ។ ចៀសវាងប្រើ AZT ប្រសិនបើ Hb<100g/l | Hb<80g/l: ពិនិត្យ Hb ម្តងទៀតក្នុង ២-៤ សប្តាហ៍ ក្រោយ បើ Hb<80g/l: ឈប់ AZT |
| ប្រព័ន្ធសរសៃប្រសាទកណ្តាល | EFV | រោគសញ្ញាលើប្រព័ន្ធសរសៃប្រសាទកណ្តាល | ប្រើប្រាស់ ARV ផ្សេងទៀត ប្រសិន បើមានជំងឺខួរក្បាល ឬ ប្រើសារជាតិគ្រោះថ្នាក់ | មានសញ្ញាតិចតួច បន្តប្រើ EFV តាម ដាន ប្រើ EFV ពេលយប់ ។ បើមាន សញ្ញា ធ្ងន់ធ្ងរ ឈប់ប្រើ EFV |
| រាគរូស | ddI, NFV, RTV | រាគ | គ្មាន | ពិនិត្យរកមូលហេតុផ្សេងៗ ព្យាបាលតាមរោគសញ្ញា ។ ឈប់ប្រើ ប្រសិនបើធ្ងន់ធ្ងរ |
| ឈឺក្បាល | AZT, EFV | ឈឺក្បាល | គ្មាន | ពិនិត្យរកមូលហេតុផ្សេងៗ ។ ឈប់ប្រើប្រសិនបើធ្ងន់ធ្ងរ |

| | | | | |
|---|---|---|---|---|
| រលាកថ្លើម | d4T, NVP, EFV, RTV | ភាពស្លឹក ចង្អោរ ក្អួត ឈឺពោះ ចេញលឿង | ពិនិត្យ ALT (± មេរោគរលាកថ្លើម) មុនពេលចាប់ផ្តើមប្រើ ។ ចៀសវាង ប្រសិនបើ បណ្តាលអោយរលាកថ្លើម ។ | ALT/AST<5xULN ពិនិត្យ ALT/AST ម្តង ទៀតក្នុង ២-៤សប្តាហ៍ ក្រោយ ALT/AST>5x ULN ឈប់ប្រើឱសថ |
| Hyperbilirubinaemia | IDV | គ្មាន | គ្មាន | មិនចាំបាច់ |
| លើសជាតិស្ករក្នុងឈាម/ទឹកនោមផ្អែម | All PIs | ភាពស្លឹក ហូបច្រើន នោមច្រើន ផឹកទឹកច្រើន | ចៀសវាងប្រើ ប្រសិនបើ ទឹកនោមផ្អែម | ប្រសិនបើ ទឹកនោមផ្អែម ត្រូវប្រើ metformin ។ បើគ្មានប្រសិទ្ធភាព ឈប់ PI |
| លើសជាតិខ្លាញ់ក្នុងឈាម (Hyperlipideamia) | All PIs, especially RTV | គ្មាន | ចៀសវាង ប្រសិនបើ លើសជាតិខ្លាញ់ក្នុងឈាមកើនឡើង | បន្ត PI ហើយ បន្ថែមឱសថបញ្ចុះជាតិខ្លាញ់ ។ បើគ្មានប្រសិទ្ធភាព ឈប់ប្រើ PI |
| Hypersensitivity syndrome | ABC, NVP | កន្ទួលស្បែក (ពិសេស NVP ), គ្រុនក្តៅ, រលាកថ្លើម, eosinophilia | គ្មាន | ឈប់ប្រើឱសថ និង មិនត្រូវប្រើឡើងវិញទៀតទេ ដែលអាចបណ្តាលអោយស្លាប់បាន |
| គ្រួសក្នុងតំរងនោម | IDV | ឈឺចាប់នៅតំបន់ផ្នែកខាងក្រោមពោះ , នោមឈាម | - បំពេញជាតិទឹក<br>- ផឹកទឹកលើសពី ១.៥លក្នុង ១ ថ្ងៃ | ឈប់ប្រើ IDV បំពេញជាតិទឹក និងឱសថបំបាត់ការឈឺចាប់ ប្រើ IDV ឡើងវិញ ក្នុងករណីលែងមានផលប៉ះពាល់កើតឡើងវិញផ្ទួនៗ |

| | | | | |
|---|---|---|---|---|
| Lactic acidosis | AZT, d4T, ddI | ភាពស្ពឹក ចង្អោរ ក្អួត រាគ និង ពិកបាកដកដង្ហើម | ចៀសវាង d4T + ddI (ពិសេស ពេលមានផ្ទៃពោះ) | មើលតារាងទី ១១ |
| ការផ្លាស់ប្តូរជាតិខ្លាញ់ Lipody-strophy | គ្រប់ (ពិសេស AZT, d4T and ddI នាំអោយផ្លាស់ប្តូរជាតិខ្លាញ់ និង PIs ដែលមានការប្រមូលផ្តុំជាតិខ្លាញ់ ) | ការបាត់បង់ជាតិខ្លាញ់នៅតំបន់ peripheral ធាត់ប្រមូលផ្តុំជាតិខ្លាញ់នៅក្នុងសរីរាង្គ " Buffalo hump" និងឡើងដោះ | ថ្លឹងថ្លែង ក្នុងការប្រើប្រាស់ឱសថផ្សេងទៀតក្រៅពី d4T និង PIs | ឈប់ប្រើ d4T ឬ AZT |
| ជំងឺសាច់ដុំ (Myopathy) | AZT | ស្ពឹតសាច់ដុំ និង ចុះខ្សោយ | គ្មាន | ឈប់ប្រើ AZT |
| ចង្អោរ/ក្អួត | AZT, ddI, RTV, LPV/r | ចង្អោរ ក្អួត | គ្មាន | -ពិនិត្យមើលមូលហេតុផ្សេង ព្យាបាលតាមរោគសញ្ញា ។ ឈប់ប្រើប្រសិនបើធ្ងន់ធ្ងរ |
| ការថយចុះគ្រាប់ឈាមស | AZT | គ្មាន | ពិនិត្យគ្រាប់ឈាម (CBC) មុនពេលចាប់ផ្តើមប្រើ ។ ចៀសវាង AZT ប្រសិនបើគ្រាប់ឈាមស $1x10^6$/ល ពិនិត្យគ្រាប់ឈាម (CBC) នៅសប្តាហ៍ទី ៤ ម្តងទៀត | គ្រាប់ឈាមស > $1x10^6$/l ពិនិត្យគ្រាប់ឈាម (CBC) នៅអាទិត្យទី ២ - ៤ ម្តងទៀត គ្រាប់ឈាមស < $1x10^6$/l ឈប់ AZT |
| រលាកលំពែង | d4T, ddI | ចង្អោរ ក្អួត ឈឺពោះ | ចៀសវាង ddI, d4T ប្រសិនបើ បណ្តាលអោយរលាកលំពែង | ពិនិត្យ Amylase. ឈប់ប្រើប្រសិនបើ Amylase > 500 ឬ ធ្ងន់ធ្ងរ |

| | | | | |
|---|---|---|---|---|
| Peripheral neuropathy | d4T, ddI | ស្ពឹកនៅតំបន់ជុំវិញ (Peripheral numbness) ស្ទើបឈឺ ឬ ខ្សោយ | ថ្លឹងថ្លែង ប្រើប្រាស់ឱសថដទៃទៀត ក្រៅពី d4T និង ddI | ឈប់ប្រើ រហូតដល់ធូរស្រាល |
| កន្ទួលស្បែក (Rash) | ABC, NVP | ផ្ទាំងស្បែកក្រហម ពងទឹក ដំបៅនៅលើ mucosal | ចាប់ផ្តើមប្រើថ្នាំ NVP កំរិតទាប រយៈពេល ២ សប្តាហ៍ដំបូង | ABC: ឈប់ប្រើឱសថ និងមិនត្រូវប្រើឡើងវិញទៀតទេ NVP: ឈប់ប្រើឱសថ ប្រសិនបើធ្ងន់ធ្ងរ ពងទឹក ដំបៅនៅតាម mucosal ឬមានគ្រុនក្តៅ |
| កូនកើតមិនធម្មតា Teratogenicity | EFV | Congenital defects (ការប៉ះពាល់លើកំណើតកូន) | ចៀសវាង EFV ប្រសិនបើមានផ្ទៃពោះ | ឈប់ប្រើ EFV |

## ឧបសម្ព័ន្ធទី ២.១ ~ ការគ្រប់គ្រងផលប៉ះពាល់ធ្ងន់ធ្ងររបស់ឱសថប្រឆាំងមេរោគអេដស៍ប្រភេទ NRTIs

**ចំណាត់ថ្នាក់ផលប៉ះពាល់របស់ឱសថ: lactic acidosis/hepatic toxicity**

- ការកើនឡើងដោយគ្មានរោគសញ្ញានូវជាតិ lactate ក្នុងឈាមកើតឡើងញឹកញាប់នៅលើអ្នកដែលប្រើជំពូកឱសថ NRTIs ។ ប៉ុន្តែ មិនមែនជាកត្តាកំណត់អោយមាន lactic acidosis នោះទេ ។
- ការកើនឡើងដោយមានរោគសញ្ញានូវជាតិ lactate ក្នុងឈាមមិនសូវមានទេ។ ប៉ុន្តែបើកើតមាន ជាទូទៅគឺអាចបណ្តាលឱ្យស្លាប់បាន ( មើលតារាងទី ១១ ខាងក្រោម ) ។
- កត្តាគ្រោះថ្នាក់ ចំពោះ lactic acidosis ដោយការប្រើប្រាស់ឱសថជំពូក NRTIs ពិសេស គឺ d4T និង ddI ។ កត្តាគ្រោះ ថ្នាក់ផ្សេងទៀតគឺ ស្ត្រីធាត់ (high body mass index) ស្ត្រីមានផ្ទៃពោះ និង បណ្តាលអោយកង្វះពពួកវីតាមីន riboflavin និង thiamin ។ រោគសញ្ញាទាំងនោះរួមមាន ចុះខ្សោយ ស្ពឹក ចង្អោរ ក្អួត រាគ និង ពិបាកដកដង្ហើម ។ លទ្ធផលនៃការពិនិត្យមន្ទីរពិសោធន៍ បានបង្ហាញឱ្យឃើញថា កើនឡើង anion gap និងសារជាតិ AST/ALT, Creatinine, Kinase, Lactate Dehydrogenase and Amylase ។ ប្រសិនបើការវាស់វែងរបស់ lactate មិនអាចធ្វើកើត ផ្អែកលើរោគសញ្ញាខាងលើ ជាមួយការកើនឡើង Anion Gap Acidosis និង កើតឡើងតេស្តមុខងារថ្លើមមិនធម្មតា (AST/ALT] គឺអាចសន្និដ្ឋាន បានថាជា Lactic Acidosis ហើយ ។
- ឈប់ប្រើប្រាស់ជំពូកឱសថ NRTIs ជាបន្ទាន់ក្នុងករណីសង្ស័យ ។ ការព្យាបាលតាមរោគសញ្ញា ដោយបំពេញជាតិទឹក ជាតិបីការបូណាត និង ជំនួយក្នុងការដកដង្ហើម ។
- ចាប់ផ្តើមប្រើឱសថប្រឆាំងមេរោគអេដស៍ម្តងទៀតដោយមិនប្រើ d4T និង ddI ហើយក៏មិនគួរប្រើ AZT ឬ 3TC ព្រោះវាអាចមានការគំរាមកំហែងដល់អាយុជីវិត ឧទាហរណ៍: ការប្រើបញ្ចូល ABC និង TDF ជាមួយ NRTI និង PI ។
- ការកើនឡើងនៃ ALT ឬ AST មាន ៥-១៥% នៅលើអ្នកដែលប្រើប្រាស់ជំពូកឱសថ NRTIs ប៉ុន្តែ ការលេចចេញរោគសញ្ញាមានតិចជាង ១% ។

**តារាងទី ១៧: លក្ខណៈពិសេស និងការគ្រប់គ្រងនៃ hyperlactacmia**

| កំរិត | Lactate (mmol/l) | Frequency (%) | ការគ្រប់គ្រង | | អត្រាស្លាប់ (%) |
|---|---|---|---|---|---|
| | | | គ្មានរោគសញ្ញា | មានរោគសញ្ញា | |
| ធ្ងន់ | > ១០ | ០.១ | បញ្ឈប់ឱសថប្រឆាំងមេរោគអេដស៍ | បញ្ឈប់ឱសថប្រឆាំងមេរោគអេដស៍ | 80 |
| មធ្យម | ៥ — ១០ | ១ | សង្កេត | ស្វែងរកមូលហេតុផ្សេងទៀត និងបញ្ឈប់ឱសថប្រឆាំងមេរោគអេដស៍ | 0 |
| ស្រាល | ២ — ៥ | ៥ | សង្កេត និង រកមើលផលវិបាក metabolic ផ្សេងៗ | ស្វែងរកមូលហេតុផ្សេងទៀត និងពិចារណាបញ្ឈប់ឱសថប្រឆាំងមេរោគអេដស៍ | 0 |

**ចំណាត់ថ្នាក់ផលប៉ះពាល់របស់ឱសថប្រឆាំងមេរោគអេដស៍: ការបាត់បង់ជាតិខ្លាញ់ (Lypoatrophy)**

- Lipoatrophy គឺ ជាផ្នែកមួយរបស់ចង្កោមរោគសញ្ញាបាត់ជាតិខ្លាញ់ ។ រោគសញ្ញានេះហាក់ដូចជាមានទំនាក់ទំនងជាមួយនឹងការប្រើ NRTIs ពិសេស d4T និង AZT ។ វានាំអោយមានការថយចុះជាតិខ្លាញ់នៅតំបន់ជុំវិញ (Peripheral) ពិសេសនៅលើផ្ទៃមុខ ដៃ ជើង និងសាច់កំប៉េះគូថ ដែលបង្ហាញចេញនៅឆ្អឹងថ្ពាល់មុខ និងសសៃឈាមខ្មៅនៅចុងដៃ ចុងជើង ។
- Lipoatrophy កើតមានញឹកញាប់ហើយជាទូទៅលេចចេញច្បាស់បន្ទាប់ពីព្យាបាលបាន មួយ ឬពីរឆ្នាំ ។ ការសិក្សាអង្កេត លើ ការផ្លាស់ប្តូរឱសថដើម្បីព្យាបាលការបាត់បង់ជាតិជុំខ្លាញ់ ជាទូទៅមិនទាន់បានលទ្ធផលដូចបំណងឡើយ ។ ការផ្លាស់ប្តូរ d4T ឬ AZT ទៅ ABC បានបង្ហាញការវិលត្រឡប់ទៅរកភាពដើម peripheral lipoatrophy មានភាពយឺតយ៉ាវ ។ បច្ចុប្បន្នឱសថដែលប្រើនៅក្នុងការព្យាបាល គឺកំពុងស្ថិតនៅក្នុងការសិក្សានៅឡើយ ។

**Zidovudine (AZT)**

- ជំងឺស្លេកស្លាំង និងជំងឺខ្វះគ្រាប់ឈាមស (neutropenia) គឺជាផលប៉ះពាល់ចំបងបំផុត ។ អត្រានៃផលប៉ះពាល់នេះ មានពី ៥ - ១០% ប៉ុន្តែវាមានអត្រាខ្ពស់នៅលើអ្នកដែលមានជំងឺអេដស៍ធ្ងន់ធ្ងរ ។ ការព្យាបាលផលប៉ះពាល់នេះ គឺបន្ថយ កំរិតថ្នាំប្រើប្រាស់ ( ប្រសិនបើមិនធ្ងន់ធ្ងរ) ដោយការបញ្ចូលឈាម និង ការផ្អាកប្រើប្រាស់ឱសថ ។
- ឈឺក្បាល ចង្អោរ និង អស់កំលាំង ដែលកើតមានប្រហែល ៥ - ១០% ប៉ុន្តែ វានឹងបាត់ទៅវិញ ក្នុងរយៈពេល ពីរ ឬ បីសប្តាហ៍ ។
- ជំងឺសាច់ដុំជាមួយការឈឺសាច់ដុំចុះខ្សោយ និងស្វិតដែលអាចកើតមានឡើង ហើយជាទូទៅ និងវិលត្រឡប់ទៅរកសភាពដើមនៅពេលឈប់ប្រើ AZT ។

**Stavudine (d4T)**

- ផលប៉ះពាល់សំខាន់ៗ នៃ d4T គឺ peripheral neutropathy ។ ផលប៉ះពាល់នេះមានញឹកញាប់ និងធ្ងន់ធ្ងរនៅពេលដែលប្រើឱសថនេះក្នុងកំរិតខ្ពស់ និងរយៈពេលយូរ ជំងឺអេដស៍ធ្ងន់ធ្ងររួមផ្សំជាមួយជាតិឱសថដទៃទៀតដែលពុលដល់សសៃប្រសាទ (neurotoxic drug) ពិសេសគឺ ddI ។ រោគសញ្ញានេះ អាចបាត់ទៅវិញជាបន្តបន្ទាប់ក្នុងរយៈពេល ពីរ ឬបីសប្តាហ៍បន្ទាប់ពីឈប់ប្រើ d4T ។
- d4T ប្រហែលជាផ្តល់ផលប៉ះពាល់ដែលជំពូក NRTI ជាងថ្នាក់ដទៃទៀតក្នុងក្រុមនេះ ដែលអាចបណ្តាលឱ្យមាន lactic acidosis ពុលថ្លើម និង បាត់បង់ជាតិខ្លាញ់ ។
- d4T ក៏អាចបណ្តាលអោយរលាកលំពែង និងជាញឹកញាប់ នៅពេលប្រើជាមួយ ddI ។
- ចង្កោមរោគសញ្ញា Guillam-Barre កើតឡើងដោយសារការប្រើ d4T ។ ប្រសិនបើមានសញ្ញាណាមួយជាប់ជាប្រចាំ ឧទាហរណ៍ សាច់ដុំចុះខ្សោយ គួរតែ ឈប់ប្រើ d4T ។

**Lamivudine (3TC)**

- 3TC និង FDC ងាយស្រួលប្រើ ហើយមាន ផលប៉ះពាល់តិចតួចបំផុត ។
- ផលប៉ះពាល់មានដោយកំរ ប៉ុន្តែអាចបណ្តាលអោយមានឈឺក្បាល វិលមុខ ចង្អោរ ក្អួត រាគ រលាកលំពែង peripheral neutropathy ជំងឺខ្វះគ្រាប់ឈាមស (neuropenia) និង ពុលថ្លើម (hepatic toxicity) ។

**Didanosine (ddI)**

- ផលប៉ះពាល់សំខាន់ៗនៃ ddI គឺ peripheral neutropathy និងរលាកលំពែង ។ Peripheral neutropathy កើតមានប្រហែល ៦-១៥% នៃអ្នកប្រើប្រាស់ឱសថនេះ ។ ផលប៉ះពាល់កើនឡើងប្រសិនបើប្រើពេលជាមួយគ្នា d4T ។ ប៉ុន្តែរោគសញ្ញានេះ និងបាត់ទៅវិញ ក្នុងរយៈពេល ពីរ ឬ បីសប្តាហ៍ក្រោយពេលឈប់ប្រើឱសថនេះ ជួយកាលផលប៉ះពាល់អាចស្ថិតនៅយូរអង្វែង និង ចុះសួម ។
- ការរលាកលំពែង កើតមានពី ១ - ៧% នៃអ្នកប្រើប្រាស់ និងបណ្តាលអោយស្លាប់ ១% ។ កត្តាគ្រោះថ្នាក់កើតឡើងនៅពេលប្រើកំរិតឱសថខ្ពស់, អ្នកផឹកជាតិស្រវឹងច្រើន អ្នកដែលមានលើសជាតិខ្លាញ់ក្នុងឈាម គ្រួសក្នុងថង់ទឹកប្រមាត់ និងការប្រើប្រាស់ឱសថដទៃទៀតដែលបណ្តាលអោយរលាកលំពែង ដូចជា d4T ។ ត្រូវតែឈប់ប្រើ ddI ប្រសិនជាបើមានរលាកលំពែង។
- ddI ក៏អាចបណ្តាលអោយ រាគ ចង្អោរ ក្អួត ឬ ឈឺពោះ ក្នុងចំណោម ៥ - ១៨ % នៃអ្នកប្រើប្រាស់ ។

**Abacavir (ABC)**

- ផលប៉ះពាល់សំខាន់ៗ នៃ ABC គឺ hypersensitivity syndrome ដែលកើតមានឡើង ៣-៥% នៃអ្នកប្រើប្រាស់ឱសថនេះ និង អាចបណ្តាលអោយស្លាប់ ។ រយៈពេលជាមធ្យមរហូតដល់លេចចេញជារោគសញ្ញា មានរយៈពេលមួយសប្តាហ៍ក្រោយពីពេលប្រើ ABC និង ជាង ៩០% នៃករណី ដែលកើតមាននៅ ៦ សប្តាហ៍តំបូង ប៉ុន្តែ វាក៏អាចកើតមានគ្រប់ពេលនៃការព្យាបាលផងដែរ ។
- រោគសញ្ញាដែលកើតមានៈ
    - គ្រុនក្តៅ កើតមានជាញឹកញាប់
    - Rash កើតមានញឹកញាប់
    - ប្រព័ន្ធរំលាយអាហារៈ ចង្អោរ ក្អួត រាគ និង ឈឺពោះ
    - ប្រព័ន្ធដកដង្ហើមៈ រលាកបំពងក ក្អក ថប់ដង្ហើម
    - ឈឺសន្លាក់ទូទៅ ឈឺសាច់ដុំ ឈឺក្បាល មិនស្រួលខ្លួន
- ការពិនិត្យបង្ហាញអោយឃើញថា មានគ្រុនក្តៅ ស្នាមកន្ទួលសើស្បែក ឡើងកូនកណ្តុរ និង ដំបៅ mucosal។ ការពិនិត្យអមគ្លីនិក បានបង្ហាញថាមានការកើនឡើង Enzyme ថ្លើម creatinie kinase, creatinine and thrombocytopenia ។
- ដើម្បីញែកពីជំងឺដទៃទៀត គឺមានការលំបាកណាស់ ។ លក្ខណៈជាច្រើន របស់ ABC hypersensitivity រួមមានៈ
    - ការពាក់ព័ន្ធ ជាមួយសរីរាង្គជាច្រើន ឧទាហរណ៍ រោគសញ្ញាប្រព័ន្ធរំលាយអាហារ និង ប្រព័ន្ធដកដង្ហើម
    - ការកើតឡើងភ្លាមៗនៃចង្កោមរោគសញ្ញា
    - រោគសញ្ញាកាន់តែធ្ងន់ធ្ងរ នៅពេលដែលកំរិតឱសថ ABC ត្រូវបានប្រើប្រាស់បន្តទៀត ។
- អ្នកដែលប្រើឱសថ ABC ត្រូវតែពិគ្រោះយោបល់ ចំពោះរោគសញ្ញា hypersensitivity ហើយនិងផ្តល់យោបល់ដើម្បីប្រាប់ពីរោគសញ្ញាណាមួយដែលកើតមានភ្លាមៗ ។ ប្រសិនបើ hypersensitivity ត្រូវបានសង្ស័យដោយមន្ត្រីសុខាភិបាលឱសថត្រូវឈប់ប្រើ ABC ហើយ និងមិនត្រូវប្រើឡើងវិញទេ ពីព្រោះវាអាចបណ្តាលអោយស្លាប់ដោយប្រតិកម្មឱសថនេះ ។ ការគ្រប់គ្រងផលប៉ះពាល់នេះ គឺការព្យាបាលតាមរោគសញ្ញាហើយគ្មានហេតុផលណាដែលត្រូវប្រើ steroids នោះទេ ។

**រូបភាពទី ១ : ទំនាក់ទំនង ddI និង ការរលាកលំពែង:**



## រូបភាពទី ២ : ការថយចុះគ្រាប់ឈាមដោយ AZT



## រូបភាពទី ៣ : ការពុលថ្លើមដោយឱសថប្រឆាំងមេរោគអេដស៍ (ART-associated liver toxicity)



**ឧបសម្ព័ន្ធទី ២.២. ការគ្រប់គ្រងផលប៉ះពាល់ធ្ងន់ធ្ងររបស់ឱសថប្រឆាំងមេរោគអេដស៍ប្រភេទ NtRTIs Tenofovir (TDF)**

- TDF ងាយស្រួលប្រើ និង មានផលប៉ះពាល់តិចតួច ។ រោគសញ្ញានៃផលប៉ះពាល់របស់ **TDF** អាចមានៈ ចង្អោរ ក្អួត និង រាគ ប៉ុន្តែ មិនធ្ងន់ធ្ងរទេ ។ មានករណី Fanconi Syndrome និង ខូចតំរងនោមផងដែរ ប៉ុន្តែ មូលហេតុច្បាស់លាស់ មិនទាន់អាចកំណត់បានទេ ។

**ឧបសម្ព័ន្ធទី ២.៣. ការគ្រប់គ្រងផលប៉ះពាល់ធ្ងន់ធ្ងររបស់ឱសថប្រឆាំងមេរោគអេដស៍ប្រភេទ Non-Nucleoside Reverse Transcriptase Inhibitors (NNRTIs)**

**ចំណាត់ថ្នាក់ផលប៉ះពាល់:** ស្នាមកន្ទួលលើស្បែក (Rash) និង រលាកថ្លើម

- Rash អាចកើតមានឡើងដោយការប្រើរួមគ្នា NVP និង EFV ប៉ុន្តែ ស្នាមកន្ទួលស្បែកធ្ងន់ធ្ងរ រួមមាន Stevens-Johnson Syndrome អាចកើតមានចំពោះ តែការប្រើ NVP ទេ ។
- មិនមានប្រតិកម្មខ្វែងគ្នា ដែលបណ្តាលឱ្យមាន Rash រវាង NVP និង EFV ទេ។ ដូច្នេះអាចប្រើ EFV បាន ប្រសិនបើ Rash កើតឡើងដោយការប្រើ NVP និងផ្ទុយមកវិញ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើ Rash ដោយសារការប្រើ NVP មានភាពធ្ងន់ធ្ងរ ឬ រួមផ្សំជាមួយការប៉ះពាល់ដល់ mucosal, ក្នុងករណីនេះ មិនគួរប្រើ EFV ទេ ។
- ជំងឺរលាកថ្លើមអាចកើតមានឡើងដោយសារប្រើ NVP និង EFV ប៉ុន្តែ ជាញឹកញាប់កើតឡើងដោយសារការប្រើ NVP (មើលតារាង ១១) ។ ដើម្បីអោយមានសុវត្ថិភាពត្រូវប្រើប្រាស់ឱសថផ្សេងទៀត បើជំងឺរលាកថ្លើមកើតមាន ឡើងដោយសារការប្រើ NVP ឬ EFV លើកលែងតែជំងឺរលាកថ្លើមមានសភាពធ្ងន់ធ្ងរ ឬ គំរាមគំហែងដល់អាយុជីវិត ។

**តារាងទី ១៨ :ផលប៉ះពាល់របស់ NNRTI (Grade3/4) ក្នុងការសិក្សា 2NN**

| **ភាគរយ** | **NVP 400mg ម្តងក្នុងមួយថ្ងៃ** | **NVP 200mg ២ ដងក្នុងមួយថ្ងៃ** | **EFV 600mg ម្តងក្នុងមួយថ្ងៃ** |
|---|---|---|---|
| ចេញរោគសញ្ញាគ្លីនីកនៃពុលថ្លើម | ១.៤ | ២.១ | ០.៣ |
| ចេញរោគសញ្ញាមន្ទីរពិសោធន៍នៃការពុលថ្លើម | ១៣.២ | ៧.៨ | ៤.៥ |
| ពុលដល់ប្រព័ន្ធសរសៃប្រសាទកណ្តាល | ១.៨ | ៤.៩ | ៦.៥ |
| ឈប់ប្រើប្រាស់ដោយសារជាតិពុល | ២៤.១ | ២១.២ | ១៥.៥ |

**Nevirapine (NVP)**

- ផលប៉ះពាល់ចំបងៗ នៃ NVP គឺ Rash និង ជំងឺរលាកថ្លើម ។
- Rash កើតមាន ១៧% នៃអ្នកប្រើប្រាស់ ហើយមានសភាពធ្ងន់ធ្ងរបណ្តាលអោយឈប់ប្រើប្រាស់ឱសថមានពី ៦-៨% ហើយ Stevens-Johnson syndrome ឬ ពុលស្បែករលួយ (toxic epidermal necrosis) កើតមាន ០.៣% ។
- Rash ជាញឹកញាប់កើតមានឡើងក្នុងរយៈពេល ២-៤សប្តាហ៍ដំបូងនៃការប្រើប្រាស់ ។ ជាធម្មតា ផ្ទាំងស្បែកក្រហម ពងទឹក នៅលើផ្ទៃ និង លើដងខ្លួន និងដៃ ។ គ្រុនក្តៅ ឈឺសាច់ដុំ រលាកថ្លើម និង eosinophilia កើតមានឡើងដែរ ។
- ប្រសិនបើ ស្នាមកន្ទួលស្បែកតិចតួច (mild to moderate) ដោយគ្មានរោគសញ្ញាផ្សេងទៀត ឬគ្មានការដាច់ដោចដល់ mucosal ទេ NVP អាចប្រើបន្តដោយប្រុងប្រយ័ត្ន ។ នៅពេលដែលកើតមាន rash ត្រូវប្រើ NVP ដោយកំរិតដូសទាប

ក្នុងរយៈ២ សប្តាហ៍ដំបូង ហើយត្រូវឈប់ប្រើគ្រប់ឱសថប្រឆាំងមេរោគអេដស៍ទាំងអស់ និងចាប់ផ្តើម ART ឡើងវិញ រួមទាំង NVP ។ ដោយការប្រើឆ្លាស់គ្នា NVP អាចប្រើបន្តប៉ុន្តែមិនត្រូវអោយកំរិតដូសពេញលេញទេ រហូតដល់បាត់ rash ។ Steroids មិនមានប្រយោជន៍ទេ ។

- ❖ ប្រសិនបើមានសញ្ញាណាមួយដែលបង្ហាញឡើងដូចខាងក្រោមនេះ ត្រូវបញ្ឈប់ការប្រើ NVP ជាស្ថាពរ ហើយទាំង EFV មិនត្រូវប្រើនៅថ្ងៃអនាគតទៀតទេ:
  - ♦ ជំងឺស្បែកធ្ងន់ធ្ងរ (severe rash)
  - ♦ Rash ជាមួយ ពងទឹកធំៗ ឬ ដាច់ស្បែក
  - ♦ មានការដាច់ដោចដល់ mucosal
  - ♦ Hypersensitivity គ្រុនក្តៅ ឈឺសាច់ដុំ រលាកថ្លើម និង eosinophilia
- ❖ ការរលាកថ្លើមអាចកើតឡើងតែឯកឯង ឬ ជាមួយ rash ឬ hypersensitivity syndrome ។ ភាពមិនធម្មតានៃការធ្វើតេស្តមុខងារថ្លើម កើតមាន ១៥% និងសញ្ញាគ្លីនិករលាកថ្លើមមានពី ១-៥% ។ ភាពខ្សោយថ្លើម និង ស្លាប់ អាចកើតឡើងដោយកំរ ។ ២ ភាគ ៣នៃ ករណីនេះ កើតឡើងនៅ ៣ខែដំបូងនៃការប្រើប្រាស់ NVP ហើយក៏អាចឡើងគ្រប់ពេលផងដែរ ។
- ❖ កត្តាគ្រោះថ្នាក់របស់ NVP រួមជាមួយការរលាកថ្លើម និង មានភាពមិនធម្មតានៃមុខងាររបស់ថ្លើម នៅពេលចាប់ផ្តើមប្រើប្រាស់ថ្នាំនេះ, អ្នកដែលផឹកជាតិស្រវឹងច្រើន, មានអាយុច្រើន, ស្ត្រីភេទ, មានរលាកថ្លើមប្រភេទ B ឬ C និង មានចំនួនកោសិកា CD4 ខ្ពស់ ។
- ❖ រោគសញ្ញាជាទូទៅមិនច្បាស់លាស់: មិនស្រួលខ្លួន ធុំបាយ ចង្អោរ និង ក្អួត ។ គួរកត់សំគាល់ថាឈឺពោះ និងចេញលឿង មិនកើតមាននៅគ្រប់ករណីទេ ។ ដូចការបកស្រាយខាងលើ ជំងឺរលាកថ្លើមកើតមានដែលជាផ្នែកមួយនៃ hypersensi - tivity syndrome ជាមួយ rash គ្រុនក្តៅមិនស្រួលខ្លួន និង eosinophilia ។
- ❖ ប្រសិនបើ រលាកថ្លើមកើតមានដោយការប្រើ NVP នោះត្រូវបញ្ឈប់ជាស្ថាពរ ។ EFV អាចប្រើប្រសិនបើ រលាកថ្លើមមិនធ្ងន់ធ្ងរ ឬគំរាមកំហែងដល់អាយុជីវិត ។

**Efavirenz (EFV)**

- ❖ ផលប៉ះពាល់សំខាន់ៗ នៃ EFV គឺ ប៉ះពាល់លើ ប្រព័ន្ធសសៃប្រសាទកណ្តាល ។
- ❖ ផលប៉ះពាល់នេះមាន ៣០-៥០% នៃអ្នកប្រើប្រាស់ និងមានវិលមុខ ឈឺក្បាល ដេកមិនលក់ អស់សង្ឃឹម រវើរវាយ សុបិនអាក្រក់ និងងងុយដេក ហើយរោគសញ្ញាទាំងនេះ អាចកើតមានឡើងក្រោយពេលប្រើប្រាស់ **EFV** ២-៣ សប្តាហ៍ ។ តិចជាង២% នៃអ្នកប្រើឱសថនេះអាចកើតមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ដូចជាការអស់កំលាំងចិត្តទាំងស្រុង មានគំនិតចង់សំលាប់ខ្លួន ឆ្កួត និងវង្វេងវង្វាន់ ។ សញ្ញាទាំងនេះអាចកើតមានឡើងចំពោះអ្នកដែលមានប្រវត្តិ ជំងឺខួរក្បាលពីមុនមក ឬ ប្រើប្រាស់ឱសថមួយ ។
- ❖ ប្រសិនបើមានរោគសញ្ញាតិចតួច EFV អាចប្រើបន្តបាន និងអោយលេបនៅពេលយប់ ដើម្បីកាត់បន្ថយផលប៉ះពាល់របស់វា ។ ប្រសិនបើផលប៉ះពាល់មានសភាពធ្ងន់ធ្ងរ EFV ត្រូវឈប់ប្រើជាអចិន្ត្រៃ ។

- ផលប៉ះពាល់ផ្សេងៗទៀត របស់ EFV គឺ rash និង រលាកថ្លើម (មើលចំណាត់ថ្នាក់ផលប៉ះពាល់: rash និង រលាកថ្លើម ទំព័រ ៥៤) ។ វាក៏អាចបណ្ដាលអោយមានកើតទារកមិនធម្មតា (teratogenic) ដែរដូចនេះមិនត្រូវប្រើប្រាស់ឱសថនេះចំពោះស្ត្រីមានផ្ទៃពោះទេ ពិសេសក្នុងត្រីមាសដំបូង ។

## រូបភាពទី ៤ : NNRTI-associated rash



### រូបភាពទី ៥ : EFV-associated CNS symptoms



## ឧបសម្ព័ន្ធទី ២,៤ ~ ការគ្រប់គ្រងផលប៉ះពាល់របស់ឱសថប្រឆាំងមេរោគអេដស៍ប្រភេទ

**Protease Inhibitors (PIs)**

**ចំណាត់ថ្នាក់ផលប៉ះពាល់លើ metabolic**

- គ្រប់ឱសថ PIs ទាំងអស់ អាចបណ្តាលអោយមានផលប៉ះពាល់ដល់ metabolic របស់រាងកាយ ដែលរួមមានវិបត្តិជាតិខ្លាញ់ (lipodystrophy) ភាពស៊ាំជាមួយ Insulin និង ទឹកនោមផ្អែម និង លើសជាតិខ្លាញ់ក្នុងឈាម ។

**ចំណាត់ថ្នាក់ផលប៉ះពាល់: ការប្រែប្រួលនៃជាតិខ្លាញ់ (lipodystrophy)**

- ចង្កោមរោគសញ្ញាទាំងនេះរួមមាន ការបាត់បង់ជាតិខ្លាញ់ក្រោមស្បែក (Peripheral lipoatrophy) ដែលកើតមានដោយការប្រើក្រុមឱសថ NRTIs ពិសេស d4T និង ការប្រមូលផ្តុំជាតិខ្លាញ់នៅពោះ ( ធាត់ "central obesity" ការប្រមូលផ្តុំជាតិខ្លាញ់នៅកញ្ចឹងក "buffalo hump" និង ឡើងដោះដែលកើតឡើងដោយការប្រើក្រុមជំពូក PIs។ ផលវិបាករបស់ការព្យាបាល ដោយក្រុមជំពូក PIs ជាញឹកញាប់ រួមផ្សំជាមួយផលវិបាក metabolic ផ្សេងៗទៀត ។
- ការប្រែប្រួលនៃជាតិខ្លាញ់ (lipodystrophy) កើតមានមួយភាគធំនៅលើអ្នកជំងឺដែលប្រើរួមគ្នា NRTIs និង PIs។ ជាទូទៅកើតមានក្រោយពីការព្យាបាលបាន ១ ឬ ២ ឆ្នាំ ។ ការសិក្សាស្រាវជ្រាវពីការផ្លាស់ប្តូរឱសថ នៅក្នុងការគ្រប់គ្រង lipodystrophy ជាទូទៅពុំបានលទ្ធផលអ្វីទេ ។ ការប្តូរពី PIs ទៅ Non-PIs មិនបានបង្ហាញផលចំណេញធំដុំឡើយ ។ ការផ្លាស់ប្តូរ d4T ឬ AZT ទៅ ABC បានបង្ហាញការវិលត្រឡប់ទៅរកភាពដើមយ៉ាងយឺតយ៉ាវនៃ peripheral lipoatrophy ។ បច្ចុប្បន្ន ឱសថដែលអាចយកប្រើ ដើម្បីព្យាបាល វិបត្តិជាតិខ្លាញ់ គឺ ស្ថិតនៅក្នុងការសិក្សានៅឡើយ ។

**ចំណាត់ថ្នាក់ផលប៉ះពាល់: ភាពស៊ាំរបស់ Insulin និង ជំងឺទឹកនោមផ្អែម**

- ភាពស៊ាំជាមួយ Insulin កើតមានរហូតដល់ ៤០% នៃអ្នកប្រើប្រាស់ក្រុមឱសថ PIs , លើសជាតិស្ករក្នុងឈាម មានពី ៣-១៧% និង ជំងឺទឹកនោមផ្អែមដែលមានរោគសញ្ញាគ្លីនិក មាន ១%។ វាអាចចាប់ផ្តើមកើតមានឡើង ជាទូទៅ ២ ឬ ៣ខែ ក្រោយការព្យាល ។
- រោគសញ្ញាកើតមានឡើង គឺជារោគសញ្ញាទឹកនោមផ្អែម : ស្លឹក ស្រេកទឹក នោមច្រើន និង ហូបច្រើន ។
- PIs អាចប្រើបន្តជាមួយឱសថព្យាបាលទឹកនោមផ្អែម ។ ការសិក្សាបន្ត បានបង្ហាញថា metformin ប្រហែលជាឱសថជួរមុខ ក្នុងការព្យាបាលជំងឺទឹកនោមផ្អែម ។ ប្រសិនមានភាពធ្ងន់ធ្ងរ និងពិបាកគ្រប់គ្រង PIs ត្រូវឈប់ប្រើ ។ ការលើសជាតិស្ករ ក្នុងឈាម ជាធម្មតាបាត់វិញបន្ទាប់ពីឈប់ប្រើឱសថ ប៉ុន្តែមិនគ្រប់ករណីទាំងអស់ទេ ។

**ចំណាត់ថ្នាក់ផលប៉ះពាល់: ការឡើងនៃជាតិខ្លាញ់ក្នុងឈាម**

- ក្រុមឱសថ PIs ទាំងអស់អាចបណ្តាលអោយជាតិខ្លាញ់កើនឡើង (triglycerides and choesterole) ប៉ុន្តែ RTV ធ្វើអោយកើនឡើងជាតិខ្លាញ់គួរអោយកត់សំគាល់ ទោះជាការកើនឡើងនៃជាតិខ្លាញ់បានបង្កើនអោយមានគ្រោះថ្នាក់នៃជំងឺបេះដូង គឺមិនទាន់ច្បាស់នៅឡើយ ។
- ត្រូវបានចាប់ផ្តើម ព្យាបាលជំងឺលើសជាតិខ្លាញ់នៅក្នុងឈាមដោយឱសថ :

- **ការកើនឡើង LDL Cholesterol** តែងងត្រូវព្យាបាលដោយប្រើឱសថ statin, pravastatin ព្រោះថា ឱសថនេះមិនសូវមានអន្តរកម្មជាមួយ PIs ។ ចាប់ផ្តើមដោយកំរិតថ្នាំទាបនិងប្រុងប្រយ័ត្នពីការវិវត្តន៍ទៅរកជំងឺសាច់ដុំបេះដូង (Myopathy) ។
- **ការកើនឡើង triglycerides** តែងងត្រូវ ព្យាបាលជាមួយ fibrates ឧទាហរណ៍ gemfibrozil or fenofibrate ។ ការកើនឡើងនៃ LDL Cholesterol and triglycerides អាចព្យាបាលដោយ statin ឬ fibrate ។ លទ្ធផលនៃសិក្សាបានបង្ហាញថា ការព្យាបាលនេះពុំមានប្រសិទ្ធិភាពនៅក្នុងការបន្ថយជាតិខ្លាញ់អោយទាបដល់កំរិតធម្មតាបាន (LDL Cholesterol or triglycerides) ទេ ។ ការព្យាបាលដោយបញ្ចូលរួមគ្នារវាង statin និង fibrates ប្រហែលជាមានប្រសិទ្ធិភាពខ្ពស់ ប៉ុន្តែបង្កើនគ្រោះថ្នាក់ ជំងឺសាច់ដុំបេះដូង ។ ប្រសិនបើមានការកើនឡើងជាតិខ្លាញ់ខ្លាំង គឺផ្លាស់ប្តូរពី PIs ទៅចំណាត់ថ្នាក់ឱសថជំពូកផ្សេងទៀត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការប្រែប្រួលជាតិខ្លាញ់មិនធម្មតាអាចស្ថិតនៅជាប់ជាប្រចាំដែរ ។

**ចំណាត់ថ្នាក់ផលប៉ះពាល់: រលាកថ្លើម**

- ជំពូកឱសថ PIs ពិសេស RTV អាចបណ្តាលអោយមានការកើនឡើង Enzymeរបស់ថ្លើម និងមានសញ្ញាគ្លីនិកនៃការរលាកថ្លើមនៅពេលណាមួយ ក្នុងកំឡុងពេលព្យាលដោយប្រើប្រាស់ឱសថ PIs ក៏ប៉ុន្តែយន្តកម្មរបស់វានៅមិនទាន់បានដឹងច្បាស់នៅឡើយទេ ។
- កត្តាគ្រោះថ្នាក់រួមមាន ការកើនឡើងនៃមុខងាររបស់ថ្លើមនៅមុនពេលចាប់ផ្តើមព្យាបាល, អ្នកផឹកជាតិស្រវឹងច្រើន, រលាកថ្លើមប្រភេទ B និង/ឬ C និង ការប្រើប្រាស់ប្រភេទថ្នាំដែលបណ្តាលឱ្យពុលដល់ថ្លើម ដូចជា d4T ។
- ការកើនឡើងតិចតួចនៃ Enzyme របស់ថ្លើម ដែលអាចកើតមានឡើង និង អាចបន្តការប្រើប្រាស់ PIs បាន ។ នៅក្នុងករណីដែលមានការកើនឡើងខ្លាំង ឬ មានរោគសញ្ញាគ្លីនិកជំងឺរលាកថ្លើម ត្រូវបញ្ឈប់ ការប្រើប្រាស់ PIs ត្រូវឈប់ជាអចិន្ត្រៃ ។

**ចំណាត់ថ្នាក់ផលប៉ះពាល់: ការផ្លាស់ប្រែប្រួលនៃឆ្អឹង** (bone disorders)

- រូបមន្តនៃការព្យាបាល (Regimens) ដែលមានជំពូកឱសថ PIs ហាក់បីដូចជាមានការកើនឡើងនៅគ្រោះថ្នាក់ ដូចជា Osteopenia ពុកឆ្អឹង (osteoporosis) និង avascular necrosis ។

**Nelfinavir (NFV)**

- NFV មានភាពងាយស្រួលប្រើប្រាស់ ហើយផលប៉ះពាល់របស់វាអាចកើតឡើងតែនៅលើប្រព័ន្ធរំលាយអាហារ ។ ការរាគរូសមានជាញឹកញាប់ ដែលកើតមានឡើងយ៉ាងឆាប់រហ័សបន្ទាប់ពីចាប់ផ្តើមប្រើ NFV ហើយជាធម្មតាវានឹងបាត់ទៅវិញ រយៈពេល ២ ឬ ៣ សប្តាហ៍ និង ការឈឺពោះ និង flatulence ក៏អាចកើតមានដែរ ។

**Indinavir/ritonavir (IDV/r)**

- ផលប៉ះពាល់សំខាន់ៗរបស់ IDV គឺ គ្រួសក្នុងតំរងនោមដែលកើតមាន ១០% នៃអ្នកប្រើប្រាស់ ហើយអាចមានរោគសញ្ញាដូចជា ឈឺចាប់នៅចង្កេះ និងនោមឈាម ។ ការគ្រប់គ្រងព្យាបាលតាមរោគសញ្ញាដោយប្រើជាតិទឹក (hydration) និងឱសថបំបាត់ការឈឺចាប់ ។ IDV ត្រូវផ្អាក ២ ឬ ៣ថ្ងៃ រហូតដល់បាត់រោគសញ្ញាបានធូរស្បើយ ។ លើកលែងតែករណី

រោគសញ្ញាកើតមានសារចុះសារឡើង IDV អាចចាប់ផ្តើមម្តងទៀតដោយប្រុងប្រយ័ត្នដោយបំពេញជាតិទឹក ។ អ្នកជំងឺដែលលេបឱសថនេះត្រូវផ្តល់ដំបូន្មានអោយផឹកទឹកយ៉ាងតិច ១,៥ លីត្រក្នុងមួយថ្ងៃ ។

- Hyperbilirubinaemia ដោយមិនមានរោគសញ្ញាកើតមាន ១០% នៃអ្នកប្រើប្រាស់ ហើយជាធម្មតាកើតមាននៅ ២-៣ សប្តាហ៍ដំបូងនៃការព្យាបាល ។ រោគសញ្ញាគ្លីនិក គឺ កើតលឿង ឬកើនឡើង Enzyme របស់ថ្លើម មានដោយកំរ ហើយជាធម្មតាមិនតំរូវអោយមានការព្យាបាលពិសេសណាមួយឡើយ ។
- IDV អាចបណ្តាលអោយមានប៉ះពាល់ដល់ភ្នែក (retinoid-like side effect) និង មានការជ្រុះសក់ ស្បែកស្ងួត បបូរមាត់ស្ងួត និង *ដុះក្រចក (ingrown nails)* ។
- ប្រហែល ៣% នៃអ្នកប្រើប្រាស់ឱសថនេះ កើតមានរោគសញ្ញាភឺ (oesophageal reflux) ។
- សមាសភាគ Ritonavir អាចបណ្តាអោយមាន peri-oral and peripheral parasthesia ។ ផលប៉ះពាល់នេះមិនមានគ្រោះថ្នាក់ទេ ប៉ុន្តែបើធ្ងន់ធ្ងរត្រូវមានការប្តូរឱសថ ។

**Lopinivir/ritonavir (LPV/r)**

- ផលប៉ះពាល់ដ៏ចំបងដែលកើតឡើងដោយសារការប្រើឱសថនេះរួមគ្នា អាចបណ្តាលមកពី សមាសភាព RTV ដូចជា រាគ និង លើសជាតិខ្លាញ់ក្នុងឈាម ។ រលាកលំពែងក៏អាចកើតមានឡើងដែរ ប្រហែលជាបន្ទាប់ពីមាន ការកើនឡើងជាតិស្ករនៅក្នុងឈាម (hypertriglyceride) ហើយ រោគស្ពឹក (parasthesis) ក៏អាចកើតមានដែរ ។

**Saquinavir/ritonavir (SQV/r)**

- ផលប៉ះពាល់ដ៏ចំបងដែលកើតឡើងដោយសារការប្រើឱសថនេះរួមគ្នា ទំនងជាបណ្តាលពីសមាសភាព RTV ដូចជា ចង្អោរ រាគ ឈឺពោះ ឈឺក្បាល រោគស្ពឹក (parasthesis) និងពុលថ្លើម ។

## ឧបសម្ព័ន្ធទី៧: អន្តរកម្មសំខាន់ៗរបស់ឱសថប្រឆាំងមេរោគអេដស៍ (Important ARV drug interactions)

- មានអន្តរកម្ម (interactions) ជាច្រើនកើតមានឡើងរវាង ជំពូកឱសថប្រឆាំងមេរោគអេដស៍ និង ជំពូកថ្នាំដទៃទៀត ។
- តារាងទី ១៩ សង្ខេបពីអន្តរកម្មរបស់ឱសថប្រឆាំងមេរោគអេដស៍សំខាន់ៗ ។ ប៉ុន្តែនៅមានអន្តរកម្ម (interactions) ជាច្រើនទៀតដូចនេះជានិច្ចកាលត្រូវពិនិត្យមើល ឯកសារយោង មុនពេលចេញវេជ្ជបញ្ជាអោយប្រើឱសថថ្មី ។

**តារាងទី ១៩: អន្តរកម្មសំខាន់ៗរបស់ឱសថប្រឆាំងមេរោគអេដស៍**

| ឱសថដែលមានអន្តរកម្ម | NVP | EFV | NFV | IDV/r | LPV/r | SQV/r |
|---|---|---|---|---|---|---|
| **Ketokonazole** | X | ? | OK | | | |
| Rifampicin | ប្រើដោយប្រុងប្រយ័ត្ន | EFV ៨០០ mg ក្នុង មួយ ថ្ងៃ | X | X | X | កំរិតឱសថ ពេញលេញ សំរាប់ ឱសថ ទាំងពីរ មុខនេះ |
| Rifabutin | OK | RBT 450- 600 mg /១ថ្ងៃ | RBT 150mg/d NFV 1000 mg q tds | | | RBT 250mg 2-3/week |
| Caritromycin | OK | X | ? | | ? | |
| Oral contraceptive | X | X | X | X | X | X |
| Methadone | បង្កើន Methadone | បង្កើន Methadone | បង្កើន Methadone | បង្កើន Methadone | បង្កើន Methadone | បង្កើន Methadone |
| 'Statins' | ? | ? | X | | X | X |
| ជំពូកឱសថដទៃទៀត ដែលមិនត្រូវប្រើជាមួយគ្នា | បន្ថែមខ្ទឹមស | Astemizole Terfenadine Cisapride Midazolam Triazolam Ergotamine Dihydro-ergotamine Garlic supplements | Astemizole Terfenadine Cisapride Midazolam Triazolam Ergotamine Dihydro-ergotamine Garlic supplements | Astemizole Terfenadine Cisapride Midazolam Ergotamine Dihydro-ergotamine Garlic supplements Flecanide Pimozide | Astemizole Terfenadine Cisapride Midazolam Ergotamine Dihydro-ergotamine Garlic supplements Flecanide Pimozide | Astemizole Terfenadine Cisapride Midazolam Ergotamine Dihydro-ergotamine Garlic supplements Flecanide Pimozide |
| ផ្សេងៗ | អាចបន្ថយកំរិត Steroid អោយទាប | តាមដាន wafarin ប្រសិនបើប្រើជាមួយគ្នា | | | | |

បន្ថែម ឬ វិធីសាស្ត្រឆ្លាស់គ្នារបស់ឱសថពន្យាកំណើត ត្រូវបានប្រើប្រាស់ ។

## ឧបសម្ព័ន្ធទី៤ : ការដាក់ពិន្ទុ ទៅតាមកាណូហ្វស្គី (Karnofsky Performance Scale)

**តារាងទី ២០: Karnofsky Performance Scale**

| កំរិតមុខងារ | ពិន្ទុ | អធិប្បាយ |
|---|---|---|
| មានលទ្ធភាព ធ្វើការងារធម្មតា មិនចាំបាច់អោយមានការថែទាំពិសេសទេ | ១០០ | ធម្មតា មិនមានការត្អូញត្អែរ មិនមានជំងឺជាក់ស្តែង |
| | ៩០ | មានលទ្ធភាពអនុវត្តសកម្មភាពធម្មតាមានរោគសញ្ញាតិចតួចរបស់ជំងឺ |
| | ៨០ | អាចធ្វើសកម្មភាពធម្មតាបានដោយខំប្រឹង មានរោគសញ្ញាខ្លះរបស់ជំងឺ |
| មិនមានលទ្ធភាពធ្វើការងារអាចស្នាក់នៅផ្ទះ និងថែរក្សាខ្លួន មានការប្រែប្រួល តំរូវការអោយមានជំនួយបន្ថែម | ៧០ | ថែរក្សាខ្លួនឯងបាន មិនមានលទ្ធភាពអនុវត្តសកម្មភាពធម្មតា ឬ ធ្វើការងារ |
| | ៦០ | តំរូវការអោយមានជំនួយខ្លះៗពីអ្នកដទៃ ប៉ុន្តែមានលទ្ធភាពថែរក្សានូវតំរូវការរបស់ខ្លួនមួយចំនួនធំ |
| | ៥០ | តំរូវការអោយមានជំនួយច្រើនពីអ្នកដទៃ និងការថែទាំវេជ្ជសាស្ត្រញឹកញាប់ |
| មិនមានលទ្ធភាពថែរក្សាខ្លួនឯង តំរូវអោយមានការថែរក្សាពីស្ថាប័ន ឬមន្ទីរពេទ្យ ជំងឺ នឹងវិវត្តន៍ទៅមុខយ៉ាងឆាប់បំផុត | ៤០ | គ្មានសមត្ថភាព តំរូវការថែរក្សាពិសេស និងជំនួយពីអ្នកដទៃ |
| | ៣០ | គ្មានសមត្ថភាពទាំងស្រុង តំរូវការអោយសំរាកនៅមន្ទីរពេទ្យ ទោះបីជាមិនទាន់ស្លាប់ក៏ដោយ |
| | ២០ | ឈឺធ្ងន់ សំរាកនៅមន្ទីរពេទ្យជាការចំបាច់ និងការព្យាបាលតាមរោគសញ្ញាជាការចាំបាច់ |
| | ១០ | សេចក្តីស្លាប់ជិតមកដល់ និងដំណើរការនៃសេចក្តីស្លាប់បន្តយ៉ាងឆាប់ |
| | ០ | ស្លាប់ |

បោះពុម្ពលើកទី២

**DFID**